## នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

សៀវភៅ

# បណ្តុះបណ្តាលភ្នាក់ងារ សុខភាពសត្វភូមិ

ដើម្បីលើកកំពស់វិស័យផលិតកម្ម និង បសុព្យាបាល

នៃព្រះរាជាណាចក្រកម្ពុជា



គំរោងបង្កើនផលិតភាពកសិកម្ម

ផ្នែកផលិតកម្ម និង បសុព្យាបាល

IFAD Loan No. 423-KH

បោះពុម្ពលើកទី ៣ ឆ្នាំ ២០០៦

## នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

## សៀវភៅ

# បណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ

ដើម្បីលើកកំពស់វិស័យផលិតកម្ម និង បសុព្យាបាល

នៃព្រះរាជាណាចក្រកម្ពុជា

ម.ព.ឯ.ក AIDOC
Code: 242-08
Date:
Donated by:

បោះពុម្ពដោយ

គំរោងបង្កើនផលិតភាពកសិកម្ម

ផ្នែកផលិតកម្ម និង បសុព្យាបាល

IFAD Loan No. 423-KH

បោះពុម្ពលើកទី ៣

ឆ្នាំ ២០០៦

សៀវភៅបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិនេះ ជាឯកសារបង្គោលទទួលស្គាល់ដោយ
ក្រសួងកសិកម្ម-រុក្ខាប្រមាញ់ និង នេសាទ ដើម្បីប្រើប្រាស់សំរាប់ការបណ្តុះបណ្តាល
ភ្នាក់ងារសុខភាពសត្វភូមិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។


សៀវភៅនេះ បោះពុម្ពលើកទី៣ ដោយគំរោងបង្កើនផលិតភាពកសិកម្ម
ដើម្បីចែកផ្សាយក្នុងគំរោង APIP, ស្រុកគោលដៅទាំង ១៤
IFAD Loan N0. 423-KH នៅឆ្នាំ 2006



#74, Monivong Blvd.
Phnom Penh
CAMBODIA
Phone : (855)-12 812073
Fax : (855)-23 426112

# សេចក្ដីថ្លែងអំណរគុណ

ការិយាល័យបសុព្យាបាល សូមថ្លែងអំណរគុណ ចំពោះការជួយសហការក្នុងការបង្កើតឱ្យបានសំរេចនូវសៀវភៅគំរូបណ្ដុះបណ្ដាលភ្នាក់ងារសុខភាពសត្វភូមិ ដោយមានការចូលរួមពីបុគ្គលិកនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ដែលមានពាក់ព័ន្ធក្នុងគំរោង APIP និង ទីប្រឹក្សាបច្ចេកទេសមួយចំនួនដូចតទៅ :

លោក សេន សុវណ្ណ ប្រធានសំរបសំរួលថ្នាក់ជាតិ

លោក លឹម ចាន់ធី ប្រធានសំរបសំរួលអនុផ្នែក ផលិតកម្មសត្វ

លោក ហ៊ុយ វេង ទទួលបន្ទុកតាមដាន និង វាយតំលៃ

លោក ផាន់ ចាន់ធុល ទទួលបន្ទុករដ្ឋបាល-គណនេយ្យ និង ហិរញ្ញវត្ថុ

បណ្ឌិត អេលីយ៉ុត ផតទ័រ (Dr. Elliot Potter) ទីប្រឹក្សាបច្ចេកទេស ក្នុងគំរោង APIP

បណ្ឌិត ម៉ារី ម៉ាកគ្លីន (Dr. Murray Maclean) ទីប្រឹក្សាផ្នែកចិញ្ចឹមសត្វ

ការិយាល័យបសុព្យាបាល សូមថ្លែងអំណរគុណផងដែរ ចំពោះការជួយឧបត្ថម្ភគាំទ្រពី លោក ថុច មេងឃាង អនុប្រធានអង្គភាពគ្រប់គ្រងគំរោង លោកញិប ច័ន្ទថេត ប្រធាននាយកដ្ឋាន ផែនការ និង ហិរញ្ញវត្ថុ លោក ថោង ស៊ីផន ប្រធានផ្នែកលទ្ធកម្មនៃអង្គភាពគ្រប់គ្រងគំរោង និង លោក ចែ សារុន ប្រធានផ្នែកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ នៃអង្គភាពគ្រប់គ្រងគំរោង ។

ជាពិសេស សូមអរគុណចំពោះឯកឧត្ដម ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ជាប្រធានអង្គភាពគ្រប់គ្រងគំរោង និង ឯកឧត្ដម មាស គីមសុវ៉ារ៉ូ អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ជាប្រធានសំរបសំរួលប្រតិបត្តិគំរោង នៃអង្គភាពគាំទ្រគំរោង ។

លោក ណោប់ សុខ ហ៊ីម ប្រធានការិយាល័យបសុព្យាបាល
លោក ម៉ៅ ដារ៉ុធ អនុប្រធានការិយាល័យបសុព្យាបាល
អ្នកសំរបសំរួល អនុផ្នែកបសុព្យាបាល នៃគំរោង APIP

# Acknowledgement

The Animal Health Office would like to acknowledge the assistance in developing the standardized approach to VAHW training, of which this manual is an important part, from the staff of the Department of Animal Health and Production involved in the APIP Project, and from technical Advisors, as follow:

Mr. Sen Sovann, National Project Coordinator
Mr. Lim Chanthy, Animal Production Promotion Coordinator
Mr. Huy Veng, in charge of Monitoring and Evaluation
Mr. Phan Chanthol, in charge of Administrative Accounting and Planning
Dr. Elliott Potter, Senior Technical Advisor, APIP
Dr. Murray Maclean, Livestock Consultant

The Animal Health Officer would also like to acknowledge the support and assistance received from Mr. Thoch Meng Kheang, Vice-Chairman of PMU, Mr. Nhep Chan Thet, Director of Finance and Planning, Mr. Thoong siphan, Procurement Officer of PMU, and Mr. Chey Savun, Finacial Officer of PMU.

Special thanks to H.E. Chan Tong Yves, Secretary of MAFF and Chairman of PMU, and H.E. Meas Kim Suwaro, Under-Secretary of State of MAFF, Executive Project Coordinator of PMU.

Nap Sok Him and Mao Davuth
Chief Animal Health Office
Animal Health Coordinator, APIP

# សៀវភៅបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ

**អារម្ភកថា**

សៀវភៅបណ្តុះបណ្តាលនេះ បានរៀបចំឡើងដោយលោក ម៉ារី ម៉ាកគ្លីន (Mr. Murray Maclean) និង លោក ម៉ាល់កុល រ៉ាំងស៊ី (Mr. Malcolm Ramsay) ក្រោមការឧបត្ថម្ភពីបណ្តាអង្គការនានា ដូចជា : UNDP/OPS CARERE, Ausaid ( កម្មវិធីផ្សព្វផ្សាយកសិកម្ម កម្ពុជា អូស្ត្រាលី) និង ការិយាល័យសេវាកម្មក្រៅប្រទេស (Oversee Service Bureau) ក្នុងកំឡុងឆ្នាំ ១៩៩៥ ដល់ ១៩៩៧ ។ ច្បាប់ដើមជាភាសាខ្មែរ ត្រូវបានធ្វើឡើងដោយមានការជួយសហការពីលោក តូច ពលពន្លក ។

អ្នកនិពន្ធសូមថ្លែងអំណរគុណ ដល់ការជួយសហការ និង ប្រឹក្សា របស់លោក គ្រីស បាថែល (Mr. Chris Bartels) នៃអង្គការ CWS នៅក្នុងដំណាក់កាលនៃការ រៀបចំដំបូង ។

ផ្នែកពិសេសៗមួយចំនួនដូចជា : កាយវិភាគវិទ្យាសត្វ ការចិញ្ចឹមសត្វ និង បច្ចេកទេសគ្រៀវសត្វ ត្រូវបានបំពេញបន្ថែមទៅក្នុងសៀវភៅបណ្តុះបណ្តាលច្បាប់ដើមនេះ ហើយឯកសារទាំងនោះ បានមកពីអង្គការសកម្មភាពខាងជើង ខាងត្បូង និង ស៊ីដសេ សំរាប់ប្រើប្រាស់នៅក្នុងកម្មវិធី បណ្តុះបណ្តាលនៃគំរោង APIP ។

សៀវភៅនេះត្រូវបានអនុវត្តសាកល្បង ដ៏ទូលំទូលាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេស ខេត្តសៀមរាប និងខេត្តរតនគីរី ។ អ្នកនិពន្ធសូមថ្លែងអំណរគុណ ដល់មន្ត្រីនៃការិយាល័យផលិតកម្ម និង បសុព្យាបាល ដែលបានជួយសហការ ។ ការផលិតបញ្ចប់នៃសៀវភៅនេះ ត្រូវបានបង្កើតឡើងដោយបង្រួមបញ្ចូលគ្នា និង សំរេចយល់ព្រមពីផ្នែកផលិតកម្ម និង បសុព្យាបាល នៃគំរោង APIP ក្នុងខែមិថុនា ឆ្នាំ ២000 ដើម្បីរក្សាទុកជាសៀវភៅបណ្តុះបណ្តាលគំរូ ថ្នាក់ជាតិ សំរាប់ការបណ្តុះបណ្តាលដល់ភ្នាក់ងារសុខភាពសត្វភូមិ នៅព្រះរាជាណាចក្រកម្ពុជា ។

លោក សេន សុវណ្ណ

អនុប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល

និង ជាប្រធានសំរបសំរួលគំរោងថ្នាក់ជាតិ ក្នុងគំរោង APIP

# Village Animal health Worker Training Manual

## Preface

This Training Manual was originally designed by Mr. Murray Maclean and Mr. Malcolm Ramsay, under the sponsorship of a range of organisations including UNDP/OPS CARERE, Ausaid (Cambodia Australia Agriculture Extension Project), and the Oversea Service Bureau, over the period 1995-97. The original Khmer version was produced with the assistance of Toch Pol Ponlork.

The authors would like to acknowledge the assistance of Mr. Chris Bartels, of Church World Service, for his assistance and advice in the original design phase.

Specific sections on animal anatomy, and on animal raising and castration techniques, have been added to the original Training Manual, from material supplied by Action NorkSub and CIDSE, for use in the APIP Training Program.

The Manual has been extensively field tested in Cambodia, especially in Siem Reap and Ratanakiri provinces. The authors would like to acknowledge staff of the Offices of Animal Health Production for their assistance, The final product of this manual was produced, consolidated and adopted by the Animal Health and Production component of APIP in June 2000, as a National Standard Training Manual for VAHW Training in the Kingdom of Cambodia.

Sen Sovann
Deputy Director and
National Project coordinator, APIP

# មាតិកាអត្ថបទ


ល.រ ទំព័រ

១ - តើនរណាជាភ្នាក់ងារសុខភាពសត្វភូមិ ? ........ ២

២ - តើត្រូវធ្វើដូចម្តេច ដើម្បីឱ្យក្លាយទៅជាភ្នាក់ងារសុខភាពសត្វភូមិ ? ........ ៤

៣ - តើអ្នកនឹងបានរៀនអ្វីខ្លះ ក្នុងវគ្គបណ្តុះបណ្តាលនេះ ? ........ ៦


មេរៀនទី ១


៤ - ដំណើរការរបស់សត្វនៅពេលវាមានសុខភាពល្អ ........ ៩

៥ - អ្វីដែលសត្វត្រូវការឱ្យមានសុខភាពល្អ ........ ១១

៦ - សកម្មភាពការសិក្សាលើជ្រូករស់មួយក្បាល ........ ១២

៧ - កាយវិភាគវិទ្យារបស់សត្វ ........ ១៣

៨ - សរីរៈវិទ្យា ........ ២២

៩ - ការរំលាយអាហាររបស់សត្វជ្រូក ........ ២៥

១០ - ការរំលាយអាហាររបស់សត្វទំពារអៀង ........ ២៧

១១ - ការរំលាយអាហាររបស់បក្សី ........ ២៩

១២ - សកម្មភាពការពិនិត្យសរីរាង្គសត្វ ........ ៣៣

១៣ - សកម្មភាពការលេងល្បែងអំពីតួនាទីរបស់សរីរាង្គ និងដំណើររបស់ចំណី និងខ្យល់ចូលក្នុងខ្លួនសត្វ ........ ៣៤

១៤ - កំណត់ហេតុរបស់លោកគ្រូ អ្នកគ្រូ ស្តីពីល្បែងនេះ ........ ៣៥

១៥ - សំនួរ ........ ៣៩


មេរៀនទី ២


១៦ - តើអ្វីធ្វើឱ្យសត្វឈឺ ឬ ស្គម? និង តើអ្វីអាចជួយឱ្យសត្វអាចមានសុខភាពល្អឡើងវិញ ? ........ ៤១

១៧ - សត្វមិនសប្បាយចិត្ត ........ ៤២

១៨ - តើយើងអាចធ្វើអ្វីខ្លះ នៅពេលដែលសត្វឈឺ ឬស្គម ដោយសារតែវាមិនសប្បាយចិត្ត ........ ៤៤

១៩ - ចំណី និងទឹក មិនគ្រប់គ្រាន់ ឬចំណីមិនឆ្ងាញ់ និង ខ្វះជីវជាតិ ........ ៤៥

២០ - តើយើងអាចធ្វើអ្វីខ្លះនៅពេលដែលសត្វស៊ីចំណី និងទឹកមិនគ្រប់គ្រាន់ ឬចំណីមិនឆ្ងាញ់ និងខ្វះជីវជាតិ ៤៧

២១ - ពេលសត្វមានព្រូន អង្កែ ដង្កែ ឬ ចៃ ........ ៤៩

២២ - តើយើងអាចធ្វើអ្វីបានខ្លះ នៅពេលដែលសត្វឈឺ ឬស្គមដោយសារព្រូន ? ........ ៥២

២៣ - តើយើងអាចធ្វើអ្វីបានខ្លះ នៅពេលដែលសត្វ មាន អង្កែ ចៃ ដង្កែ ? ........ ៥៤

២៤ - ពេលដែលមេរោគធ្វើការលុកលុយខ្លួនសត្វ ........ ៥៥

២៥ - តើយើងអាចធ្វើអ្វីបានខ្លះ នៅពេលដែលសត្វឈឺដោយសារមានការវាយប្រហារពីមេរោគ ..... ៥៧
២៦ - នៅពេលសត្វពុល ..... ៥៨
២៧ - តើយើងអាចធ្វើអ្វីបានខ្លះ នៅពេលដែលសត្វឈឺ ឬ ស្គមដោយសារជាតិពុល ..... ៦០
២៨ - ពេលដែលសត្វមានរបួស ..... ៦០
២៩ - តើយើងអាចធ្វើអ្វីបានខ្លះ នៅពេលដែលសត្វមានរបួស ? ..... ៦១
៣០ - អ្វីដែលធ្វើឱ្យសត្វឈឺ ឬស្គម និងអ្វីដែលយើងអាចធ្វើឱ្យសត្វ ជា ឬធាត់ ? ..... ៦២

## មេរៀនទី ៣

៣១ - សកម្មភាពភ្នាក់ងារសុខភាពសត្វភូមិ នៅពេលទៅពិនិត្យសត្វឈឺ ..... ៦៣
៣២ - ពិនិត្យកន្លែងសត្វរស់នៅ ..... ៦៦
៣៣ - សាកសួរម្ចាស់សត្វ អំពីសត្វ និង បញ្ហារបស់វា ..... ៦៧
៣៤ - វាស់កំដៅសត្វ ..... ៦៩
៣៥ - ការពិនិត្យមើលរោគសញ្ញាដែលកើតមានលើខ្លួនសត្វ ..... ៧១
៣៦ - ការសង្ស័យលើមូលហេតុនៃជំងឺ ..... ៧២
៣៧ - ការជ្រើសរើសវិធីព្យាបាល ដើម្បីជួយឱ្យសត្វជាសះស្បើយ ..... ៧៣
៣៨ - សកម្មភាពលេងល្បែងព្យាបាលសត្វ ..... ៧៦

## មេរៀនទី ៤

៣៩ - ការចិញ្ចឹមសត្វឱ្យមានសុខភាពល្អ ..... ៧៨
៤០ - ការថែរក្សាឱ្យសត្វសប្បាយចិត្តជានិច្ច ..... ៧៩
៤១ - ការផ្តល់ចំណីអាហារឱ្យសត្វបានគ្រប់គ្រាន់ ..... ៨១
៤២ - ការការពារជំងឺដែលបង្កឡើងដោយព្រូន ..... ៨៤
៤៣ - ការការពារជំងឺដែលបង្កឡើងដោយមេរោគ ..... ៨៥
៤៤ - ការចិញ្ចឹមគោ ..... ៨៨
៤៥ - ការចិញ្ចឹមជ្រូក ..... ៩៦
៤៦ - ការចិញ្ចឹមមាន់ ..... ១០៦
៤៧ - របៀបប្រើប្រាស់វ៉ាក់សាំង និង ថ្នាំព្យាបាល ..... ១១៨
៤៨ - របៀបប្រើប្រាស់វ៉ាក់សាំង ..... ១២១
៤៩ - វ៉ាក់សាំងដែលប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ..... ១២២
៥០ - របៀបប្រើប្រាស់ថ្នាំព្យាបាល ..... ១២៣

៥១ - អាសុនតុល ............ ១២៥
៥២ - ស៊ុលហ្វា ៣៣ ............ ១២៨
៥៣ - ស៊ុលទ្រីហ្សិក ............ ១៣០
៥៤ - ស្ត្រិបតូមីស៊ីន ១ក្រាម ............ ១៣១
៥៥ - ក្លរតេត្រាសូន ............ ១៣២
៥៦ - អុកស៊ីតែត ............ ១៣៤
៥៧ - សិបតូទ្រីល (ចាក់) ............ ១៣៥
៥៨ - សូតាប៉ែន (ចាក់) ............ ១៣៦
៥៩ - ប៉េនីស៊ីលីនហ្សេ ១លាន ............ ១៣៧
៦០ - អុកស៊ីតូស៊ីន ............ ១៣៨
៦១ - ហ្វែកូបសង់ ១២ ............ ១៣៩
៦២ - ទីឡូ-ប៉េសេ ............ ១៤០
៦២ - អំពីជីចសាឡូន ............ ១៤១
៦៣ - កាល់ស្យូម $B_{12}$ ............ ១៤៣
៦៤ - បេ កំប្លិច អា. ដេ. អឺ ............ ១៤៦
៦៥ - សកម្មភាពចាក់វ៉ាក់សាំង គោ ក្របី ជ្រូក មាន់ ............ ១៤៧
៦៦ - សកម្មភាពលេងល្បែងអំពីការចិញ្ចឹមសត្វ ............ ១៤៨

## មេរៀនទី ៦

៦៧ - ជំងឺសំខាន់ៗ មួយចំនួនរបស់សត្វ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ............ ១៤៩
៦៨ - ជំងឺដែលបង្កឡើងដោយព្រូន ............ ១៥០
៦៩ - ជំងឺដែលបង្កឡើងដោយមេរោគ ............ ១៥១
៧០ - ជំងឺមួយចំនួនរបស់សត្វដែលបង្កឡើងដោយមេរោគ ............ ១៥២
៧១ - ជំងឺសារទឹក សត្វគោ ក្របី ............ ១៥៣
៧២ - ជំងឺបូសខ្យល់ ............ ១៥៥
៧៣ - ជំងឺឈាមខ្មៅ ............ ១៥៧
៧៤ - ជំងឺអុតក្តាម ............ ១៦០
៧៥ - ព្រូនមូលធំ កូនក្របី ............ ១៦៤
៧៦ - ព្រូនមូលផ្សេងទៀតរបស់គោក្របី ............ ១៦៦
៧៧ - ព្រូនសំប៉ែតរបស់គោ ក្របី ............ ១៦៩

៧៨ - ជំងឺប៉េស្តជ្រូក ........................................ ១៧១
៧៩ - ជំងឺកញ្ច្រិលជ្រូក ........................................ ១៧៣
៨០ - ជំងឺរាគរូសកូនជ្រូក ........................................ ១៧៥
៨១ - ជំងឺហើមសួត ........................................ ១៧៨
៨២ - ជំងឺតេតាណូស ........................................ ១៨០
៨៣ - ជំងឺពាសដោះមេជ្រូក ........................................ ១៨១
៨៤ - ជំងឺចុងអង្គុរជ្រូក និងមនុស្ស ........................................ ១៨៤
៨៥ - ព្រូនមូលរបស់ជ្រូក ........................................ ១៨៦
៨៦ - ជំងឺញាវកាស ........................................ ១៨៨
៨៧ - ជំងឺអាសន្នរោគបក្សី ........................................ ១៩១
៨៨ - ជំងឺសាល់ម៉ូណែឡូសបក្សី ........................................ ១៩៤
៨៩ - ជំងឺអុតបក្សី ........................................ ១៩៦
៩០ - ជំងឺកុកស៊ីឌីយ៉ូស៊ីសបក្សី ........................................ ១៩៨
៩១ - ជំងឺប៉េស្តទា ........................................ ២០០
៩២ - ជំងឺបណ្តាលពីព្រូន ........................................ ២០៣
៩៣ - ការក្រៀវគោ ក្របី ........................................ ២០៥
៩៤ - ការក្រៀវជ្រូក ........................................ ២១០
៩៥ - ជំងឺមួយចំនួននៃសត្វញីបន្តពូជ ........................................ ២១៩
៩៦ - ជំងឺឆ្កែឆ្កួត និង ជំងឺដែលបណ្តាលមកពីឆ្កែឆ្កួតខាំ ........................................ ២២៩

<u>មេរៀនទី ៧</u>

៩៧ - ពេលត្រលប់ទៅផ្ទះវិញ ........................................ ២៣១
៩៨ - ការងារបន្ថែមដែលអ្នកគួរធ្វើនៅពេលដែលអ្នកទៅព្យាបាលសត្វឈឺ ........................................ ២៣២
៩៩ - ល្បែងបង្ហាញអំពីពេលមេរោគចូលទៅក្នុងខ្លួនសត្វ ........................................ ២៣៧
១០០ - ល្បែងអំពីការចិញ្ចឹមសត្វ ........................................ ២៤៣
១០១ - ល្បែងអំពីការព្យាបាលសត្វ ........................................ ២៥៥
១០២ - ពិតមានស្តីពីជំងឺសត្វ ........................................ ២៨៣
១០៣ - កម្មវិធីបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ ........................................ ២៨៤
១០៤ - ជំងឺផ្តាសាយបក្សី ........................................ ២៨៨
១០៥ - គ្រូបង្ហាត់សិក្ខាកាមចិញ្ចឹមសត្វគោ ក្របី ........................................ ៣៣៣



# សេចក្តីផ្តើម

## តើនរណាជាភ្នាក់ងារសុខភាពសត្វភូមិ?

ភ្នាក់ងារសុខភាពសត្វភូមិគឺជាអ្នកជួយកសិករ ឬអ្នកភូមិ ដែលរស់នៅក្នុងភូមិរបស់គេអោយចិញ្ចឹមសត្វមានសុខភាពល្អ និង ឆាប់ធំធាត់ ។

នៅពេលដែលអ្នកក្លាយទៅជាភ្នាក់ងារសុខភាពសត្វភូមិ អ្នកនឹងមានសមត្ថភាពដូចខាងក្រោមនេះ :

- ចិញ្ចឹមសត្វអោយមានសុខភាពល្អ និងឆាប់ធំធាត់ និង ជួយបង្រៀនកសិករនៅក្នុងភូមិ អោយចេះចិញ្ចឹមសត្វដូចអ្នកដែរ ។
- ពិនិត្យសត្វឈឺ និង ចេះជ្រើសរើសយកការព្យាបាលត្រឹមត្រូវ និង មានប្រសិទ្ធភាព ។
- ការពារសត្វកុំអោយឈឺ ដោយចាក់ថ្នាំការពារ និង ប្រើវិធីផ្សេងៗទៀត ។
- ចេះប្រើសំភារៈបសុពេទ្យបានត្រឹមត្រូវ ។
- ចេះទិញ លក់ និងថែរក្សាថ្នាំបានត្រឹមត្រូវ ។
- រក្សាទុកកំនត់ហេតុការងាររបស់អ្នក ដែលនាំអោយអ្នកអាចបានយល់ដឹងថែមទៀតអំពីការងារ និង អាចបន្ត និង ពង្រីក ការងារអោយកាន់តែមានប្រសិទ្ធភាព ។

ពេលភ្នាក់ងារសុខភាពសត្វភូមិចាក់ថ្នាំការពារ ឬ ព្យាបាល និង ទំលាក់ព្រូនសត្វ ម្ចាស់សត្វត្រូវបង់ប្រាក់អោយភ្នាក់ងារសុខភាពសត្វភូមិ ។ ធ្វើដូចនេះដើម្បីអោយភ្នាក់ងារសុខភាពសត្វភូមិមានប្រាក់អាចទៅទិញថ្នាំ និង សំភារៈដើម្បីបន្តការងារនេះតទៅទៀត ។

ដូចនេះមានន័យថានៅពេលភ្នាក់ងារសុខភាពសត្វភូមិជួយអ្នកភូមិ ហើយអ្នកភូមិជួយភ្នាក់ងារសុខភាពសត្វភូមិអោយគេអាចបន្តការងាររបស់គេនៅក្នុងភូមិ ទាំងនេះនាំអោយសត្វទាំងអស់នៅក្នុងភូមិមានសុខភាពល្អដែលមានផលប្រយោជន៍ដ៏ល្អសំរាប់យើងគ្រប់ៗគ្នា ។

# តើនរណាជា ភ្នាក់ងារសុខភាពសត្វភូមិ?



# តើត្រូវធ្វើដូចម្ដេចដើម្បីអោយក្លាយទៅជាភ្នាក់ងារសុខភាពសត្វភូមិ?

ជាដំបូងអ្នកនឹងត្រូវទៅរៀននៅសាលាក្នុងឃុំរបស់អ្នក ដែលមានរយៈពេលប្រហែល ៤ អាទិត្យជាមួយគ្រូបង្រៀនរបស់អ្នក ដែលជាពេទ្យសត្វមកពីការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្តរបស់អ្នក ។
ក្រោយពីពេលរៀន និង ធ្វើលំហាត់អនុវត្តន៍ជាក់ស្ដែងចប់ អ្នកនឹងត្រូវបានផ្ដល់អោយនូវ សំភារៈ និង ថ្នាំមួយចំនួន ដែលអាចធានាអោយអ្នកអាចចាប់ផ្ដើមការងារជាភ្នាក់ងារសុខភាពសត្វភូមិនៅក្នុងភូមិរបស់អ្នកបាន ។

ពេលអ្នកជួយដល់កសិករនៅក្នុងភូមិអ្នក កសិករនឹងបង់ប្រាក់សំរាប់ការងាររបស់អ្នក ។ ប្រាក់នេះអ្នកអាចរក្សាទុកសំរាប់ទិញថ្នាំ និង សំភារៈផ្សេងៗនៅពេលដែលអ្នកត្រូវការ ។

នៅពេលដែលអ្នកធ្វើការ ៦ ខែដំបូងក្នុងភូមិរបស់អ្នក លោកគ្រូអ្នកនឹងទៅជួយត្រួតពិនិត្យមើលការងារអ្នករៀងរាល់អាទិត្យ និង ចូលរួមពិភាក្សាលើបញ្ហាដែលអ្នកមាន ដើម្បីអោយការងាររបស់អ្នកមានដំណើរការកាន់តែប្រសើរឡើង ។

រៀងរាល់ខែនៃឆ្នាំដំបូងអ្នកនឹងត្រូវចូលរួមប្រជុំជាមួយនិងគ្រូ និងជាមួយភ្នាក់ងារសុខភាពសត្វភូមិផ្សេងៗទៀតនៅក្នុងឃុំរបស់អ្នក ។ តាមរយៈការប្រជុំ អ្នកនឹងអាចបានប្ដូរនូវពត៌មានជាមួយអ្នកទាំងនោះ ហើយគ្រូអ្នកនឹងអាចជួយដោះស្រាយបញ្ហាដែលអ្នកមាន ។

ក្រោយពេលធ្វើការបានមួយឆ្នាំ អ្នកអាចជួបទាក់ទងជាមួយភ្នាក់ងារសុខភាពសត្វភូមិផ្សេងទៀត តាមការសំរេចចិត្តរបស់អ្នក ហើយគ្រូរបស់អ្នកនឹងមកចូលរួមបើសិនជាអ្នកអញ្ជើញគាត់មក ។

## តើត្រូវធ្វើដូចម្តេចដើម្បីអោយក្លាយជាភ្នាក់ងារសុខភាពសត្វភូមិ?



ការិយាល័យពេទ្យសត្វខេត្ត    ភូមិអ្នកស្រុក

រៀនក្នុងរយៈពេល ៤ ទៅ ៦ អាទិត្យ



លោកគ្រូទៅជួបនៅភូមិរាល់អាទិត្យ



លោកគ្រូ និងភ្នាក់ងារសុខភាពសត្វភូមិ

នៅក្នុងឃុំ ជួបប្រជុំគ្នារាល់ខែ





# តើអ្នកនឹងបានទៅរៀនអ្វីខ្លះក្នុងវគ្គបណ្តុះបណ្តាលនេះ?

ក្នុងវគ្គបណ្តុះបណ្តាលនេះ  អ្នកនឹងបានរៀនអំពីរបៀបជួយសត្វឈឺអោយជាមានសុខភាពល្អឡើងវិញ  ដោយប្រើថ្នាំព្យាបាល និង ដោយកត្តាផ្សេងៗ ទៀតដែលសត្វត្រូវការនៅពេលវាឈឺ ដូចជា ចំណី ទឹក ជំរក និង ការថែទាំសត្វជាដើម ។ ប៉ុន្តែនៅមានថ្នាំ និង កត្តាផ្សេងៗទៀតក្រៅពីប្រភេទថ្នាំដែលអ្នកបានកំពុងប្រើ ហើយដែលអ្នកអាចប្រើប្រាស់វាបានក្នុងការព្យាបាលសត្វអោយបានជាសះស្បើយពីជំងឺ ។ អ្នកនឹងបានរៀនផងដែរនូវមូលហេតុដែលបណ្តាលអោយសត្វឈឺ ដូច្នេះអ្នកអាចមានសមត្ថភាពក្នុងការជ្រើសរើសយកវិធីក្នុងការព្យាបាលប្រកបដោយប្រសិទ្ធភាព  ដែលធ្វើអោយសត្វឆាប់ជាសះស្បើយ ។

### នៅពេលដែលអ្នកយល់ដឹងអំពី:

- តើមានដំណើរការដូចម្តេចនៅពេលដែលសត្វមិនទាន់ឈឺ
- មូលហេតុអ្វីដែលបណ្តាលអោយសត្វឈឺ
- តើសត្វមានអាការៈ ឬរោគសញ្ញាដូចម្តេច? នៅពេលដែលសត្វឈឺដោយមូលហេតុផ្សេងៗពីគ្នា

### ពេលនោះអ្នកនឹងអាច  :

- ពិនិត្យសត្វឈឺ
- ធ្វើការសង្ស័យពីមូលហេតុដែលបណ្តាលអោយសត្វឈឺ
- ជ្រើសរើសនូវការព្យាបាលបានត្រឹមត្រូវដើម្បីអោយសត្វឆាប់បានជាសះស្បើយ

ការព្យាបាលសត្វ  មិនមែនជាការងាររបស់ភ្នាក់ងារសុខភាពសត្វភូមិម្នាក់ឯងនោះទេ  វាទាមទារអោយមានការជួយជ្រោមជ្រែងពីសំណាក់ម្ចាស់សត្វផងដែរ  ។ ភ្នាក់ងារសុខភាពសត្វភូមិអាចជ្រើសរើសយកថ្នាំព្យាបាលប្រកបដោយប្រសិទ្ធភាព រីឯកសិករត្រូវចេះរៀបចំ ចំណី ទឹកគ្រប់គ្រាន់ និង ជំរកព្រមទាំងការថែទាំអោយបានល្អ ។ ព្រោះកត្តាទាំងនេះមានសារៈសំខាន់ណាស់ គឺវាដូចជាថ្នាំដែលជួយព្យាបាលសត្វអោយជាសះស្បើយបានដែរ ។

នៅក្នុងវគ្គបណ្តុះបណ្តាលនេះ  អ្នកមិនត្រឹមតែបានរៀនអំពីវិធីព្យាបាលសត្វឈឺប៉ុណ្ណោះនោះទេ  អ្នកបានរៀនផងដែរ  អំពីកត្តាដែលធ្វើអោយសត្វមានសុខភាពល្អ  និង  មានសុខភាពកាន់តែប្រសើរ  និង  កាន់តែមាំមួនឡើងដែលអាចការពារខ្លួនមិនអោយឈឺបាន  ។  ចំពោះកសិករ  ការការពារសត្វមិនអោយឈឺគឺជាបញ្ហាចំបងដែលគេត្រូវធ្វើ ព្រោះការទិញថ្នាំមកព្យាបាល តែងតែមានតំលៃខ្ពស់ និង ការការពារជាទូទៅមានតំលៃថោកជាងជានិច្ច ។ម្យ៉ាងទៀត មានជំងឺខ្លះងាយស្រួលក្នុងការការពារតែមិនអាចព្យាបាលបានឡើយ ។

**ការពារប្រសើរជាងព្យាបាល  ពីព្រោះវាមានតំលៃថោក**
**និងអាចការពារសត្វមិនអោយស្លាប់បាន**

# ការព្យាបាល

## ការព្យាបាល មានប្រសិទ្ធិភាព



## ការព្យាបាល គ្មានប្រសិទ្ធិភាព



# ការការពារ

## ការការពារ មានប្រសិទ្ធិភាព



## ការការពារ គ្មានប្រសិទ្ធិភាព



# មេរៀនទី ១

## ដំណើរការរបស់សត្វនៅពេល
## វាមានសុខភាពល្អ



## 1.1 សេចក្តីផ្តើម

ក្នុងមេរៀននេះអ្នករៀនអំពីដំណើរការរបស់សត្វនៅពេលវាមានសុខភាពល្អ។

## 1.2 គោលបំណង

ក្រោយពីបញ្ចប់មេរៀន សិក្ខាកាមទាំងអស់នឹងអាចមានសមត្ថភាពដូចខាងក្រោមនេះ :

- ដាក់ឈ្មោះនូវកត្តា ៥យ៉ាងដែលសត្វត្រូវការដើម្បីរស់
- រៀបរាប់អំពីដំណើរការជាប្រក្រតីក្នុងខ្លួនសត្វ ដែលមានសុខភាពធម្មតា
- ដាក់ឈ្មោះនូវសរីរាង្គសំខាន់ៗ ទាំង១៤ របស់សត្វគោ ក្របី ជ្រូក មាន់
- រៀបរាប់អំពីថាតើសរីរាង្គនីមួយៗជួយដល់ជីវិតសត្វយ៉ាងដូចម្តេច?
- ដាក់ឈ្មោះសរីរាង្គខាងក្នុងរបស់ផ្ទាំងរូបសត្វជ្រូក ហើយគូសបំព្រួញអំពីកន្លែង ដើម្បីស្ទានទំងន់សត្វ និង ខ្យល់ចូល ទៅដល់ ។
- ពិនិត្យសត្វជ្រូករស់
- ចាប់ជ្រូកដោយប្រើប្រដាប់ចាប់ជ្រូកប្រើខ្សែម៉ែត្រ និងតារាងស្ទានទំងន់ដើម្បីស្ទានទំងន់សត្វ
- ប្រើទែម្ងម៉ែត្រដើម្បីវាស់កំដៅខ្លួនសត្វ

## 1.3 សំភារៈសំរាប់ការសិក្សា

ជ្រូកពាក្យាល ប្រដាប់ចាប់ជ្រូក ទែម្ងម៉ែត្រ ខ្សែម៉ែត្រ អ្នកសំលាប់ជ្រូក សំភារៈ និង ឧបករណ៍សំរាប់វះកាត់ជ្រូក ផ្ទាំងក្រដាស ប៊ិចឬខ្មៅដៃពណ៌ ។ បើសិនជាគ្រូ ឬសិស្ស ជាជនជាតិអ៊ិស្លាម យើងត្រូវយកគោឬមាន់ជំនួសវិញ ។

## 1.4 អត្ថបទ

# 1.4.1 អ្វីដែលសត្វត្រូវការអោយមានសុខភាពល្អ

១ សត្វត្រូវការកត្តា ៥ យ៉ាងអោយមានសុខភាពល្អ

- ចំណីអាហារ
- ទឹក
- ខ្យល់
- ការពារ ខាងក្នុងនិងខាងក្រៅ
- កំដៅខ្លួនត្រឹមត្រូវ

២ សំរាប់អោយសត្វមានកត្តា៥ យ៉ាងនេះវាត្រូវ

- ស៊ី
- ផឹក
- ដកដង្ហើម
- មានកូនកណ្ដុរនៅក្នុងខ្លួន និងស្បែកខាងក្រៅ
- ខួរក្បាល អោយត្រួតពិនិត្យកំដៅខ្លួន

៣ ពីខាងក្រៅយើងអាច

- មើលឃើញសត្វ
  - ស៊ី ចំណីអាហារ
  - ផឹកទឹក
  - ដកដង្ហើម ខ្យល់
  - លាមក ទឹកនោម
- មើលស្បែកវា ( ការពារខាងក្រៅ)
- វាស់កំដៅវា

៤ ពីខាងក្រៅយើងមិនអាចមើល

- ចំណីអាហារ ទឹក ខ្យល់ ទៅណានៅក្នុងខ្លួនសត្វ
- កូនកណ្ដុរ ( ការពារខាងក្រៅ)

# 1.4.2 សកម្មភាព

# ការសិក្សាលើជ្រូករស់មួយក្បាល



លោកគ្រូអ្នកនឹងនាំអ្នកទៅពិនិត្យមើលជ្រូករស់មួយក្បាល ។ តើអ្នកបានឃើញអ្វីខ្លះ? អ្នកអាចឃើញផ្នែកខាងក្រៅរបស់សត្វ ឃើញស្បែក និង អ្នកបានឃើញវាដើរស៊ីចំណី ជុះអាចម៍ និងនោម ។ តើមានអ្វីខ្លះទៀតដែលអ្នកអាចឃើញពីខាងក្រៅនៃខ្លួនសត្វ? នៅពេលដែលអ្នកមើលសត្វ អ្នកអាចសន្និដ្ឋានថាសត្វឈឺ ឬជាដោយការពិនិត្យមើលគ្រប់លក្ខណៈទាំងនេះ ។

លោកគ្រូបង្រៀននឹងបង្ហាញអ្នក អំពីរបៀបចាប់ជ្រូកដោយប្រើសំភារៈចាប់ជ្រូក និងរបៀបវាស់កំដៅជ្រូកដោយស៊កទែម្ងម៉ែត្រទៅក្នុងរន្ធគូទជ្រូក ។ តើកំដៅនៅខាងក្នុងខ្លួនជ្រូកមានប៉ុន្មានអង្សារ? ....................................

បន្ទាប់ពីនេះ លោកគ្រូនឹងបង្ហាញអំពីរបៀបវាស់ទំហំទ្រូងជ្រូក ក្នុងគោលបំណងធ្វើការប៉ាន់ស្មាន ទំងន់របស់វា ។ តើជ្រូកនេះមានទំងន់ ប៉ុន្មាន?..........................................................................................

# កាយវិភាគវិទ្យារបស់សត្វ
## Anatomy of animal

**កាយវិភាគវិទ្យា:** គឺជាវិទ្យាមួយដែលសិក្សាអំពីកាយ និង ទីតាំងសរីរាង្គក្នុងខ្លួនសត្វ ។ ខ្លួនប្រាណរបស់សត្វមានលក្ខណៈខុសប្លែកៗគ្នា ទៅតាមប្រភេទនីមួយៗ ឧទាហរណ៍ : គោ ក្របី សេះ ជ្រូក មាន់ ទា ។ល។ ដោយយោងទៅតាមការចាំបាច់សំរាប់ភ្នាក់ងារសុខភាពសត្វភូមិក្នុងការសិក្សាលើផ្នែកបច្ចេកទេសបសុព្យាបាល និង ការចិញ្ចឹមសត្វ ដូច្នេះហើយយើងបានលើកយកសត្វមួយចំនួន ដែលបានជួបប្រទះជាញឹកញាប់ មកសិក្សានូវលក្ខណៈខ្លះៗរបស់វា គឺមាន : គោ ក្របី ជ្រូក និង មាន់ ។

### ១_កាយវិភាគនៃសត្វគោ ក្របី ( Cattle Anatomy)

គោ-ក្របី ជាសត្វពាហនៈ ដែលប្រជាកសិករយើងប្រើប្រាស់ ក្នុងការប្រកបការងារកសិកម្ម ។ ចំពោះសត្វគោ ក្របី មានលក្ខណៈរួមគ្នាមួយ គឺជាសត្វស៊ីស្មៅ និង ជាសត្វទំពារអៀងដូចគ្នា ក៏ប៉ុន្តែរូបរាងកាយរបស់វាមិនដូចគ្នាទាំងស្រុងនោះឡើយ ដូច្នេះហើយយើងធ្វើការវិភាគរាងកាយរបស់សត្វនិមួយៗ ដូចតទៅ :

#### ក_ពិនិត្យផ្នែកខាងក្រៅ :

ផ្នែកខាងក្រៅខ្លួនសត្វគោទាំងមូល ដែលគ្របដណ្ដប់ដោយស្បែកក្រាស់ និង មានរោមទន់នៅលើស្បែក ។ ស្បែកការពារខ្លួនប្រាណរបស់វា និង ប្រឆាំងនឹងមេរោគបានមួយចំនួន ហើយអាចស៊ូទ្រាំនឹងកំដៅថ្ងៃបាន។

យើងបែងចែកខ្លួនជាបួនចំណែកសំខាន់ៗគឺ :

- ក្បាល
- ដងខ្លួន
- ជើងមុខ និង ជើងក្រោយ
- កន្ទុយ

**១_ក្បាលគោ :** នៅលើក្បាលគោមាន ស្នែង ភ្នែក ច្រមុះ មាត់ និងត្រចៀក ។ គេសង្កេតឃើញស្នែងរបស់គោឈ្មោលមានលក្ខណៈរឹងមាំ និង ធំហើយវែងជាងគោញី ។



**២-ដងខ្លួន :** ក្បាលគោតភ្ជាប់នឹងដងខ្លួនដោយសារក ដែលភ្ជាប់ទៅដោយឆ្អឹងកងក និង សសៃពួរធំៗ ។

ខ្លួនរបស់សត្វគោចែកចេញជា : ខ្នង ចង្កេះ ត្រគាក ប្រអប់ទ្រូង និង ប្រអប់ពោះ ។

-ខ្នង : ផ្សំឡើងដោយឆ្អឹងកងខ្នងជាច្រើនកង់

-ចង្កេះ : ផ្សំឡើងដោយឆ្អឹងកងចង្កេះ និងឆ្អឹងត្រគាក

-ប្រអប់ទ្រូង : ផ្សំឡើងដោយឆ្អឹងកងខ្នង និង ឆ្អឹងជំនីរ

-ប្រអប់ពោះ : ផ្សំឡើងដោយឆ្អឹងកងចង្កេះ និង សាច់ដុំស្បែកពោះ ។ ផ្នែកខាងក្រោមពោះមានកន្សោមដោះ ចំពោះ សត្វញី និង លិង្គ ចំពោះសត្វឈ្មោល ។

## ៣-ជើងមុខ និង ជើងក្រោយ

ជើងមុខ : ភ្ជាប់ខ្លួនដោយឆ្អឹងស្លាបប្រចៀវ ។ ជើងចែកចេញជា :

- ដើមដៃ (ជើងមុខ)
- កំភួនដៃ (ជើងមុខ)
- ប្រអប់ជើង

ជើងក្រោយ : ភ្ជាប់ខ្លួនដោយសារឆ្អឹងត្រគាក ។ ជើងក្រោយចែកចេញជា :

- ភ្លៅ
- កំភួនជើង
- ប្រអប់ជើង

**៤-កន្ទុយ :** កន្ទុយគោភ្ជាប់ទៅនឹងដងខ្លួនដោយសារឆ្អឹងកងត្រគាក ដែលភ្ជាប់នឹងឆ្អឹងកងខ្លួនតៗ គ្នារហូតដល់កន្ទុយ ។ កន្ទុយចែកចេញជា : ដើមកន្ទុយ កណ្តាល និង ចុងកន្ទុយ ។

កន្ទុយរបស់វាគឺសំរាប់ការពារសត្វល្អិតផ្សេងៗដែលរំខានដល់វា ។ ដើមកន្ទុយមានតួនាទីការពារមេរោគ និងធូលីផ្សេងៗមកប៉ះពាល់ទ្វារលាមក និង ប្រដាប់បន្តពូជចំពោះ (សត្វញី) ។ ចុងកន្ទុយមានដុះរោមវែងដូចសរសៃសក់ដែលវាប្រើសំរាប់បក់សត្វល្អិតមករំខានវា ។

☞ **ការពិនិត្យលើក្របី:**

ខ្លួនរបស់សត្វក្របីមានលក្ខណៈរួមច្រើនដូចសត្វគោដែរ តែក្នុងនោះក៏មានលក្ខណៈខុសប្លែកពីសត្វគោខ្លះដែរ ដូចជា :

-លើក្បាលរបស់វា : មានស្នែងធំសំប៉ែតហើយវែង

-លើខ្លួនរបស់វា : គ្របដណ្តប់ដោយស្បែកពណ៌ខ្មៅទន់ស្តើង និងរោមរឹង ប៉ុន្តែស្តើង ដែលបណ្តាលអោយសត្វក្របីពុំអាចទ្រាំនឹង កំដៅថ្ងៃបានយូរ ។

-ចំពោះជើងមុខ និង ជើងក្រោយ មានលក្ខណៈដូចសត្វគោដែរ ក៏ប៉ុន្តែជើងក្របីមានលក្ខណៈធំមាំជាងជើងគោ ។

-កន្ទុយក្របី : មានប្រវែងខ្លីជាងកន្ទុយគោ ។

## ខ.ពិនិត្យផ្នែកខាងក្នុងខ្លួននៃសត្វគោ ក្របី

-ផ្នែកក្បាលគោ ក្របី : ក្នុងប្រអប់ក្បាលផ្សំដោយឆ្អឹងលលាដ៏ក្បាល ហើយក្នុងលលាដ៏ក្បាលមានខួរក្បាល ។

-ក្នុងមាត់ : មានថ្គាមលើ និង ថ្គាមក្រោម មានធ្មេញ និង អណ្តាត (គោ ក្របី គ្មាន ធ្មេញលើទេ)

-ខ្នង : ក្នុងឆ្អឹងកងនៃដងខ្លួន មាន ខួរ សរសៃប្រសាទ និង សរសៃឈាម ។

-ក្នុងប្រអប់ទ្រូង : មានបំពង់អាហារ បំពង់ខ្យល់ សួត និង បេះដូង ។

-ប្រអប់ពោះ : មាន ក្រពះ ថ្លើម ប្រមាត់ ផាល តំរងនោម ប្លោកនោម ស្បូន អូវែ (សត្វញី) ប្រូស្តាត ចំពោះ សត្វឈ្មោល) ពោះវៀនតូច និង ពោះវៀនធំ ។

ចំពោះក្រពះសត្វគោ ក្របី (ដែលជាសត្វទំពារអៀង) ចែកចេញជាបួនទៀតគឺ : ពោះធំ ពោះចក ពោះស្រទាប់ ពោះរំអិល ។

✍ **កំណត់ហេតុ** ប្រអប់ទ្រូង និង ប្រអប់ពោះខ័ណ្ឌគ្នាដោយសារសន្ទះទ្រូង ។






**ក្រពះសត្វទំពារអៀង**

## ១. កាយវិភាគនៃសត្វជ្រូក (Pig Anatomy)

ជ្រូកជាសត្វមួយប្រភេទដែលប្រជាកសិករនិយមចិញ្ចឹម តាមលក្ខណៈគ្រួសារក្តី និង ជាឧស្សាហកម្មក្តី ។ ជ្រូកជាប្រភេទស៊ីចំណីខុសប្លែកពីគោ ក្របី ព្រោះការរំលាយអាហាររបស់វា គឺដោយសារក្រពះ។ ក្រពះជ្រូកមានតែមួយ ខុសប្លែកពីក្រពះសត្វទំពារអៀង ។

### ក. ពិនិត្យផ្នែកខាងក្រៅ :

ខ្លួនជ្រូកទាំងមូលគ្របដណ្តប់ដោយស្បែក និង រោមរឹងស្តើង ។ ក្រោមស្បែកមានកំរាស់ខ្លាញ់ ដែលបណ្តាលអោយជ្រូកមិនអាចរស់នៅហាលថ្ងៃបានយូរឡើយ ។ សត្វជ្រូកចែកចេញជា :

-ក្បាល

-ដងខ្លួន

-ជើងមុខ និង ជើងក្រោយ

-កន្ទុយ

**១. ក្បាល** : មានត្រចៀក ច្រមុះ មាត់ និង ភ្នែក។

**២. ដងខ្លួន** : ក្បាលភ្ជាប់ទៅនឹងដងខ្លួនដោយក ប៉ុន្តែកជ្រូកខ្លីពិបាកក្នុងការពិនិត្យ ព្រោះវាមានទ្រង់ទ្រាយស្ទើរស្មើនិងដងខ្លួន។ ដងខ្លួនជ្រូកចែកចេញជា : ខ្នង ចង្កេះ ត្រគាក ប្រអប់ទ្រូង និង ប្រអប់ពោះ។ ផ្នែកខាងក្រោមពោះមានដោះពីរជួរ និង មានលិង្គចំពោះសត្វឈ្មោល។

ខ្នង : ផ្សំឡើងដោយឆ្អឹងកងខ្នងជាច្រើនកង់

ចង្កេះ : ផ្សំឡើងដោយឆ្អឹងកងចង្កេះ

ត្រគាក : ផ្សំឡើងដោយឆ្អឹងកងចង្កេះ និង ឆ្អឹងត្រគាក

ប្រអប់ទ្រូង : ផ្សំឡើងដោយឆ្អឹងកងខ្នង និង ឆ្អឹងជំនីរ

ប្រអប់ពោះ : ផ្សំឡើងដោយឆ្អឹងកងចង្កេះ និង សាច់ដុំស្បែកពោះ

**៣. ជើងមុខនិងជើងក្រោយ** : មានលក្ខណៈស្រដៀងនិងជើងគោ ក្របី ប៉ុន្តែ ជើងជ្រូកវាតូចហើយទន់។

**៤. កន្ទុយ** : កន្ទុយជ្រូកខ្លី និងមានរោមវែងបន្តិចផ្នែកខាងចុង (ហើយមានលក្ខណៈដូចជាកន្ទុយគោក្របីដែរ។




* ចំពោះផ្នែកខាងក្នុងមានលក្ខណៈប្រហាក់ប្រហែលគ្នា ដូចបានរៀបរាប់នៅក្នុងមេរៀនកាយវិភាគនៃគោក្របីដែរ ។ ខុសប្លែកគ្នាត្រង់ថា ជ្រូកមានក្រពះមួយ មិនដូចសត្វទំពារអៀងទេ ។

## ១. កាយវិភាគបក្សី (Poultry Anatomy)



**ប្រព័ន្ធចលនា** : ប្រព័ន្ធចលនារបស់បក្សី ក៏ដូចជាប្រព័ន្ធចលនារបស់សត្វចិញ្ចឹមកូនដោយទឹកដោះដែរ មាន : ឆ្អឹងសន្លាក់ និង សាច់ដុំ ។

-ឆ្អឹង : ឆ្អឹងបក្សីស្រាលណាស់វាពេញទៅដោយខ្យល់ ។ ឆ្អឹងក្បាលមូលសំប៉ែត ចំពុះជាតិស្នែង ។

-ឆ្អឹង : ឆ្អឹងមាន១៤កំណាត់ ឆ្អឹងខ្នងមាន៧កំណាត់ ឆ្អឹងកន្ទុយមាន៧កំណាត់ហើយមានចលនារស់រវើក។ ឆ្អឹងទាំងនេះបន្តបន្ទាប់តម្រៀបគ្នាដោយសន្លាក់។

-ឆ្អឹងជំនីរ :ឆ្អឹងជំនីរមាន៧គូ គូទី២ ៣ ៤ និងទី៥ មានបន្តដោយឆ្អឹងមួយកំណាត់ទៀតដែលសំរាប់ ៣ង្រឹកទ្រូង ។



-ឆ្អឹងស្លាប : ឆ្អឹងស្លាបជាអវយវះលើ មានចលនាសំរាប់សំរាលខ្លួន ( ហើរ)

-ឆ្អឹងជើង : ឆ្អឹងជើងជាអវយវះក្រោមធ្វើចលនាផ្លាស់ប្តូរទីកន្លែងដោយសន្លាក់ ( ដើរ ឫរត់ ) ឆ្អឹងម្រាមជើង ៣ ហុចទៅមុខ ១ហុចទៅក្រោយ ចុងម្រាមមានក្រចកជាតិស្នែង ។

-ឆ្អឹងទ្រូង : ឆ្អឹងទ្រូងសំប៉ែត លូតលាស់ឆាប់រហ័សដែលតភ្ជាប់សាច់ដុំស្លាបដោយឆ្អឹងគាន់មួយកំណាត់។

-ឆ្អឹងត្រគាក : ឆ្អឹងត្រគាករាងខូងទ្រវែង ទូលាយផ្នែកខាងក្រោយសំរាប់ជាផ្លូវបញ្ចេញស៊ុត ។

-សាច់ដុំ : បក្សីមានសាច់ដុំពីរប្រភេទ សាច់ដុំពួរ ជាសាច់ដុំនៅបណ្តោយតាមឆ្អឹងជើង សាច់ដុំបន្ទះ គឺជា សាច់ដុំទ្រូង មានចលនាសំរាប់ផ្តល់កម្លាំងហើរ ហើយលូតលាស់ឆាប់រហ័ស។




**ប្រព័ន្ធរំលាយអាហារ :** ប្រព័ន្ធរំលាយអាហារមាន ចំពុះ បំពង់អាហារ គេ ទងកោះ កោះ ពោះវៀន ក្លូអាក់ និង មានរួមផ្សំដោយ ថ្លើម លំពែង ។




**ប្រព័ន្ធដកដង្ហើម :** បក្សីដកដង្ហើមខុសពីសត្វដ៏ទៃ កាលណាវាដកដង្ហើម ទ្រូងមិនកំរើកទេ (មិនរីកមិនយឺត) មាន : ច្រមុះ បំពង់ខ្យល់ ទងសួត សួត ។




**ប្រព័ន្ធចំរាញ់ទឹកមូត្រ :** មានៈ ក្រលៀន បំពង់នោម គ្មានប្លោកនោមទេ ក្រលៀនស្ថិតនៅជ្រៅក្នុងឆ្អឹងផាល ក្រលៀនម្ខាងមាន៣ក្លែប ក្លែបនីមួយៗមានបំពង់តូចដែលមករួមគ្នាកើតជាបំពង់ទឹកនោម។ បំពង់ទឹកនោមទាំងនោះ ឆ្មារស្តើង ពណ៌ស្រអាប់ ដែលនាំទឹកនោមទៅក្លូអាក់ ហើយលាយជាមួយលាមក ទឹកនោមបក្សីស "ខាប់" ឬ ពាក់កណ្តាលរាវ វាប្រែទៅជារឹង ឬខាប់នៅពេលត្រូវខ្យល់មានសភាពដូចកំបោរ។

**ប្រព័ន្ធបន្តពូជ :**

**-បក្សីឈ្មោល :** មានពងពីរនៅក្នុងប្រហោងពោះ ក្រោមក្លែបក្រលៀនទីមួយ ទឹកកាមបានមកពីពង ទាំង២ ហើយ ហូរតាមបំពង់បង្ហូរភ្ជាប់មកក្លូអាក់ ។

**-បក្សីញី :** មានអូវែ (ដំបែរ) តែមួយនៅខាងឆ្វេងក្រោមពោះ ជាចង្កោមដំបែរមានរាងជាគ្រាប់មូលតូចធំជាច្រើន ពណ៌លឿងហៅថា វីតេលុស (Vitellus) កាលណាវីតេលុសណាមួយទុំវារបេះចេញពីចង្កោម ហើយធ្លាក់ចូលក្នុងបំពង់បង្ហូរ ។ បំពង់បង្ហូរជាផ្លូវមានចលនាលូតលាស់ ហើយឃឹតរីករហ័សដែលនាំវីតេលុសទៅក្នុងក្លូអាក់ ហើយបង្កើតបន្តបន្ទាប់នូវជាតិពងស និង សំបក "ពងស" ។




-ស៊ុត ៖ មាន់ញីគ្មានឈ្មោលជាន់ក៏វាពងដែរ ប៉ុន្តែវាមិនញាស់ទេ ព្រោះវាគ្មានពន្លកជីវិត (កំណើតកូន) ដូច្នេះ ពន្លក ជីវិតត្រូវផ្សំផ្គុំជាមួយទឹកកាមឈ្មោល និងវីតេលុសរបស់មេ ។ ស៊ុតមាន់ និង សំបកភ្នាស់ក្រៅ ភ្នាសក្នុងសំបក និង ក្នុងខ្យល់នៅផ្នែកខាងពងធំ ។ ពងលឿង និង ពងស មានភ្នាសស្តើងស្រោបជុំវិញ ។



# សរីរៈវិទ្យា
# *Physiology*

**សរីរៈវិទ្យា :** គឺជាវិជ្ជាដែលសិក្សាពីចលនា ឬសកម្មភាពនៃប្រព័ន្ធសរីរៈនីមួយៗរបស់សត្វ និង បង្ហាញពីមុខងារនីមួយៗនៃសរីរៈ និង ជាលិកា ។

យើងបានសិក្សាអំពីកាយវិភាគវិទ្យារួចមកហើយ ដូច្នេះយើងដឹងហើយថា សរីរាង្គនីមួយៗស្ថិតនៅផ្សេងៗគ្នាដែលមានទីតាំងច្បាស់លាស់ ។ ឥឡូវយើងសិក្សាបន្តទៅទៀត អំពីទំនាក់ទំនងពីសរីរាង្គមួយទៅសរីរាង្គមួយទៀតក្នុងខ្លួនសត្វ ។

## ដំណើរការ និង ទំនាក់ទំនងផ្សេងៗក្នុងខ្លួនសត្វ

ដំណើរការ និង ទំនាក់ទំនងសំខាន់ៗនៃសរីរាង្គក្នុងខ្លួនសត្វចែកចេញជា :

១. ប្រព័ន្ធសរសៃប្រសាទ

២. ប្រព័ន្ធនៃការដកដង្ហើម

៣. ប្រព័ន្ធនៃរបត់ឈាមរត់

៤. ប្រព័ន្ធនៃការរំលាយអាហារ

៥. ប្រព័ន្ធនៃការបន្តពូជ

## ១. ប្រព័ន្ធសរសៃប្រសាទ :

មូលដ្ឋានសំខាន់នៃប្រព័ន្ធសរសៃប្រសាទគឺខួរក្បាល ។ ខួរក្បាលបញ្ជូនពត៌មានទៅផ្នែកផ្សេងៗនៃដងខ្លួនសត្វតាមរយៈសរសៃប្រសាទ និង ខួរឆ្អឹងខ្នង ។ ផ្ទុយទៅវិញសរសៃប្រសាទដែលស្ថិតនៅតាមសរីរាង្គរបស់សារពាង្គកាយសត្វទាំងមូល បញ្ជូនពត៌មានពីផ្នែកខាងក្រៅ ទៅឱ្យខួរក្បាលតាមរយៈខួរឆ្អឹងខ្នង ដូច្នេះខួរមានតួនាទីសំខាន់ណាស់ ក្នុងការបញ្ជាទៅ សរីរាង្គផ្សេងៗ ឱ្យធ្វើចលនា <u>ឧទាហរណ៍:</u> បញ្ជាមាត់អោយទំពារអាហារ, បញ្ជាជើងអោយធ្វើចលនា, សត្វអាចដើរ, បញ្ជាដល់សត្វឱ្យ ដឹងរបស់រឹង, ក្តៅ, ត្រជាក់, និង បញ្ជាឱ្យសត្វដឹងនូវអ្វីដែលវាត្រូវការបំពេញក្នុងខ្លួនរបស់វា ។ល។

ខួរក្បាលមានសភាពទន់ណាស់ និង អាចងាយបែកបាក់បាន ដូច្នេះហើយទើបខួរក្បាលត្រូវបានផ្ទុកក្នុងប្រអប់ឆ្អឹងយ៉ាងមាំ ( លលាដ៍ក្បាល ) ដើម្បីការពារកុំឱ្យវាខូចខាត ។

ខួរឆ្អឹងខ្នងក៏មានសភាពដូចខួរក្បាលដែរ ដូច្នេះខួរឆ្អឹងខ្នងនេះក៏ត្រូវព័ទ្ធជុំវិញទៅដោយឆ្អឹងកងតូចៗ ជាច្រើនដែលភ្ជាប់គ្នាដោយជាលិកាមិនរឹងដូចឆ្អឹង ។ ទោះជាយ៉ាងណាក៏ខ្នងត្រូវតែអាចបត់បែនបាន នោះសត្វទើបអាចធ្វើចលនា ។




ខួរក្បាលមានសារៈសំខាន់ណាស់ បើសិនជាខួរក្បាលឈប់ធ្វើការ សត្វក៏អាចស្លាប់ភ្លាម ។

## ២. ប្រព័ន្ធដកដង្ហើម

សរីរាង្គទាំងឡាយត្រូវការអុកស៊ីហ្សែន ដើម្បីមានចលនា ដូច្នេះសួត ជាអ្នកបំបែកសមាសភាពខ្យល់ដើម្បីយកអុកស៊ីហ្សែនទៅអោយសរីរាង្គផ្សេងៗ តាមរយៈឈាម ។

ជាដំបូងខ្យល់ចូលទៅក្នុងសួតតាមរយៈរន្ធច្រមុះ ឆ្លងកាត់បំពង់ខ្យល់ ហើយខ្យល់ចូលទៅក្នុងសួតតាមរយៈទងសួត និង កូនថង់សួត ។ សួតមានតួនាទីបំលែងសមាសភាពខ្យល់ ដោយស្រូបយកអុកស៊ីហ្សែនចូលក្នុងឈាម ទៅចែកចាយដល់សរីរាង្គផ្សេងៗ តាមរយៈសប់បញ្ជូននៃចលនាបេះដូង ។ រីឯក្នុងខ្យល់ដែលមានឧស្ម័នកាបូនិច សួតត្រូវបញ្ជូនចេញមកក្រៅវិញ ។

ដូច្នេះសួតជាសរីរាង្គមួយសំខាន់ណាស់ក្នុងខ្លួនសត្វ ប្រសិនបើសួតឈប់ធ្វើការ (មានន័យថាសត្វឈប់ដកដង្ហើម) សត្វអាចស្លាប់បានប្រហែល ២ ទៅ ៣នាទី ពីព្រោះនៅមានអុកស៊ីហ្សែនខ្លះក្នុងឈាម ។



## ៣, ប្រព័ន្ធរត់ឈាម :

បេះដូងគឺជាសរីរាង្គសំខាន់មួយ ក្នុងការបញ្ចេញឈាមដែលមានអុកស៊ីហ្សែន ទៅចិញ្ចឹមសរីរាង្គ និង ឧស្ម័នកាបូនិច ដែលសរីរាង្គមិនត្រូវការមកក្រោវិញ ។

បេះដូងចែកចេញជាពីរផ្នែក គឺផ្នែកខាងឆ្វេង និង ផ្នែកខាងស្តាំ ផ្នែកនីមួយចែកចេញជាពីរទៀត គឺថតលើ និង ថតក្រោម ខណ្ឌដោយសន្ទះមួយដែលហៅថា ប្រើស សំរាប់បិទ និង បើកតាមចលនាបេះដូង ។ ចលនានៃចង្វាក់បេះដូងចែកចេញជាពីរគឺ :

-ចលនាសង្កត់ : ក្នុងចលនានេះធ្វើអោយឈាមចេញពីបេះដូង

-ចលនាប៉ោង : គឺធ្វើអោយឈាមចូលទៅក្នុងបេះដូងវិញ

បេះដូងភាគខាងស្តាំទទួលឈាមខ្មៅមកពីសរីរាង្គ និង បេះដូងភាគខាងឆ្វេងទទួលឈាមក្រហមមកពីសួត ។

ការចែកចាយឈាម: សរសៃឈាមធំចែកជាសរសៃតូចពីរ :

សរសៃឈាមរបស់សួត ឬដំណើរឈាមរត់ "តូច" នាំឈាមខ្មៅទៅអោយសួត ហើយទទួលយកខ្យល់អុកស៊ីហ្សែន រួចបញ្ជូនទៅអោយបេះដូង ។

-ដំណើរឈាមរត់ "ធំ" គឺនាំឈាមក្រហមយកទៅចែកអោយគ្រប់សរីរាង្គ

-ក្នុងដំណើរឈាមរត់តូច សរសៃអាក់ទែផ្ទុកឈាមខ្មៅ សរសៃវ៉ែនផ្ទុកឈាមក្រហម ។

សរសៃឆ្មារ១ដែលនៅស្រទាប់លើសើរស្បែក ផ្ទុកឈាមដែលមានជាតិប្លាស្មា និង គោលិកាស ឆ្លងកាត់កោសិកានៃសរីរៈ ហៅថាជាលិកា ។

បេះដូងមានសារៈសំខាន់ណាស់ក្នុងការចិញ្ចឹមសរីរាង្គផ្សេង១ ព្រោះត្រូវការអុកស៊ីហ្សែន ដើម្បីទ្រទ្រង់កាយទាំងមូល ដូច្នេះបើសិនជាបេះដូងឈប់ធ្វើចលនា សត្វនឹងស្លាប់ភ្លាម ។

វត្ថុសំខាន់បំផុតសំរាប់សត្វ ក្នុងការរស់នៅមានជីវិតទៅបានគឺ ខួរក្បាល បេះដូង និង សួត ដូច្នេះកាយសត្វទាំងមូលត្រូវពឹងផ្អែកទៅលើកត្តាបីនេះ បើសិនជាសរីរាង្គណាមួយគ្មានដំណើរសត្វក៏ត្រូវបាត់បង់ជីវិតដែរ ។




**ប្រព័ន្ធ រត់ឈាម**




១. បេះដូង
២. អាអក
៣. វ៉ែនកាវមុខ
៤. វ៉ែនកាវក្រោយ
៥. អាក់ទែសួត
៦.. វ៉ែនសួត
៧. ថតលើឆ្វេង
៨. ថតលើស្តាំ
៩. ថតក្រោមឆ្វេង
១០. ថតក្រោមស្តាំ
១១. វ៉ាល់
១២. សួត
១៣. ចុង ( អវយវៈ ) មុខ
១៤. ចុង ( អវយវៈ ) ក្រោយ
១៥. តំរងនោម
១៦. ថ្លើម
១៧. បំពង់គ្រពះ និង ពោះវៀន

## ៤. ប្រព័ន្ធរំលាយអាហារ :

យើងបានសិក្សារួចមកហើយថា ដើម្បីអោយមានជីវិតរស់នៅ សត្វត្រូវការនាំយកខ្យល់អុកស៊ីហ្សែនចូលទៅក្នុងខ្លួនរបស់វាតាមរយៈប្រព័ន្ធដកដង្ហើម មិនតែប៉ុណ្ណោះ សត្វក៏ត្រូវការដែរនូវចំណីអាហារ និង ទឹកដែលត្រូវនាំចូលតាមមាត់ ទៅក្នុងប្រព័ន្ធរំលាយអាហារ ហើយត្រូវការបញ្ចេញចោលនូវកាកសំណល់នៃអាហារខ្លះ ដែលកាយសត្វ មិនត្រូវការ ។

ដើម្បីចិញ្ចឹមកាយបាន សរីរាង្គនីមួយៗ ត្រូវបំពេញមុខងារផ្សេងៗ ដើម្បីយកសារធាតុទាំងនោះទៅបំពេញតាមតំរូវការនៃសរីរាង្គទាំងអស់ ។

**ផ្លូវរំលាយអាហារមាន:** មាត់ បំពង់អាហារ ក្រពះ ពោះវៀនតូច ពោះវៀនធំ ហើយបញ្ចេញកាកសំណល់មកក្រៅតាមទ្វារលាមក ។

សរីរាង្គនីមួយៗ បានបំពេញតួនាទីផ្សេងៗ ក្នុងនោះទំនាក់ទំនងនៃការរំលាយអាហារ វាអាស្រ័យទៅតាមប្រភេទសត្វក្នុងការរំលាយអាហារ គេសង្កេតឃើញមានលក្ខណៈខុសគ្នា ដូចជា :

-ការរំលាយអាហាររបស់សត្វជ្រូក

-ការរំលាយអាហាររបស់សត្វទំពារអៀង ( គោ ក្របី)

-ការរំលាយអាហាររបស់បក្សី ( មាន់)

## I. ការរំលាយអាហាររបស់សត្វជ្រូក

ការរំលាយអាហាររបស់សត្វជ្រូក គឺស្ថិតនៅជំពូកសត្វដែលមានក្រពះមួយ ព្រោះក្រពះមានរាងជាថង់មួយស្តើង និង មានភាពទន់ជ្រាយ ។ ដូច្នេះសត្វជ្រូកត្រូវការអាហារដែលមានសភាពទន់ម៉ដ្ឋ ហើយនិងរហ័សរលាយ ដើម្បីឱ្យក្រពះមានសភាពជាប្រក្រតី ។

យើងដឹងហើយថា សរីរាង្គត្រូវការអុកស៊ីហ្សែន ដើម្បីអោយការដំណើរការ ទន្ទឹមនឹងនោះសរីរាង្គទាំងនេះ ក៏ត្រូវការចំណីអាហារ និង ទឹក ដែលនៅក្នុងនោះមានជាតិថាមពល, ជីវជាតិ, រ៉ែធាតុ ដូច្នេះដើម្បីស្រូបយកសារជាតិ ទាំងនេះ ប្រព័ន្ធរំលាយអាហារត្រូវបានបំពេញតួនាទីដូចខាងក្រោម :

មាត់មានតួនាទីចាប់យកចំណីអាហារឱ្យបានចូលដល់ក្នុងមាត់ ។ ពេលចំណីអាហារចូលដល់ក្នុងមាត់ហើយសត្វពុំអាចលេបទៅទាំងមូលបានទេ ដូច្នេះវាត្រូវការបំបែកចំណីអាហារទាំងនោះជាបំណែកតូចៗ ដោយសារធ្មេញ អណ្តាត និងរសទឹកមាត់ ។ អណ្តាតមានតួនាទីច្រើន ក្រៅពីជួយបង្វិលបំបែកអាហារ វាជួយធ្វើឱ្យសត្វដឹងនូវរសជាតិរបស់ អាហារ ហើយនិងបញ្ចេញនូវអ្វីដែលវាពុំចង់លេបចូល វានឹងខ្ទាក់បញ្ចេញមកក្រៅវិញ ។ ផ្ទុយទៅវិញ អ្វីដែលមានរសជាតិ ឆ្ងាញ់ និងជាសេចក្តីត្រូវការរបស់សរីរាង្គ អណ្តាតបានរុញច្រានចូលទៅក្នុងតាមរយៈបំពង់អាហារដល់ក្រពះ ។ ចំណីអាហារទាំងអស់ផ្ទុកនៅក្នុងក្រពះដែលធ្វើឱ្យក្រពះពេលនោះមានលក្ខណៈរីកធំដូចអាង សត្វហាក់ដូចជាពុំចង់ស៊ីច្រើន តទៅទៀត

ដែលយើងតែងថាសត្វឆ្អែតហើយ ។ ពេលនោះក្រពះបំពេញតួនាទីរបស់វា គឺវាចាប់ផ្ដើមធ្វើចលនាកិនបំបែក អាហារទាំងនោះឱ្យមានសភាពម៉ដ្ឋ ដោយសាររសក្រពះ រសប្រមាត់ និង លំពែងដើម្បីបញ្ជូនដល់ពោះវៀនតូច ។

ពោះវៀនតូចមានលក្ខណៈដូចទុយោវែងហើយទន់ ។ វាបំពេញតួនាទីជាអ្នកស្រូបយកសារធាតុទាំងឡាយដែលមាននៅក្នុងចំណីអាហារ តាមរយៈភ្នាសពោះវៀន ដែលពាសពេញទៅដោយសរសៃឈាមតូចៗ ។ សរសៃឈាមតូចទាំងនេះបានយកសារធាតុទាំងឡាយដែលភ្នាសពោះវៀនបញ្ជូនទៅដល់ថ្លើម ។ ថ្លើមជាសរីរាង្គរឹងហើយធ្ងន់ ។ ថ្លើមមានតួនាទីសំខាន់ណាស់ក្នុងការស្រូបយកសារធាតុទាំងឡាយដែលបានមកពីអាហារ ទៅចែកចាយដល់សរីរាង្គផ្សេងៗ នៃដងខ្លួនសត្វ ។ ថ្លើមក៏មានកាកសំណល់របស់វាដែរ ដូច្នេះកាកសំណល់ទាំងនេះ ថ្លើមបានបញ្ជូនចូលទៅក្នុងបំពង់តូចមួយដែលហៅថា "បំពង់ទឹកប្រមាត់" ដែលហូរចូលទៅក្នុងពោះវៀនតូចវិញ ។ រីឯកាកសំណល់ចំណីអាហារដែលកាយសត្វមិនត្រូវការ ក៏បញ្ជូនចេញមកក្រៅវិញតាមរយៈពោះវៀនធំ ។

ពោះវៀនធំមានតួនាទីជាអ្នកផ្ទុកនូវកាកសំណល់ដែលសល់ពីពោះវៀនតូច ហើយមានតួនាទីជាអ្នកស្រូបយកជាតិទឹកពីកាកសំណល់ចំណីអាហារ តាមរយៈសរសៃឈាមតូចៗដែរ ។ ពេលដែលស្រូបយកជាតិទឹករួចហើយ ពោះវៀនធំបានរុញច្រានកាកសំណល់ទាំងនេះចេញមកក្រៅតាមទ្វារធំ ។ កាកសំណល់ដែលចេញមកក្រៅនេះហៅថា លាមក ។

ក្រៅពីនេះមានសារធាតុខ្លះទៀតនៅក្នុងឈាមដែលសត្វមិនត្រូវការ ហើយសារធាតុទាំងនេះបែកចេញពីឈាម នៅពេលដែលឈាមហូរកាត់តំរងនោម ។ តម្រងនោមដើរតួនាទីជាអ្នកត្រងឈាមហូរចូលពីម្ខាង និង ចេញពីម្ខាងទៀតនៅពេលឈាមច្រោះស្អាតហើយវាបន្តត្រឡប់ចូលទៅក្នុងសារពាង្គកាយវិញ និង កាកសំណល់ដែលសល់ពីត្រងនោះហៅថា ទឹកនោម ។ ប្លោកនោមមានរាងដូចជាកូនថង់មួយ ព្រោះថាទឹកនោមត្រូវរក្សាទុកនៅក្នុងនោះ ។ នៅពេលដែលមានទឹកនោមចេញប្លោកនោមហើយ ពេលនោះប្លោកនោមកន្ត្រាក់ (គឺសត្វឈឺនោម) ដើម្បីបញ្ចេញទឹកនោមពី ប្លោកនោមតាមបំពង់ទឹកនោម ហើយបញ្ចេញមកក្រៅតាមយោនី (សត្វញី) ឬតាមលិង្គ (សត្វឈ្មោល) ។






| | | |
|---|---|---|
| ១. តំរងទឹកនោម | ៥. ក្រពេញទឹកនោម | ៩. សាច់ដុំទាញលិង្គ |
| ២. បំពង់តំរងនោម | ៦. ចុងពោះវៀន | ១០. ទ្វារលាមក |
| ៣. ពោះវៀនធំ | ៧. ប្រូស្តាត | ២២. ប្រដាប់បន្តពូជ |
| ៤. បំពង់ទឹកនោម | ៨. សាច់ដុំបញ្ចេញពីប្លោកនោម | ២៣. ប្លោកនោម |

## II. ការរំលាយអាហាររបស់សត្វទំពារអៀង

ក្រពះគោ ក្របី ស្ថិតនៅក្នុងពពួកក្រពះសត្វទំពារអៀង ។ ជាទូទៅក្រពះសត្វទំពារអៀងមានលក្ខណៈធំក្រាស់ ហើយចែកចេញជាបួនគឺ :

-ពោះធំ ឬ ពោះកន្ទ្រែង **(Rumen)**

-ពោះចក **(Reticulum)**

-ពោះស្រទាប់ **(Omasum)**

-ពោះរំអិល **(Abomasum)**

ជាដំបូងការរំលាយអាហាររបស់សត្វទំពារអៀងគឺមាត់ ដែលមានអណ្តាត និង ធ្មេញ ។ អណ្តាតបានប្រមូលបញ្ជូនស្មៅទៅក្នុងមាត់ និង ផ្តាច់ដោយធ្មេញក្រាស់របស់វា ។ នៅពេលដែលស្មៅចូលទៅក្នុងមាត់ ធ្មេញរបស់វាមិនបានទំពារអោយម៉ដ្ឋភ្លាមទេ គឺគ្រាន់តែធ្វើឱ្យស្មៅទន់ និង សើមដោយទឹកមាត់ រួចអណ្តាតបានបញ្ជូនស្មៅទៅក្នុងក្រពះធំតាមរយៈបំពង់អាហារ រីនៅក្នុងក្រពះធំមានមេរោគម្យ៉ាង (គឺមីក្រុបដែលអាចជួយអោយអាហាររលាយដោយបង្កើតជាតិហ្គាសនៅក្នុងពោះវៀនធំ ដែលអាចរុញច្រានស្មៅត្រឡប់មកមាត់វិញនៅពេលសំរាកម្តងៗ ។ ស្មៅចេញពីពោះវៀនធំត្រឡប់មកមាត់វិញ ដូច្នេះដើម្បីឱ្យមាត់បំពេញតួនាទីរបស់ខ្លួនជាលើកទី២ ពេលមាត់បានបញ្ចេញរសទឹកមាត់ និង ធ្មេញជាអ្នកទំពារបំបែកស្មៅអោយល្អិត ហើយបញ្ជូនទៅពោះចកតាមរយៈបំពង់អាហារដែរ ។ ម្តងនេះស្មៅដែលបានទំពារជាលើកទី២នេះ មិនចូលទៅក្នុងពោះវៀនធំវិញទេ គឺវាចូលទៅក្នុងពោះចក ហើយពោះចកក៏បំពេញតួនាទីក្នុងការបំបែកស្មៅ ដើម្បីបញ្ជូនទៅពោះស្រទាប់ជាបន្ត។

ពោះស្រទាប់មានតួនាទីកិនបំបែកបន្ថែម  ដើម្បីបញ្ជូនបន្តដល់ពោះវិអិលទៀត ។ យើងឃើញស្មៅដែលបានទទួលការកិ បំបែក ចាប់ពីពោះធំរហូតដល់ពោះវិអិល មានលក្ខណៈម៉ដ្ឋជាស្រេច  ព្រោះក្នុងពោះវិអិលមានលក្ខណៈដូចសត្វក្រពះមួយ ដែរ ។ រីឯកាកសំណល់ដែលសារពាង្គកាយមិនត្រូវការ  បានបញ្ចេញមកក្រៅហៅថា លាមក និង ទឹកនោម ។




## ប្រព័ន្ធរំលាយអាហារសត្វទំពារអៀង

☞ **កំណត់សំគាល់:**

មិនត្រូវផ្តល់ថ្នាំពពួកអង់ទីប៊ីយ៉ូទិក តាមមាត់ដល់សត្វទំពារអៀងនោះទេ ព្រោះពពួកថ្នាំនេះវាចូលទៅសំលាប់មីក្រុបដែលមានប្រយោជន៍នៅក្នុងក្រពះសត្វ ដែលធ្វើអោយសត្វបញ្ឈប់ការទំពារអៀង បណ្តាលអោយហើមពោះ និង បណ្តាលឱ្យសត្វស្លាប់បាន (បើសិនព្យាបាលមិនបានទាន់ពេលវេលា) ។

ចំពោះកូនគោ ក្របី នៅពេលកំពុងបៅដោះទឹកដោះដែលកូនគោបៅចូលតាមមាត់ ហើយ ធ្លាក់ចូលដល់ពោះចេក ពោះស្រទាប់ ពោះរំអិល តែម្តង ដោយមិនពិបាកឆ្លងកាត់ពោះធំឡើយ ។




## III. **ការរំលាយអាហាររបស់បក្សី**

ការរំលាយអាហាររបស់បក្សី មានលក្ខណៈខុសគ្នាចំពោះសត្វក្រពះមួយនិងសត្វទំពារអៀង ។ ប្រដាប់រំលាយ អាហាររបស់វាមាន: ចំពុះ បំពង់អាហារ គែ កោះ ពោះវៀនតូច ពោះវៀនធំ ដោយផ្សំរសថ្លើម រសប្រម៉ាត់ រសលំពែង ផងដែរ ទើបបញ្ចេញមកក្រៅតាមក្លូអាក់ ។

ចំពុះមានមុខងារ ចាប់យកចំណីអាហារប៉ុន្តែនៅក្នុងចំពុះ ឬមាត់ពុំមានធ្មេញសំរាប់ទំពារអាហារ នោះទេ ។ ហើយអណ្តាតបានបញ្ជូនចំណីអាហារចូលទៅក្នុងគែ តាមបំពង់អាហារ ។ គែមានលក្ខណៈជាថង់ស្តើងមួយដូចក្រពះដែរ តែវាពុំ មានតួនាទីកិនបំបែកចំណីអាហារនោះទេ វាគ្រាន់តែជាថង់មួយផ្ទុកចំណីអាហារតែប៉ុណ្ណោះ ។ ក្រោយពីបំពេញចំណីអាហារនៅក្នុងគែនោះពេញហើយ សត្វហាក់ដូចជាមិនចង់ស៊ីចំណីអាហារទៀតឡើយ ដែលយើងសន្មត់ថាវាឆ្អែតហើយ ។ ក្រោយពីបំពេញចំណីអាហារនៅក្នុងគែរួចហើយ គែក៏ចាប់ផ្តើមបញ្ជូនចំណីអាហារចូលទៅក្នុងកោះតាមរយៈទងកោះនិងក្រពះ ។ កោះមានតួនាទីកិនបំបែកចំណីអាហារអោយល្អិតដោយសាររសក្រពះ (ទងកោះ) ពេលណាកោះកិនបំបែកចំណីអាហារមិនបានសត្វបក្សីហាក់ដូចជាមានវិញ្ញាណដឹងបញ្ជាអោយលេបយកដុំគ្រួសឬថ្មល្អិតៗ ដើម្បីជួយរំលាយអាហារនៅក្នុងកោះ ។ ហេតុដូច្នេះ ហើយបានជាយើងនៅពេលវះកាត់កោះ យើងឃើញមានដុំគ្រួសថ្មល្អិតៗ នៅទីនោះ ។

ក្រោយពេលដែលកោះបំបែកចំណីល្អិតហើយ វាបានបញ្ជូនចូលមកពោះវៀនតូច ហើយធ្លាក់ចូលពោះវៀនធំ និង បញ្ចេញមកក្រៅតាមក្លូអាក់។

## ប្រព័ន្ធរំលាយអាហាររបស់បក្សី



ដូច្នេះសរីរាង្គនៃការរំលាយអាហារមានតួនាទីសំខាន់ណាស់ ក្នុងការទ្រទ្រង់រាងកាយសត្វអោយមានសុខភាពល្អ ។ បើសិនសរីរាង្គណាមួយក្នុងប្រព័ន្ធរំលាយអាហារ ត្រូវខូចមុខងាររបស់ខ្លួន វានឹងធ្វើឱ្យសត្វឈឺភ្លាម ។ ដូច្នេះយើងគួរផ្តល់ចំណី និងទឹកតាមតំរូវការរបស់សត្វ និងសមស្របទៅតាមប្រភេទនិងអាយុសត្វដែលត្រូវការ ។

## ✡ ប្រព័ន្ធនៃការបន្តពូជៈ

- ការបន្តពូជនៃសត្វចិញ្ចឹមកូនដោយទឹកដោះ និងសត្វបក្សី មានលក្ខណៈខុសគ្នាគឺ សត្វចិញ្ចឹមកូនដោយទឹកដោះ កើតមកមានរូបរាងជាកូនតែម្តង និងសត្វបក្សីកើតមកពីពង ហើយទើបក្រាបញាស់ចេញជាកូន ។




ការបន្តពូជនេះកើតឡើងដោយ ការផ្សំផ្គុំគ្នារវាងសត្វញី និងសត្វឈ្មោល បង្កើតជាកូនចៅបន្តជាជំនាន់ៗ ដើម្បីឱ្យមានកូនចៅទៅបាន គឺវាបង្កឡើងដោយសារទឹកកាមឬស្ពែម **(Sperm)** របស់សត្វឈ្មោលត្រូវជួបនិងអូវុលរបស់សត្វញី ។

សត្វញីបង្កើតអូវុលចេញពីអូវ៉ែ **(Ovary)** ក្នុងចន្លោះពេល ២១ថ្ងៃ ។ ដំណាក់កាលនេះសត្វញីចង់អោយសត្វឈ្មោលឡើងពាក់ ។ ស្ពែមគឺផលិតចេញពីពងស្វាសនៃសត្វឈ្មោល ដូច្នេះសត្វឈ្មោលបានបញ្ចេញស្ពែមទៅជួបនឹងអូវុលរបស់សត្វញី តាមរយៈការជួបគ្នា ( ពាក់គ្នា) បង្កើតបានជាកំណកូនហៅថាអំប្រីយ៉ុង ។

អំប្រីយ៉ុងលូតលាស់យ៉ាងយឺតៗនៅក្នុងស្បូនសត្វញី ហើយបន្ទាប់មកត្រូវបង្កើតចេញជាកូនសត្វតាមរយៈនៃការលូតលាស់របស់អំប្រីយ៉ុងខុសៗ គ្នា អាស្រ័យទៅនឹងប្រភេទសត្វនីមួយៗ :

ឧទាហរណ៍ :

-គោ ផើម មានរយៈពេល ៩ខែ ១០ថ្ងៃ

-ក្របី ផើម មានរយៈពេល ១០ខែ

-ជ្រូក ផើម មានរយៈពេល ៣ខែ ៣អាទិត្យ ៣ថ្ងៃ

ក្នុងរយៈពេលកំណត់នៃការផើមរបស់សត្វញី កូនសត្វដែលនៅក្នុងស្បូនបានចេញមកក្រៅដែលហៅថាការកើតកូន។

ក្រោយពីកើតរួច កូនសត្វបៅដោះរបស់មេវាដែលជាចំណីអាហារសំរាប់កូនសត្វលេបបានស្រួល និងមានសារធាតុ គឺមីហៅថា អង់ទីគ័រ ដែលអាចការពារកូនសត្វកុំអោយឈឺ ដូច្នេះជាការសំខាន់ណាស់យើងត្រូវជួយអោយកូនសត្វ ទទួលយកទឹកដោះដំបូង គឺឱ្យវាបៅក្នុងកំឡុងពេល ២៤ម៉ោងបន្ទាប់កើតមក ។ ព្រោះនេះជាពេលវេលាដែលមេរបស់វាផលិតនូវកូឡូសស្ត្រម (ទឹកដោះដំបូងដែលមានអង់ទីគ័រច្រើន សំរាប់ការពារកូនសត្វពីជំងឺផ្សេងៗ) ។ បើសិនជាកូនសត្វមិនបានបៅទឹកដោះដំបូងក្នុងកំឡុងពេល២៤ម៉ោងនោះទេ វានឹងងាយទទួលជំងឺ ហើយនិងពុំមានសុខភាពមាំមួនល្អ។



# 1.4.3 សកម្មភាព

# ការពិនិត្យ សរីរាង្គសត្វ



អ្នកដែលចេះសំលាប់ជ្រូកនឹងសំលាប់ជ្រូក បន្ទាប់មកលោកគ្រូ អ្នកគ្រូនឹងបង្ហាញអំពីរបៀបវះកាត់ជ្រូកដើម្បីអោយអ្នកបាន ឃើញសរីរាង្គទាំងឡាយដែលមាននៅក្នុងខ្លួនជ្រូក ។

គ្រូនឹងជួយបង្ហាញដល់អ្នកនូវសរីរាង្គផ្សេងៗ ។

តើសរីរាង្គណាមួយដែលឆ្ងាញ់ជាងគេ?................... ។

## 1.4.4 សកម្មភាពការលេងល្បែងអំពីតួនាទីរបស់សរីរាង្គ និងដំណើររបស់ចំណី ទឹក និងខ្យល់ចូលទៅក្នុងខ្លួនសត្វ



វាមានសារៈសំខាន់ណាស់នៅក្នុងការដឹងពីផ្នែកផ្សេងៗ របស់សត្វនិងតួនាទីរបស់វាក្នុងការជួយទ្រទ្រង់ជីវិតសត្វ ។ ដើម្បីសិក្សាពីតួនាទីរបស់សរីរាង្គនីមួយៗ យើងត្រូវលេងល្បែងមួយដែលក្នុងនោះយើងត្រូវប្រៀបប្រដូចថា បន្ទប់ដែលយើងកំពុងតែស្ថិតគឺជាខ្លួនសត្វ ហើយយើងទាំងអស់គ្នាគឺកំពុងតែស្ថិតនៅក្នុងខ្លួនសត្វ ព្រោះយើងទាំងអស់គ្នាគឺកំពុងតែស្ថិតនៅក្នុងបន្ទប់នេះ។ បន្ទាប់មកយើងសន្មត់ថា :

- ទ្វារមួយនេះគឺជាមាត់របស់សត្វដែលជាផ្លូវរបស់អាហារចូល
- បង្អួចនេះគឺជាច្រមុះរបស់សត្វដែលជាផ្លូវសំរាប់ដកដង្ហើម
- ទ្វារមួយនោះគឺជារន្ធគូទដែលជាផ្លូវសំរាប់បញ្ចេញលាមក មកខាងក្រៅ
- បង្អួចមួយនោះទៀតគឺជាផ្លូវសំរាប់បញ្ចេញទឹកនោម មកក្រៅ
- ជញ្ជាំងបន្ទប់គឺជាស្បែកសត្វ
- សិក្ខាកាមទាំងអស់គឺជាសរីរាង្គផ្សេងៗគ្នាដែលស្ថិតនៅក្នុងខ្លួនសត្វ

គ្រូរបស់អ្នកនឹងបង្រៀនរបៀបលេងល្បែងនេះ ហើយអ្នកនឹងឃើញថា :

- គ្រប់សរីរាង្គទាំងអស់ត្រូវការចំណីអាហារ
- គ្រប់សរីរាង្គទាំងអស់ត្រូវការទឹក
- គ្រប់សរីរាង្គទាំងអស់ត្រូវការខ្យល់
- គ្រប់សរីរាង្គទាំងអស់ត្រូវការ ការពារទាំងផ្នែកខាងក្នុងនិងខាងក្រៅ
- គ្រប់សរីរាង្គទាំងអស់នឹងត្រូវការស្ថិតនៅក្រោមកំដៅត្រឹមត្រូវ ។

## កំនត់ហេតុរបស់លោកគ្រូ អ្នកគ្រូ ស្តីពីល្បែងនេះ

គូររូបសត្វជ្រូក នឹងប្រព័ន្ធសរីរាង្គទាំងអស់លើក្តារខៀន។

សិក្ខាកាមទាំងអស់គួរតែត្រូវបានប្រាប់អោយដឹង ដូចខាងក្រោមនេះ :

(ពួកគេអាចពាក់មួកឺដាក់ផ្លាកសំគាល់ខ្លួនគេ)

- សិក្ខាកាមម្នាក់ដើរតួជា មាត់ ត្រូវឈរក្បែរទ្វារ ដែលបានសន្មត់ថាជាមាត់
- សិក្ខាកាមម្នាក់ដើរតួជា ក្រពះ
- សិក្ខាកាមម្នាក់ដើរតួជា ពោះវៀនតូច
- សិក្ខាកាមម្នាក់ដើរតួជា ពោះវៀនធំ ត្រូវឈរក្បែរទ្វារដែលជារន្ធគូទ
- សិក្ខាកាមម្នាក់ដើរតួជា ថ្លើម
- សិក្ខាកាមម្នាក់ដើរតួជា ច្រមុះ ត្រូវឈរក្បែរបង្អួចដែលជាច្រមុះ
- សិក្ខាកាមម្នាក់ដើរតួជា សួត
- សិក្ខាកាមម្នាក់ដើរតួជា បេះដូង
- សិក្ខាកាមម្នាក់ដើរតួជា ឈាម
- សិក្ខាកាមម្នាក់ដើរតួជា តំរងនោម
- សិក្ខាកាមម្នាក់ដើរតួជា ប្លោកនោម ត្រូវឈរក្បែរបង្អួចដែលជា លិង្គ
- សិក្ខាកាមម្នាក់ដើរតួជា កូនកណ្តុរ
- សិក្ខាកាមម្នាក់ដើរតួជា ខួរក្បាល

ត្រូវរៀបចំសិក្ខាកាមដែលនៅក្នុងថ្នាក់អោយដូចជាសរីរាង្គដែលត្រូវបានរៀបចំនៅក្នុងខ្លួនសត្វ។

ពេលនេះអ្វីដែលយើងចង់ឃើញនោះ គឺតើមានអ្វីកើតឡើងចំពោះចំណី ទឹក ខ្យល់ នៅពេលដែលយើងធ្វើចលនាចូលទៅក្នុងខ្លួនសត្វ ។

នៅពេលដែល ចំណី ទឹក ខ្យល់ចូលទៅក្នុងខ្លួនសត្វ

- សូមសរសេរ រឺ គូសអំពីដំណើររបស់ចំណី ទឹក និងខ្យល់ នៅលើផ្ទាំងក្រដាសធំ១៣សន្លឹកផ្សេងគ្នាដែលមានគូររូបដូចរូបភាពដែលបានគូរលើក្តារខៀន ។
- មួយសន្លឹកសំរាប់ចំណី មួយសន្លឹកសំរាប់ទឹក និងមួយសន្លឹកទៀតសំរាប់ខ្យល់ ។
- ប្រើខ្មៅដៃពណ៌បៃតងសំរាប់គូសដំណើរការរបស់ចំណី ខៀវសំរាប់ទឹកនិងខ្មៅដៃពណ៌លឿងសំរាប់ខ្យល់ ។
- ធ្វើដូចនេះគឺអោយអ្នកទាំងអស់គ្នាមើលឃើញតាមលំដាប់លំដោយនូវអ្វីដែលកើតមានឡើង ។

## ដំណើរការរបស់ចំណី



សិក្ខាកាមម្នាក់បានសន្មត់ថាជាមាត់ ទៅប្រមូលយកស្មៅមួយក្តាប់ពីខាងក្រៅបន្ទប់ ហើយបញ្ជូនស្មៅនេះទៅអោយក្រពះ និងក្រពះបញ្ជូនទៅអោយពោះវៀនតូច ។ ពោះវៀនតូចនឹងជ្រើសរើសផ្នែកល្អៗ នៃចំណីនេះ ហើយបញ្ជូនទៅអោយឈាម និងបញ្ជូនផ្នែកមិនល្អទៅអោយពោះវៀនធំ ដែលជាអ្នកបញ្ជូនស្មៅមិនល្អនេះចេញមកក្រៅតាមទ្វារដែលសន្មត់ថាជារន្ធគូទ ។ ឈាមត្រូវនាំសារធាតុចិញ្ចឹមទៅអោយគ្រប់សរីរាង្គ ពេលនោះសរីរាង្គនីមួយៗជ្រើសរើសយកចំណីណា ដែលគេត្រូវ ការ និងអោយទៅឈាមវិញនូវចំណីណាដែលមិនត្រូវការ ។

### ទាំងនេះគឺជាការបង្ហាញ អំពី របៀបទទួលចំណីអាហាររបស់សរីរាង្គទាំងអស់

## ដំណើរការរបស់ទឹក



សិក្ខាកាមម្នាក់ដែលសន្មត់ថាជា មាត់ត្រូវចាប់យកកែវទឹក ហើយបញ្ជូនទៅឱ្យក្រពះ ។ ក្រពះបញ្ជូនទឹកនេះមួយភាគធំ អោយឈាម និងមួយភាគទៀតទៅអោយ ពោះវៀនតូច ។ ឈាមទទួលទឹកនេះហើយធ្វើដំណើរជុំវិញខ្លួនសត្វ និងបញ្ជូនទឹកនេះទៅអោយគ្រប់សរីរាង្គផឹក ។ ប៉ុន្តែនៅសល់ទឹកចំនួនដែលគ្មានសរីរាង្គណាត្រូវការ ដូច្នេះឈាមនាំទឹកដែលនៅសល់នេះទៅអោយតំរងនោម និងបន្ទាប់មកតំរងនោមបញ្ជូនទៅអោយប្លោកនោម និងទីបញ្ចប់ប្លោកនោម នឹងបញ្ចេញទឹកនេះមកក្រៅតាមបង្ហួចដែលយើងសន្មត់ថាជាលិង្គ............ ។

### នេះគឺជាការបង្ហាញអំពី របៀបទទួលយកទឹករបស់សរីរាង្គទាំងអស់

ត្រូវតែធ្វើការវាយប្រហារជាមួយអ្នកដែលចូលមកឈ្លានពាន ឬរំលោភ ។

យើងនិងសិក្សាអំពីប៉ុស្តិ៍ការពារ ឬក៏អ្នកយាមនេះបន្ថែមទៀតនៅក្នុងមេរៀនខាងក្រោយគឺ នៅពេលដែលយើងនិយាយអំពី ថាតើមានអ្វីកើតឡើងចំពោះសត្វនៅពេលមានការរុករានដោយអ្វីដែលចង់ធ្វើអោយសត្វឈឺ ។

ដូចនេះបញ្ជាក់អោយឃើញថា គ្រប់សរីរាង្គទាំងអស់ត្រូវបានការពារទាំងខាងក្នុងនិងទាំងខាងក្រៅ ។

# កំដៅ

គ្រប់ចលនាទាំងអស់នៅក្នុងខ្លួនសត្វអាចធ្វើអោយផ្នែកខាងក្នុងនៃខ្លួនសត្វមានកំដៅខ្លាំង ។

នៅពេលដែលវាមានកំដៅខ្លាំង ពេកធ្វើអោយសរីរាង្គទាំងអស់មានដំណើរការមិនស្រួលនិងមិនអាចធ្វើការងារបានល្អ ។ ដូច្នេះនៅពេលដែលសរីរាង្គទាំងនោះ ចាប់ផ្តើមឡើងកំដៅវាប្រាប់ទៅខួរក្បាល ហើយខួរក្បាលបញ្ជាមកសួត អោយសួតបញ្ចេញខ្យល់ក្តៅមកក្រៅ និងបញ្ជាទៅ ស្បែកអោយស្បែកបញ្ចេញញើសដើម្បីធ្វើឱ្យខ្លួនសត្វចុះត្រជាក់វិញ ។ សត្វនឹងចាប់ផ្តើមរកទឹកផឹក និងរកកន្លែងត្រជាក់ដើម្បីដេក ។

បើសិនជាខ្លួនសត្វចុះត្រជាក់ខ្លាំងពេកក៏ធ្វើអោយសរីរាង្គទាំងអស់មានដំណើរការមិនស្រួលហើយក៏វាធ្វើការមិនបានល្អដែរ ។

**ដូច្នេះបញ្ជាក់អោយឃើញថាគ្រប់សរីរាង្គទាំងអស់**
**ត្រូវការស្ថិតនៅក្រោមកំដៅត្រឹមត្រូវ**

# ខ្យល់

សិក្ខាកាមដែលសន្មត់ថាជា ច្រមុះត្រូវចាប់យកស្បោងខ្យល់មួយ ហើយបញ្ជូនទៅអោយសួត ។ បន្ទាប់មកសួតត្រូវបញ្ជូនថង់ខ្យល់នេះទៅអោយឈាម ។ ពេលទទួលស្បោងខ្យល់នេះហើយឈាមធ្វើ ដំណើរជុំវិញខ្លួនសត្វហើយចែកចាយខ្យល់នេះអោយទៅសរីរាង្គផ្សេងទៀត ។ ប៉ុន្តែនៅមានខ្យល់មួយចំនួនដែលគ្មានសរីរាង្គណាត្រូវការ ។ ដូច្នេះឈាមត្រូវនាំយកខ្យល់ដែលនៅសល់នេះមកវិញហើយបញ្ជូនត្រឡប់ទៅឱ្យសួតវិញ ។ សួតក៏ត្រូវបញ្ចេញខ្យល់នេះ មកក្រៅវិញតាមរយៈច្រមុះ ។



**សកម្មភាពនេះគឺជាការបង្ហាញអំពី របៀបទទួលយកខ្យល់របស់សរីរាង្គ**

# ការការពារ

ស្បែកសត្វគឺហាក់បីដូចជាជញ្ជាំងបន្ទប់ គឺជាអ្នកការពារសត្វពីឥទ្ធិពលអាក្រក់នៃមជ្ឈដ្ឋានខាងក្រៅដែលអាចនាំអោយសត្វ ឈឺ ។ ចំណែកឯកូនកណ្តុរ គឺហាក់បីដូចជាប៉ុស្តិ៍ការពារ ឬក៏ជាអ្នកយាមការពារ ។ អ្នកយាមតែងតែឈរយ៉ាងស្ងៀមស្ងាត់និងជា ធម្មតាគេត្រួតពិនិត្យនូវរាល់អ្វីៗដែលចូលមកក្នុងខ្លួនសត្វ ដោយធានាថាអ្វីៗទាំងអស់ដែលចូលក្នុងខ្លួនសត្វមិនបង្ក គ្រោះថ្នាក់ ដល់សត្វឡើយ ។

## 1.4.5 លំហាត់

បន្ទាប់ពីបញ្ចប់នៃការលេងល្បែង អ្នកត្រូវបំពេញនូវរូបភាពដែលស្ថិតនៅទំព័រខាងក្រោយដូចជា :

- ដាក់ឈ្មោះឱ្យសរីរាង្គនីមួយៗ
- ប្រើខ្មៅដៃពណ៌បៃតងដើម្បីបង្ហាញពីទីកន្លែងដែលចំណីអាហារចូលទៅ
- ប្រើខ្មៅដៃពណ៌ខៀវដើម្បីបង្ហាញពីទីកន្លែងដែលទឹកចូលទៅ
- ប្រើខ្មៅដៃពណ៌លឿងដើម្បីបង្ហាញពីទីកន្លែងដែលខ្យល់ចូលទៅ
- ប្រើខ្មៅដៃពណ៌ក្រហមដើម្បីបង្ហាញពីប្រព័ន្ធការពារផ្នែកខាងក្រៅនិងផ្នែកខាងក្នុង

បន្ទាប់ពីការគូសបំពេញនូវរូបភាពនេះរួចហើយចូរឆ្លើយនូវសំណួរដែលមាននៅលើទំព័របន្ទាប់ ។

បើសិនជាអ្នកត្រូវការជំនួយ អ្នកអាចសួរគ្រូរបស់អ្នក ។

## 1.4.7 សំនួរ

១-តើមានអ្វីកើតឡើងចំពោះចំណីនៅពេលដែលវាចូលទៅក្នុងខ្លួនសត្វ ?

........................................................................................................................

........................................................................................................................

២- តើមានអ្វីកើតឡើងចំពោះទឹកនៅពេលដែលវាចូលទៅក្នុងខ្លួនសត្វ ?

........................................................................................................................

៣- តើមានអ្វីកើតឡើងចំពោះខ្យល់នៅពេលដែលវាចូលទៅក្នុងខ្លួនសត្វ ?

........................................................................................................................

៤-តើសត្វការពារខ្លួនវាពីការរុករានរបស់មេរោគ និងព្រូនយ៉ាងដូចម្ដេច?

........................................................................................................................

៥-តើសត្វរក្សាខ្លួនវាអោយស្ថិតក្រោមកំដៅដូចម្ដេច?

........................................................................................................................

ក្រោយពីបញ្ចប់ការលេងល្បែងនេះ គ្រូអ្នកនឹងនាំអ្នកឱ្យទៅពិនិត្យមើលជ្រូករស់មួយចំនួនទៀត ។

- តើជ្រូកទាំងនោះមានសុខភាពល្អ និងសប្បាយចិត្តដែរ ឬទេ? ..........................
- តើកំដៅក្នុងខ្លួនជ្រូកមានប៉ុន្មានអង្សា?..........................................................
- តើជ្រូកនេះមានទំងន់ប្រហែលប៉ុន្មានគីឡូ?.......................................................



# មេរៀនទី ២

## តើអ្វីដែលធ្វើអោយសត្វឈឺ ឬ ស្គម ?
## និង
## តើអ្វីដែលអាចជួយអោយសត្វមានសុខភាពល្អឡើងវិញ






## 2 .1 សេចក្ដីផ្ដើម

ក្នុងមេរៀននេះអ្នករៀនអំពី តើអ្វីដែលធ្វើសត្វឈឺឬស្គម និង តើអ្វីដែលអាចជួយសត្វមានសុភាពល្អឡើងវិញ ។

## 2 .2 គោលបំណង

ក្រោយពីបានបញ្ចប់ មេរៀនសិក្ខាកាមទាំងអស់នឹងអាចមានសមត្ថភាពដូចខាងក្រោមនេះ :

- កំណត់ឈ្មោះនូវមូលហេតុ៦យ៉ាងដែលធ្វើអោយសត្វឈឺ រឺ ស្គម
- សរសេរឧទាហរណ៍មួយចំនួនរបស់កត្តានីមួយៗ
- រៀបរាប់ពីអ្វីដែលយើងអាចធ្វើដើម្បីជួយសត្វឈឺ ឬ ស្គមបណ្ដាលមកពីកត្តា ៦យ៉ាងខាងលើ

## 2 .3 សំភារៈសំរាប់ការសិក្សា

ផ្ទាំងក្រដាស

## 2 .4 អត្ថបទ

### 2.4.1 សត្វមិនសប្បាយចិត្ត

នៅពេលដែលសត្វមិនសប្បាយចិត្តធ្វើអោយវា



- មិនឃ្លានចំណី វាស៊ីចំណីបានតិចហើយចុះស្គម ។
- ប្រព័ន្ធការពារនិងអ្នកយាម (កូនកណ្ដុរ) មិនសប្បាយចិត្តដែរ ពេលនោះពួកគេបញ្ឈប់ការ ការពារខ្លួនសត្វដែលផ្ដល់ ឱកាសដល់មេរោគនិងព្រូនក្នុងការធ្វើការរុករាននិងធ្វើអោយសត្វឈឺ ។



មានកត្តាច្រើនយ៉ាងដែលធ្វើអោយសត្វមិនសប្បាយចិត្ត

ឧទាហរណ៍

- កូនជ្រូកមិនសប្បាយចិត្តនៅពេលដែលវាត្រូវគេបំបែក ចេញពីមេវា ហើយដាក់វានិងគូទកង់ ឬម៉ូតូដឹកវាយកទៅលក់នៅទីឆ្ងាយ ។ (មានការលំបាកក្នុងការធ្វើដំណើរ ប្លែកកន្លែង និងការប្ដូរចំណី) ។



មេគោមិនសប្បាយចិត្តនៅពេលដែលគេដឹកវាយកទៅលក់នៅ កន្លែងឆ្ងាយដោយមិនបានអោយចំណីនិងទឹកផឹកតាមផ្លូវគ្រប់គ្រាន់ ។ (ពិបាកក្នុងការធ្វើដំណើរ) ។



- សត្វមិនសប្បាយចិត្តនៅពេលដែលគេបង្ខាំងវាជាមួយសត្វច្រើនទៀតនៅក្នុងកន្លែង ចង្អៀត ហើយក្រខ្វក់ ។



- សត្វនៅក្នុងភូមិមិនសប្បាយចិត្តនៅពេលដែលអាកាសធាតុក្តៅខ្លាំងហើយគ្មានម្លប់ជ្រក ឬក៏អាកាសធាតុប្រែប្រួល ទៅជាត្រជាក់ខ្លាំង ហើយនៅទីនោះគ្មានជំរកអោយសត្វជ្រក ។ (អាកាសធាតុមិនល្អ)



- សត្វក្របីមិនសប្បាយចិត្តនៅពេលដែលគេប្រើវាអោយភ្ជួរស្រែក្នុងរយៈពេល៣អាទិត្យដោយមិនអោយសំរាក ។ (ធ្វើការច្រើនពេក)

តើអ្នកអាចរកឃើញនូវកត្តាផ្សេងៗទៀតដែលអាចធ្វើអោយសត្វមិនសប្បាយចិត្តដែរឬទេ?

សូមសរសេរកត្តាទាំងនោះនៅទីនេះ

..........................................................................................................

..........................................................................................................

..........................................................................................................

# តើយើងអាចធ្វើអ្វីខ្លះនៅពេលដែលសត្វឈឺ ឬស្គម ពីព្រោះវាមិនសប្បាយចិត្ត?

ដើម្បីធ្វើឱ្យសត្វសប្បាយចិត្តឡើងវិញយើងត្រូវ :

- ចិញ្ចឹមសត្វក្នុងកន្លែងស្អាតនិងសមរម្យ
- ផ្តល់កន្លែងធំល្មមដល់សត្វ និងមិនដាក់ប្រជ្រៀតគ្នាជាមួយសត្វច្រើន
- ផ្តល់ជំរកត្រឹមត្រូវដែលអាចការពារនិងអាកាសធាតុមិនល្អបាន
- អោយសត្វសំរាកឱ្យបានគ្រប់គ្រាន់ និងងូតទឹកអោយសត្វផង

មិនត្រូវធ្វើការផ្លាស់ប្តូរចំណីលឿនពេក ត្រូវធ្វើដោយសន្សឹមៗ

## 2.4.2 ចំណី និងទឹកមិនគ្រប់គ្រាន់ ឬចំណីមិនឆ្ងាញ់ និងខ្វះជីវជាតិ



នៅពេលដែលសត្វមិនបានស៊ីចំណីនិងទឹកគ្រប់គ្រាន់ឬ ចំណីមិនឆ្ងាញ់និងខ្វះជីវជាតិ



- សរីរាង្គទាំងអស់នឹងត្រូវបាត់បង់ចំណីអាហារនិងទឹកដែលត្រូវការដើម្បីធ្វើការងាររបស់សរីរាង្គទាំងនោះ ។ សរីរាង្គទាំងអស់នឹងចុះខ្សោយហើយអស់កំលាំង ។
- សត្វនិងស្គម ឬ លូតលាស់យឺត ឬក៏ឈប់លូតលាស់តែម្តង ។
- ប្រព័ន្ធការពារ និងស្បែកត្រូវចុះខ្សោយក្នុងការការពារសត្វ នៅពេលដែលមានមេរោគចូលមកធ្វើការប្រយុទ្ធជាមួយនឹងវា ។ ដូច្នេះនៅពេលដែលសត្វមិនបានស៊ីចំណីគ្រប់គ្រាន់វា នឹងអាចឈឺយ៉ាងឆាប់រហ័ស ។

សត្វទាំងអស់ត្រូវការចំណីដែលមានគុណភាពល្អនិងគ្រប់គ្រាន់ ជាពិសេសចំពោះកូនសត្វនិងសត្វដែលកំពុងបំបៅកូន ។

*ឧទាហរណ៍ :*

- កូនសត្វត្រូវការចំណីអាហារ ដែលមានគុណភាពល្អនៅពេលដែលកូនសត្វដូចជាកូនជ្រូក កូនគោ មិនបានស៊ីនូវចំណីដែលមានគុណភាពល្អគ្រប់គ្រាន់វា
  - មិនអាចធំធាត់បានល្អ
  - មិនអាចធំដល់កំរិតដែលវា គួរតែអាច ធំដល់នោះ ឡើយ ។



នៅពេលដែល កូនសត្វមិនបានផឹកទឹកគ្រប់គ្រាន់ វានឹងស្លាប់យ៉ាងរហ័ស ។

- មេសត្វត្រូវការចំណីដែលមានគុណភាពល្អយ៉ាងច្រើន ។
  - នៅពេលមេសត្វដែលកំពុងបំបៅកូនមិនបានស៊ីចំណីមានគុណភាពល្អគ្រប់គ្រាន់
  - វានឹងចុះស្គមយ៉ាងរហ័ស ។ នេះដោយសារកូនបឺតយកជីវជាតិអស់យ៉ាងច្រើននៅពេលដែលវាបៅដោះមេវា ។



- នៅក្នុងទឹកដោះមានជាតិទឹកយ៉ាងច្រើន ដូច្នេះបើសិនជាមេសត្វមិនបានផឹកទឹកគ្រប់គ្រាន់
  - វានឹងផលិតទឹកដោះបានតិច ហើយជួនកាលវានិងបញ្ឈប់ផលិតទឹកដោះតែម្តង ។

- បើសិនជាគ្មានទឹកដោះគ្រប់គ្រាន់កូនគោកូនជ្រូកនឹងទទួលការឈឺចាប់ដោយសារការខ្វះទឹកនិងខ្វះចំណី ។

# តើយើងអាចធ្វើអ្វីខ្លះនៅពេលសត្វស៊ីចំណី និងទឹកមិនគ្រប់គ្រាន់ ឬចំណីមិនឆ្ងាញ់និងខ្វះជីវជាតិ



យើងអាច

- ផ្តល់បន្ថែមអោយសត្វមាន ចំណី និងទឹកគ្រប់គ្រាន់ ។

ឧទាហរណ៍

- ជ្រូកចិញ្ចឹមយកសាច់ត្រូវឱ្យវាស៊ីអោយបានឆ្អែត ។
- យើងត្រូវដាក់ទឹកស្អាតនៅក្បែរសត្វរាល់ពេល ។ ធ្វើដូចនេះសត្វអាចផឹកទឹកបានយ៉ាងច្រើន និងបានគ្រប់ពេល តាមតែចិត្តវាចង់ ។

- ផ្តល់ចំណីឆ្ងាញ់និងមានជីវជាតិ

ឧទាហរណ៍



- ពេលខ្លះគោ ក្របី មិនបានស៊ីស្លឹករុក្ខជាតិពណ៌បៃតង គ្រប់គ្រាន់ ។
- ពេលខ្លះគោ ក្របីត្រូវការអំបិលថែមទៀត ឬពេលខ្លះវាបែរជាបានទទួលអំបិលច្រើនពេក ។
- ពេលខ្លះចំបើងដែលយើងអោយគោ ក្របីស៊ីជាចំបើងចាស់ ដូច្នេះយើងត្រូវផ្អាប់ចំបើងនេះ ជាមួយជីអ៊ុយរ៉េដើម្បីអោយវាមានរស់ជាតិកាន់តែឆ្ងាញ់ជាងមុន ។
- ពេលខ្លះចំណីដែលអោយជ្រូកស៊ី សាបពេក រឺ ប្រៃពេកឬក៏អាចមកពីកន្ទក់ដែលយើងដាក់អោយជ្រូកស៊ីនោះមានអង្កាមច្រើនពេក ។
- ពេលខ្លះជ្រូកមិនបានស៊ីស្លឹករុក្ខជាតិគ្រប់គ្រាន់ ។
- បើសិនជាចំណីដែលសត្វស៊ីជារៀងរាល់ថ្ងៃនោះវាមិនឆ្ងាញ់ សត្វវានឹងមិនស៊ីអោយបានគ្រប់គ្រាន់
- ដើម្បីអោយសរីរាង្គវាធ្វើការបានល្អឡើង ។

* ប្រើប្រាស់ថ្នាំដើម្បីជួយអោយសត្វឃ្លាន ដែល ធ្វើអោយសត្វ អាចស៊ីចំណីបានច្រើនជាងមុន ។




Vitamin

* បើសិនជាសត្វរាគអាចម៍ យើងអាចលាយថ្នាំខ្លះៗ ជាមួយនិងទឹកអោយសត្វផឹកដែលអាចជួយដល់ ក្រពះក្នុងការបញ្ជូនជាតិទឹកទៅអោយឈាម ។




អូរ៉ាលីត

បើសិនជាសត្វវាមិនចង់ស៊ីចំណីនេះទេ ទោះបីចំណីនោះល្អ ឬ ឆ្ងាញ់យ៉ាងណាក៏ដោយ យើងគួរតែគិតអំពីកត្តាផ្សេងៗទៀតដែលធ្វើអោយសត្វមិនស៊ីចំណី ។



ឧទាហរណ៍

* សត្វនោះឈឺ (សត្វ គ្រុន សត្វមានព្រូន)



ដូច្នេះយើងអាចជ្រើសរើសយកការព្យាបាលបានត្រឹមត្រូវ ។

## 2.4.3 ពេលសត្វមានព្រូន អង្កែ ដង្កែ ឬ ចៃ

ព្រូន អង្កែ ដង្កែ និងចៃ អាចរស់បានដោយសារតែ ការជញ្ជក់បឺតយកឈាម ឬជីវជាតិពីសត្វដែលវានៅជាមួយ ។ ដូច្នេះសត្វនិងចាប់ផ្តើមចុះស្គមបន្តិចម្តងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ។



## ពេលសត្វមានព្រូន ៖



មានព្រូនច្រើនប្រភេទ

- ព្រូនខ្លះមានរាងមូល
- ព្រូនខ្លះមានរាងសំប៉ែត
- ព្រូនខ្លះមានរាងដូចជាស្លឹកឈើ



ព្រូនរស់នៅក្នុងសត្វ

- ព្រូនភាគច្រើនរស់នៅក្នុងក្រពះ ពោះវៀនតូច ពោះវៀនធំ ឬនៅក្នុងថ្លើម ។
- ព្រូនខ្លះរស់នៅក្នុងសួត នៅក្នុងសាច់ដុំ
- ជាពិសេសព្រូនរស់នៅក្នុងសត្វក្មេង រឺ សត្វកំពុងបំបៅដោះ ។



ពេលព្រូនរស់នៅក្នុងសត្វ

- ព្រូនស៊ី រឺ ជញ្ជក់នៅកន្លែងនោះបន្តិចម្តងៗ
- អ្នកយាមមិនអាចវាយប្រហារជាមួយព្រូន
- ខ្លួនមិនឡើងកំដៅ ឬ គ្រុនឡើយទេ
- បើសិនជាមានព្រូនច្រើននៅក្នុងខ្លួនសត្វ សរីរាង្គទាំងឡាយមិនអាចធ្វើការបានល្អ ដូច្នេះ សត្វអាចចាប់ផ្តើម
    - រាគរូស ទល់លាមក មិនឃ្លានចំណី ស្រកទំងន់ និងចុះស្គមបន្តិចម្តងៗ
    - ស្បែកវាឡើងស្ងួតហើយគ្រើម
    - រោមវាបះឡើង



ពេលព្រូនរស់នៅក្នុងខ្លួនសត្វ

- ព្រូនបន្តពូជបង្កើតជាពងព្រូន
- ពងព្រូនចេញពី ខ្លួនសត្វតាមលាមក



ពងព្រូនរស់នៅលើដី និងនៅលើស្មៅ

- ពេលសត្វស៊ីស្មៅ រឺ ដី

  ពងព្រូនចូលទៅក្នុងខ្លួនសត្វហើយបង្កើតព្រូន





# តើយើងអាចធ្វើអ្វីបានខ្លះនៅពេលដែលសត្វឈឺ ឬ ស្គមដោយសារព្រូន

**ពេលសត្វមានព្រូន ៖**

នៅពេលដែលសត្វឈឺ ឬស្គមដោយសារព្រូន យើងអាច

- ប្រើប្រាស់ថ្នាំសំលាប់ព្រូន
- ថ្នាំនេះវាខុស ពីថ្នាំសំលាប់មេរោគ
  ឬ ថ្នាំដែលបង្អង់សកម្មភាពមេរោគ ។

ឧទាហរណ៏

- ថ្នាំ **Ivomec**
- ថ្នាំ **Levamisole**
- ថ្នាំ **Mebendazole**
- ថ្នាំ **Fasinex**



បន្ទាប់ពីធ្វើការទំលាក់ព្រូនរួចហើយ ព្រូនថ្មីនឹង ចូលមកក្នុងខ្លួនសត្វទៀត ដូច្នេះនៅពេលអនាគតយើងត្រូវធ្វើការទំលាក់ព្រូនម្តងទៀត ។



បើសិនជាមេសត្វដែលកំពុងបំបៅកូន មានព្រូនច្រើននៅក្នុងខ្លួនវា

- ព្រូនចេញពីខ្លួនសត្វតាមទឹកដោះ





## ពេលសត្វមានអង្កែ ចៃ ដង្កែ :



អង្កែ ចៃ ដង្កែ វារកស៊ីនៅក្នុងស្បែកសត្វ ពេលខ្លះវា

- ធ្វើឱ្យស្បែកសត្វឡើងក្រហម ឬក៏
- ធ្វើអោយយើងអាចមើលឃើញកន្ទួល១នៅលើស្បែកសត្វ
- ជារឿយ១ ធ្វើអោយសត្វធុញ និងរមាស់ ហើយមិនចង់ស៊ីចំណី

អង្កែ ចៃ ដង្កែ ខ្លះខាំទំលុះស្បែកសត្វហើយបឺតឈាម ដែល

- ធ្វើអោយសត្វចុះខ្សោយ ស្រកទំងន់ព្រោះគ្មានឈាមគ្រប់គ្រាន់ក្នុងការដឹកនាំចំណើ ទឹក ខ្យល់ទៅអោយសរីរាង្គនៅក្នុងខ្លួនសត្វ ។

# តើយើងអាចធ្វើអ្វីបានខ្លះនៅពេលដែលសត្វមានអង្គែ ចៃ ដង្កែ

នៅពេលសត្វឈឺ ឬស្គមដោយសារ ចៃ ដង្កែ និង អង្គែ យើងអាច

- ប្រើប្រាស់ថ្នាំសំរាប់សំលាប់ពួកវា ឬក៏
- ចាប់ ឬបេះចៃ ដង្កែ នេះចេញពីខ្លួនសត្វម្តងមួយៗ ដោយដៃរបស់យើង ។
- ថ្នាំនេះវាខុសគ្នាពីថ្នាំដែលសំលាប់ មេរោគ រឺបង្អង់សកម្មភាពមេរោគ ។

ឧទាហរណ៍ :

- ថ្នាំ Ivomec អាចសំលាប់អង្គែ នឹងព្រូនផង
- ថ្នាំ Asuntol អាចសំលាប់អង្គែ ចៃ ដង្កែ
- ថ្នាំ Negasunt អាចសំលាប់អង្គែ ចៃ ដង្កែ



## 2.4.4 ពេលដែលមេរោគធ្វើការលុកលុយខ្លួនសត្វ



មេរោគគឺជាសត្វមានជីវិត

- ជីវិតតូចៗ ដែលយើងមិនអាចមើលឃើញនិងភ្នែកទទេបានឡើយ ។
- ដែលត្រូវការស៊ីចំណីនិងបង្កើតកូនចៅ ។



មេរោគខ្លះចូលចិត្តនៅក្នុងខ្លួនសត្វ ហើយរកស៊ីផ្នែកខ្លះៗនៃខ្លួនសត្វ ។

- ពួកវាហាក់ដូចជាចោរដែលចង់ចូលទៅក្នុងផ្ទះ ដើម្បីលួច និងបំផ្លាញវត្ថុមួយចំនួន ។



មេរោគចូលទៅក្នុងខ្លួនសត្វស៊ី ហើយរុករាន និងធ្វើការបំផ្លិចបំផ្លាញសរីរាង្គរបស់សត្វ និងធ្វើអោយសត្វឈឺ ឬស្លាប់ ។



មេរោគមានច្រើនប្រភេទហើយពួកវាចូលចិត្តរស់នៅគ្រប់កន្លែងទាំងអស់

- មេរោគខ្លះ ចូលចិត្តរស់នៅក្នុងដី
- មេរោគខ្លះ ចូលចិត្តរស់នៅក្នុងទឹក



មេរោគអាចចូលទៅក្នុងខ្លួនសត្វតាមរយៈ

- ចំណីអាហារ និងទឹកពេលសត្វស៊ីនិងផឹក
- តាមខ្យល់នៅពេលដែលសត្វដកដង្ហើម
- តាមស្បែកនៅពេលដែលសត្វត្រូវរបួស ឬមានការរបកស្បែក

នៅពេលដែលមេរោគចូលទៅក្នុងខ្លួនសត្វ

- ស៊ីផ្នែកខាងក្នុងនៃខ្លួនសត្វ អោយសត្វឈឺ
    - មេរោគខ្លះខ្សោយ
    - មេរោគខ្លះខ្លាំង
- អ្នកយាមវាយប្រហារជាមួយនឹងមេរោគ
- កំដៅក្នុងខ្លួនសត្វឡើងក្តៅ




មេរោគចេញពីខ្លួនសត្វតាមរយៈ

- តាមខ្យល់ពេលដែលសត្វដកដង្ហើមចេញ
- តាមលាមកនៅពេលដែលសត្វជុះអាចម៍
- តាមទឹកនោមនៅពេលដែលសត្វជុះនោម
- តាមទឹកមាត់នៅពេលដែលសត្វហៀរទឹកមាត់
- តាមសំបោរនៅពេលសត្វហៀរសំបោរ
- តាមទឹករងៃនៅពេលដែលវាជ្រាបចេញពីមុខរបួស




ដូចនេះវាមានលក្ខណៈងាយស្រួល ទៀត ។ ចំពោះមេរោគក្នុងការឆ្លងពីសត្វមួយទៅសត្វផ្សេង



# តើយើងអាចធ្វើអ្វីបានខ្លះនៅពេលសត្វឈឺ ដោយសារមានការវាយប្រហារពីមេរោគ

នៅពេលដែលសត្វគ្រុនយើងអាច

- ប្រើថ្នាំដើម្បីព្យាយាមសំលាប់ រឺ បង្អង់សកម្មភាពមេរោគ ដើម្បីអោយ ប្រព័ន្ធការពារអាចទទួលជ័យ ជំនះក្នុងការវាយប្រហារជាមួយនឹងមេរោគ និងសត្វអាចជាសះស្បើយឡើងវិញ ។
- ថ្នាំនេះវាខុសពីថ្នាំសំលាប់ព្រូន និងសំលាប់ចៃ ដង្កែ និង អង្កែ ។

ឧទាហរណ៍

- ថ្នាំ streptopen
- ថ្នាំ Oxytetracycline
- ថ្នាំ Sulfa

## 2.4.4 នៅពេលសត្វពុល

មានកត្តាជាច្រើនដែលអាចធ្វើអោយសត្វពុល ។




ឧទាហរណ៍

- ស្លឹករុក្ខជាតិមួយចំនួន
- ពស់ចឹក
- ពងគីង្គក់
- សត្វល្អិតទិច
- សារធាតុគីមី ( ថ្នាំសំលាប់សត្វល្អិត ជី អ៊ុយរ៉េ)

ជាតិពុលទាំងអស់នេះអាចចូលទៅក្នុងខ្លួនសត្វ

- ស៊ីចំណីដោយសារជាតិទាំងនោះ
- ស្បែក

នៅពេលជាតិពុលចូលទៅក្នុងខ្លួនសត្វវានឹងធ្វើអោយ

- មានការខូចខាតដល់សរីរាង្គ
- សត្វឈឺ

សត្វដែលពុលអាចបង្ហាញអោយឃើញ

- រោគសញ្ញាផ្សេង១ពីគ្នា
  - ពីព្រោះដោយសារ វាមានជាតិពុលច្រើន ប្រភេទខុស១គ្នាដែរ
  - ពីព្រោះដោយសារ ជាតិពុលនេះ អាចមានកំរិត
    - ខ្សោយ
    - មធ្យម
    - ខ្លាំង

ឧទាហរណ៍ :

- ជាតិពុលដែលមាននៅក្នុងស្មៅហើយចូលទៅក្នុងថ្លើម ធ្វើអោយថ្លើមមានការឈឺចាប់យ៉ាងខ្លាំង ។ ដូចនេះ ថ្លើមមិនចង់ ធ្វើការមិនចង់ទទួលយកចំណីដែលចែកចាយចំណីទៅអោយសរីរាង្គផ្សេង១ ទៀត ។

សត្វមានអារម្មណ៍ឈឺចាប់ហើយចាប់ផ្តើមចុះស្គម ហើយបើសិនជាយើងយកដៃស្ទាប ឬសង្កត់ខ្លួនសត្វត្រង់ម្តុំ ក្បែរ ថ្លើម ពេលនោះសត្វហាក់ដូចជាមានការចុកចាប់ ។

សត្វដែលពុលអាចមានអាការៈដូចខាងក្រោម :

- ស្លាប់មួយរំពេច ( ពុលខ្លាំង)
- ដើរធេងធោង និងវិលវល់ ( ជាតិពុលមានឥទ្ធិពលដល់សាច់ដុំ ឬខួរក្បាល)
- រាគអាចម៍ ( ជាតិពុលមានឥទ្ធិពលលើពោះវៀនតូច)
- ធ្វើអោយហើមពោះ ( ជាតិពុលមានឥទ្ធិពលលើក្រពះ)
- និងមានបញ្ហាផ្សេង១ ទៀត ។

# តើយើងអាចធ្វើអ្វីបានខ្លះនៅពេលសត្វឈឺ ឬ ស្លាប់ដោយសារជាតិពុល

ឧទាហរណ៍



- នៅពេលដែលសត្វពុលដោយសារជីអ៊ុយរ៉េ យើងអាចអោយសត្វផឹកទឹកខ្មេះ ដើម្បីបន្សាប ជាតិពុលរបស់ជីអ៊ុយរ៉េនេះ ។
- នៅពេលដែល សត្វពុល ដោយសារជាតិគីមី ដែលវាស៊ី នោះយើងត្រូវបុកធ្យូងអោយម៉ត់លាយជាមួយទឹកអោយ សត្វផឹក ។
- បើសិនជាសត្វឈឺដោយសារជាតិពុលផ្សេងៗទៀត យើងត្រូវប្រើប្រាស់ថ្នាំបូរាណ ។

## 2.4.5 ពេលដែលសត្វមានរបួស

នៅពេលដែលសត្វត្រូវទទួលការវាយដំដោយអ្វីមួយ កន្លែងដែលបានប៉ះទង្គិចនោះនឹងត្រូវខូចខាត ។

ឧទាហរណ៍

- ឡានបុកគោៗនោះអាចបាក់ជើង
- ផ្លែដូង ធ្លាក់ត្រូវលើ ក្បាលគោៗ នោះនឹងត្រូវឈឺចាប់ក្នុងខួរក្បាល ។



ការប៉ះទង្គិច ឬការមានរបួសអាចធ្វើអោយ

- របក ស្បែក សត្វ
- មេរោគជ្រៀតចូលទៅតាមមុខរបួសហើយ ធ្វើអោយសត្វ ឈឺ និង ក្តៅខ្លួន



# តើយើងអាចធ្វើអ្វីខ្លះនៅពេលដែល សត្វមានរបួស



នៅពេលដែលសត្វមានរបួសយើងត្រូវ

- សំអាតមុខរបួសដោយសារប្រើប្រាស់
  - ទឹក
  - ថ្នាំម្សៅដែលអាច
    - ធ្វើមុខរបួសស្ងួត
    - សំលាប់ដង្កូវ
    - ឧទាហរណ៍ ថ្នាំ Negasunt
- បើសិនជាសត្វឈឺ (មានក្តៅខ្លួន) យើងត្រូវចាក់ថ្នាំ សំលាប់ មេរោគ

ឧទាហរណ៍



- ថ្នាំ streptapen
- ថ្នាំ Oxytetracycline
- ថ្នាំ Sulfa

# អ្វីដែលអោយសត្វឈឺ ឬ ស្គម និង អ្វីដែលយើងអាចធ្វើអោយសត្វជា ឬធាត់





# មេរៀនទី ៣

## សកម្មភាពភ្ជាប់ទារសុខភាពសត្វភូមិ
## នៅពេលទៅពិនិត្យសត្វឈឺ



## 3 .1 សេចក្តីផ្តើម

ក្នុងមេរៀននេះអ្នកនិងបានរៀនអំពីអ្វីដែលអ្នកត្រូវធ្វើនៅពេលកសិករមកហៅអ្នកទៅព្យាបាលសត្វឈឺ ។ តើត្រូវធ្វើដូ ម្តេច ដើម្បីអោយដឹងពីមូលហេតុដែលបណ្តាលអោយសត្វឈឺ និង តើអ្នកនិងកសិករគួរតែធ្វើអ្វីខ្លះ ដើម្បីជួយអោយស ជាសះស្បើយ ឡើងវិញ ។

## 3 .2 គោលបំណង

ក្រោយពីការបញ្ចប់ មេរៀនសិក្ខាកាមទាំងអស់នឹងអាចមានសមត្ថភាពដូចខាងក្រោមនេះ

- ដាក់ឈ្មោះរបស់ដំណាក់កាលទាំង៦ នៅពេលទៅពិនិត្យសត្វ
- សរសេរឧទាហរណ៏អំពីអ្វីដែលយើងត្រូវពិនិត្យនៅកន្លែងចិញ្ចឹមសត្វ
- សរសេរឧទាហរណ៏អំពីសំណួរដែលអ្នកត្រូវសួរទៅម្ចាស់សត្វ
- សរសេរអំពីកំដៅធម្មតារបស់សត្វ និងកំដៅនៅពេលវាក្តៅខ្លួន
- សរសេរឧទាហរណ៏អំពីអ្វីដែលអ្នកត្រូវធ្វើនៅពេលដែល អ្នកពិនិត្យសត្វផ្ទាល់
- សរសេរឈ្មោះថ្នាំសំលាប់មេរោគព្រូន ចៃ ដង្កៅ អង្កែ
- បំពេញទំរង់បែបបទនៃពតិមានជំងឺសត្វត្រឹមត្រូវ



## 3 .3 សំភារៈសំរាប់ការសិក្សា :

3 .4 អត្ថបទ

## 3.4.1 សង្ខេប

មាន៦ដំណាក់កាលដែលអ្នកត្រូវអនុវត្តន៍នៅពេលដែលអ្នកទៅពិនិត្យសត្វឈឺ

១- ពិនិត្យទីកន្លែងដែលសត្វរស់នៅ

២- សួរទៅម្ចាស់សត្វអំពីសត្វនិងបញ្ហាដែលកើតឡើងចំពោះសត្វគាត់

៣- វាស់កំដៅសត្វហើយមើលថាតើវាក្តៅរឺអត់

៤- ពិនិត្យមើលសត្វតើមានរោគសញ្ញាអ្វីកើតឡើង

៥- ធ្វើការសង្ស័យនៃមូលហេតុនៃជំងឺ

៦- ជ្រើសរើសយកវិធីព្យាបាលមួយ ឬពីរដើម្បីជួយសត្វអោយជាសះស្បើយឡើងវិញ ។

ដើម្បីជាជំនួយដល់អ្នកអោយនឹកឃើញអ្វីដែលអ្នកត្រូវធ្វើនៅពេលដែលអ្នកទៅពិនិត្យសត្វឈឺអ្នកអាចប្រើដៃរបស់អ្នកដូចបាន បង្ហាញក្នុងរូបភាពខាងក្រោមនេះ ។



## 3.4.2 ពិនិត្យកន្លែងសត្វរស់នៅ




មុនពេលអ្នកពិនិត្យសត្វ អ្នកត្រូវតែពិនិត្យមើលកន្លែងដែលសត្វនោះនៅ ព្រោះយើងចង់ដឹងថា តើសត្វសប្បាយចិត្ត ឬក៏អត់ ។

ឧទាហរណ៍

- កន្លែងនោះល្អ ឬ ក៏អត់
  - មានអនាម័យ
  - ប្រហែលអាចកន្លែងចង្អៀតកខ្វក់
  - ក្តៅពេក
  - ហុយ



បន្ទាប់ពីនោះអ្នកអាចធ្វើការប៉ាន់ស្មានមើល

- តើវាសប្បាយ ឬក៏អត់
- តើវាមានឆ្លងជំងឺពីសត្វផ្សេងទៀត ឬក៏អត់(បើសិនជាវា មានទាក់ទងជាមួយសត្វផ្សេង)

# 3.4.3 សាកសួរម្ចាស់សត្វអំពីសត្វ និងបញ្ហារបស់វា




មានបញ្ហាជាច្រើនអំពីសត្វដែលអ្នកមិនអាចដឹងដោយគ្រាន់តែពិនិត្យមើលដោយផ្ទាល់ភ្នែក ។ ដូច្នេះអ្នកត្រូវការសាកសួរពីម្ចាស់សត្វនូវសំនួរខ្លះ

○ ដំបូងគួរសួរពត៌មានខ្លះពីសត្វ

- បើសិនវាជាសត្វមេ តើវាផើមឬវាកំពុងបំបៅដោះ?
- តើសត្វនេះក្រៀវ រឺអត់?
- តើសត្វនេះមានអាយុប៉ុន្មាន?



○ សួរអំពីបញ្ហារបស់សត្វ

- តើសត្វនេះវាស៊ីចំណី រឺអត់?
- តើសត្វនេះឈឺប៉ុន្មានថ្ងៃហើយ តើម្ចាស់សត្វបានឃើញអ្វីខ្លះ?



○ សួរអំពីថាតើម្ចាស់សត្វបានព្យាបាល ឬចាក់ថ្នាំការពារអ្វីខ្លះហើយដល់សត្វ

- តើថ្នាំអ្វីខ្លះដែលម្ចាស់សត្វបានប្រើប្រាស់ និងប្រើប្រាស់តាំងពីពេលណាមក?



○ សាកសួរអំពីសត្វផ្សេងទៀត ដើម្បីដឹងថាតើបញ្ហានេះធំប៉ុន្មាន?

- តើសត្វផ្សេងទៀតឈឺដែររឺទេ?
- តើសត្វរបស់កសិករផ្សេងទៀត ឈឺដែល ឬអត់



បន្ទាប់ពីនោះអ្នកអាចចាប់ផ្តើមគិតអំពីអ្វីដែលបណ្តាលអោយសត្វឈឺ

## 3.4.4 វាស់កំដៅសត្វ




អ្នកបានរៀនរួចហើយថាការវាស់កំដៅសត្វជួយឱ្យអ្នកដឹងថាតើមានមេរោគកំពុងធ្វើការរុករានខ្លួន សត្វ ឬ អត់ ។
បើសិនជាខ្លួនសត្វឡើងកំដៅ យើងអាចសង្ស័យថាមានមេរោគកំពុងរុករានខ្លួនសត្វ ដែលជាមូលហេតុបណ្ដាលអោយសត្វឈឺ ។ ការវាស់កំដៅសត្វគោ ក្របី ជ្រូក មានប្រយោជន៍ណាស់សំរាប់ការងារភ្នាក់ងារសុខភាពសត្វភូមិ ។ ចំពោះសត្វមាន់នឹងបក្សីផ្សេងទៀតវាមានកំដៅខាងក្នុងខ្លួនវាខ្ពស់ហើយនៅពេលដែលវាឈឺ ជាធម្មតាគឺបណ្ដាលមកពីមេរោគ ដូច្នេះជាធម្មតាយើងមិនបាច់វាស់កំដៅវាឡើយ អ្នកក៏បានរៀនរួចមកហើយពីរបៀបវាស់កំដៅជ្រូក គោ ក្របី ។

- កំដៅធម្មតារបស់គោ ក្របី គឺ (៣៨,៥) (38 .5) , (៣៨-៣៩)(38-39)
  - បើសិនជាសត្វគោក្របីមានកំដៅលើសពី ៣៩,៥ អង្សា ពេលនោះយើងត្រូវសង្ស័យថា មានមេរោគបានចូលក្នុងខ្លួន សត្វហើយកំពុងធ្វើការរុករាននៅខាងក្នុង ។




- កំដៅធម្មតារបស់ជ្រូកគឺ 39 (38.5 - 39.5) (៣៨,៥-៣៩,៥)
- បើសិនកំដៅរបស់ខ្លួនជ្រូកឡើងលើសពី ៣៩,៥អង្សា នោះយើងត្រូវសង្ស័យថាមានមេរោគ បានចូលក្នុងខ្លួនសត្វ ហើយកំពុងធ្វើការរុករាននៅខាងក្នុង ។



- កំដៅធម្មតារបស់មេជ្រូកកើតកូន ឬកំពុងបំបៅដោះកូន គឺ ៣៩-៤០ អង្សា ។ បើសិនជាកំដៅរបស់ខ្លួន
  - ជ្រូកឡើងលើសពី ៤០ អង្សានោះយើងត្រូវសង្ស័យថាមានមេរោគបានចូលក្នុងខ្លួនសត្វហើយកំពុងធ្វើការរុករាននៅខាងក្នុង ។



- ត្រូវចង់ចាំដែរថា ខ្លួនសត្វឡើងក្តៅនៅពេលដែលវាធ្វើការ ច្រើនឬវាឈរក្រោមកំដៅថ្ងៃយ៉ាងក្តៅ ។ ដូច្នេះជាការប្រសើរ អ្នកត្រូវវាស់កំដៅសត្វនៅពេលដែលសត្វសំរាកនៅក្នុងម្លប់ត្រជាក់ ។





## 3.4.5 ការពិនិត្យមើលរោគសញ្ញាដែលកើតមានលើខ្លួនសត្វ




ក្រោយពីពេលវាស់កំដៅហើយអ្នកត្រូវពិនិត្យអោយបានច្បាស់នៅលើខ្លួនសត្វ ដើម្បីរកមើលថាតើមានអ្វីដែលខុសពីធម្មតា ។

ឧទាហរណ៍

- តើអ្នកគិតថាសត្វនេះមានទំងន់ប៉ុន្មានគីឡូ? ធាត់ឬស្គម?
- តើសត្វមានភាពស្រងូតស្រងាត់ ឬ យ៉ាងណា?
- តើវាដកដង្ហើមធម្មតា ឬក៏ខ្សោយ ខ្លីច ឬរឹងជើង?
- តើវាដកដង្ហើមធម្មតា ឬក៏ ញាប់? វាក្អកដែរ ឬអត់?
- តើវាជុះអាចម៍ធម្មតា ឬទល់លាមក ឬរាគអាចម៍ ឬក៏វារាគមួល?
- តើវានោមមកធម្មតា ? តើទឹកនោមពណ៌ធម្មតា ឬខុសពីធម្មតា?
- តើស្បែក និងរោមវាធម្មតា ឬស្ងួត ឬរលោង ?តើស្បែកវាមានពណ៌ខុសពីធម្មតាដែលឬទេ?
- តើវារមាស់ឬទេ? វាមានចៃ ដង្កែ ឬអត់?
- តើភ្នែកវាធម្មតាឬខ្វង ឬក្រហម ឬក៏មានហៀរទឹកភ្នែក?
- តើមាត់ច្រមុះវាធម្មតា ឬមានអ្វីប្លែក?
- តើមានឃើញអ្វីទៀតដែលអ្នកគិតថាវាមិនប្រក្រតី?

ការសួរនូវសំនួរខាងលើនេះអាចជួយអ្នកក្នុងការធ្វើការសង្ស័យលើមូលហេតុនៃជំងឺ ។

# 3.4.6 ការសង្ស័យលើ មូលហេតុនៃជំងឺ




ពេលនេះជាពេលដែលអ្នកត្រូវគិតនូវអ្វីដែលអ្នកបានឃើញនិងនូវអ្វីដែលកសិករបាននិយាយប្រាប់អ្នក។ បន្ទាប់មកអ្នកនឹងអាច ធ្វើការសង្ស័យលើមូលហេតុ ដែលបណ្តាលអោយសត្វឈឺ ។ អ្នកអាចមានការសង្ស័យ

- មួយ ឬ



- ច្រើន



នូវមូលហេតុនៃជំងឺ ក្នុងចំនោមមូលហេតុទាំង៦ ដែលអ្នកបានរៀនរួចមកហើយ ។

## 3.4.7
# ការជ្រើសរើសវិធីព្យាបាលដើម្បីជួយអោយសត្វជាសះស្បើយ

6



ពេលនេះគឺជាពេលដែលអ្នកត្រូវធ្វើការជ្រើសរើសរកវិធីព្យាបាលណាមួយដែលអាចជួយអោយសត្វជាសះស្បើយ ។ អ្នកអាច ជ្រើសរើសវិធីព្យាបាលមួយឬក៏ច្រើនជាងមួយ នៃវិធីព្យាបាលទាំង៥ទៅតាមការសង្ស័យរបស់អ្នកនូវមូលហេតុនៃជំងឺ ។

### ១. ធ្វើអោយសត្វសប្បាយចិត្ត

- គ្មានថ្នាំណាដែលធ្វើអោយសត្វសប្បាយចិត្តនោះទេ ។
- នេះគឺជាការងាររបស់ម្ចាស់សត្វ ។



### ២. ផ្តល់ចំណីអាហារនិងទឹកគ្រប់គ្រាន់ដល់សត្វ

ឧទាហរណ៍ :

- បើសិនជាសត្វភាគអាចម៍ រឺក៏ខ្វះជាតិទឹកនៅក្នុងខ្លួនអ្នកអាចប្រើថ្នាំលាយជាមួយទឹកអោយសត្វផឹកដើម្បីឱ្យក្រពះអាចផ្តល់ទឹកទៅឱ្យឈាម ។



ដើម្បីឱ្យសត្វសប្បាយចិត្ត កសិករម្ចាស់សត្វត្រូវបង្កើននិងយកចិត្តទុកដាក់ក្នុងការថែរក្សាសត្វអោយបានដិតដល់ ។

អ្នកអាចជួយពន្យល់ដល់កសិករថា បើកន្លែងចិញ្ចឹមសត្វ

មិនស្អាតឬក៏មិនមានចំណីនិងទឹកគ្រប់គ្រាន់ទេនោះគ្មានអ្វីដែលអាចជួយអោយសត្វបានសប្បាយចិត្តឡើយ ។ ហើយក៏គ្មានមូលហេតុអ្វីដែលធ្វើអោយសត្វឈឺ ក្រៅពីការខ្វះការថែទាំ និងអោយចំណីអាហារ ទឹកគ្រប់គ្រាន់នោះទេ ។

## ៣. ប្រើថ្នាំសំលាប់ព្រូន ឬ ថ្នាំសំលាប់ចៃ ដង្កែ អង្កែ



## ៤. ប្រើថ្នាំសំលាប់មេរោគ



មានថ្នាំព្យាបាលច្រើនប្រភេទនៅក្នុងការព្យាបាលជំងឺសត្វ ។
លោកគ្រូអ្នកបានបង្ហាញនូវថ្នាំខ្លះរួចមកហើយ
នៅក្នុងមេរៀនទី២ ។

ពេលនេះគ្រូអ្នកនឹងពន្យល់របៀបប្រើប្រាស់ថ្នាំនីមួយៗ ដែលអ្នកអាចទិញបាននៅក្នុងឱសថស្ថានក្នុងខេត្តរបស់អ្នក នៅពេល ដែលគ្រូអ្នកពន្យល់អំពីថ្នាំនីមួយៗ ចូរសរសេរឈ្មោះថ្នាំនេះតាមកន្លែងអោយបានត្រឹមត្រូវ ។

## ៥. ប្រើថ្នាំដើម្បីបន្សាបជាតិពុល

- ប្រើទឹកខ្មេះដើម្បីបន្សាបជាតិពុលដោយជាតិអ៊ុយរ៉េ ។

ប្រើថ្នាំបូរាណដើម្បីបន្សាបជាតិពុលផ្សេងៗ ។

មិនស្អាតឬក៏មិនមានចំណីនិងទឹកគ្រប់គ្រាន់ទេនោះគ្មានអ្វីដែលអាចជួយអោយសត្វបានសប្បាយចិត្តឡើយ ។ ហើយក៏គ្មានមូលហេតុអ្វីដែលធ្វើអោយសត្វឈឺ ក្រៅពីការខ្វះការថែទាំ និងអោយចំណីអាហារ ទឹកគ្រប់គ្រាន់នោះទេ ។

## ៣. ប្រើថ្នាំសំលាប់ព្រូន ឬ ថ្នាំសំលាប់ចៃ ដង្កែ អង្កែ



## ៤. ប្រើថ្នាំសំលាប់មេរោគ

មានថ្នាំព្យាបាលច្រើនប្រភេទនៅក្នុងការព្យាបាលជំងឺសត្វ ។
លោកគ្រូអ្នកបានបង្ហាញនូវថ្នាំខ្លះរួចមកហើយ
នៅក្នុងមេរៀនទី២ ។



ពេលនេះគ្រូអ្នកនឹងពន្យល់របៀបប្រើប្រាស់ថ្នាំនីមួយៗ ដែលអ្នកអាចទិញបាននៅក្នុងឱសថស្ថានក្នុងខេត្តរបស់អ្នក នៅពេល ដែលគ្រូអ្នកពន្យល់អំពីថ្នាំនីមួយៗ ចូរសរសេរឈ្មោះថ្នាំនេះតាមកន្លែងអោយបានត្រឹមត្រូវ ។

## ៥. ប្រើថ្នាំដើម្បីបន្សាបជាតិពុល

- ប្រើទឹកខ្មេះដើម្បីបន្សាបជាតិពុលដោយជាតិអ៊ុយរ៉េ ។

ប្រើថ្នាំបូរាណដើម្បីបន្សាបជាតិពុលផ្សេងៗ ។

ព័ត៌មានស្តីពីជំងឺសត្វ ភូមិ........................ ឃុំ...................... ស្រុក.......................... ខេត្ត.........................

គោ ☐ ក្របី ☐ ជ្រូក ☐ មាន់ ☐ សត្វផ្សេងៗ......................... ឈ្មោះម្ចាស់សត្វ.........................

១ កន្លែងចិញ្ចឹមល្អ ☐ កន្លែងចិញ្ចឹមមិនល្អ ☐

ឈ្មោះបសុពេទ្យ............... ថ្ងៃ........ខែ......ឆ្នាំ.........

ឈ្មោល/ញី.............

អាយុ..........ក្រៀវ/អត់ក្រៀវ...............ផើម/អត់ផើម/មានកូនបៅដោះ..............................

២ សត្វស៊ីចំណីមានសភាពយ៉ាងម៉េច?...........................................................................................

....

ដាក់ចំណីអ្វីអោយសត្វស៊ី?.......................................................................................................

....

សត្វឈឺប៉ុន្មានថ្ងៃហើយ?.........................................................................................................

៣ កំដៅប៉ុន្មាន?.................................

៤ ទំងន់ប៉ុន្មាន គក្រ?.......... សត្វធាត់ ☐ ធម្មតា ☐ សត្វស្គម ☐

| | | |
|---|---|---|
| សត្វអន់តិច ☐ | សត្វអន់ខ្លាំង ☐ | |
| សត្វដើរធម្មតា ☐ | ដើរមិនធម្មតា ☐ | ដំណើរយ៉ាងម៉េច?.................................. |
| លាមកធម្មតា ☐ | លាមករាគលាមកក្លៀន ☐ | មានសភាពយ៉ាងម៉េច?............................... |
| ទឹកនោមធម្មតា ☐ | ទឹកនោមមិនធម្មតា ☐ | មានសភាពដូចម្តេច?................................. |
| សត្វដកដង្ហើមធម្មតា ☐ | សត្វដកដង្ហើមញាប់ ☐ | សត្វក្អក |
| មាត់ច្រមុះធម្មតា ☐ | មាត់ច្រមុះមិនធម្មតា ☐ | មានសភាពយ៉ាងម៉េច?............................... |
| ភ្នែកធម្មតា ☐ | ភ្នែកមិនធម្មតា ☐ | មានសភាពយ៉ាងម៉េច?............................... |
| ស្បែកនិងរោមធម្មតា ☐ | ស្បែកនិងរោមមិនធម្មតា ☐ | មានសភាពយ៉ាងម៉េច?............................... |

មានបញ្ហាអ្វីផ្សេងទៀត?..........................................................................................................

៥

សត្វឈឺបណ្តាលមកពី :



៦

ការព្យាបាលដោយប្រើថ្នាំអ្វី?

ឈ្មោះថ្នាំ — ប៉ុន្មាន CC (គ្រាប់) ម្តង

១......................................... .........................................

២......................................... .........................................

ការណែនាំដល់ម្ចាស់សត្វ .............................................................................................

បានព្យាបាលប៉ុន្មានថ្ងៃ :..................សត្វជា សត្វមិនជា សត្វស្លាប់

# 3.3 សកម្មភាព

# លេងល្បែងព្យាបាលសត្វ



# 3.4 សង្ខេប



# មេរៀនទី ៤

## ការចិញ្ចឹមសត្វអោយមានសុខភាពល្អ



## 4 .4 អត្ថបទ

# 4.4.1 ការថែរក្សាអោយសត្វសប្បាយចិត្តជានិច្ច

មានវិធីតែមួយគត់ដែលធ្វើអោយសត្វសប្បាយចិត្តជានិច្ច គឺការថែទាំល្អ រឺការគ្រប់គ្រងល្អដែលមាននៅក្នុងឧទាហរណ៍ខាងក្រោមនេះ

ឧទាហរណ៍

- ជំរកនិងកន្លែងស្នាក់នៅគឺជាកត្តាដ៏សំខាន់ក្នុងការការពារកុំអោយសត្វឈឺ ។ វាអាច
  - ជួយបន្ថយនូវឥទ្ធិពលអាក្រក់របស់អាកាសធាតុ
  - បញ្ឈប់សត្វពីការដើរចច្រប់យ៉ាងឆ្ងាយ
  - ការពារកុំអោយចោរលួច
  - កុំអោយទៅជួបជាមួយនឹងសត្វដ៏ទៃដែលមានមេរោគក្នុងខ្លួន ហើយអាចចំលងមេរោគទាំងនោះទៅសត្វ ផ្សេងទៀតបាន
  - អោយអ្នកផ្តល់ចំណីអាហារ និងទឹកដល់សត្វបានគ្រប់គ្រាន់ និងងាយស្រួលដោយគ្មានសត្វផ្សេងៗទៀតចូល មកលួចស៊ីបានឡើយ
  - មិនត្រូវប្រើសត្វធ្វើការងារដោយគ្មានការសំរាក
  - មិនត្រូវអោយសត្វដើរឆ្ងាយដោយគ្មានការសំរាកនោះឡើយ
  - ការផ្តល់កន្លែងអោយក្របី និងជ្រូកដេកត្រាំទឹកនៅពេលដែល មានអាកាសធាតុក្តៅខ្លាំង (ព្រោះក្របីនិង ជ្រូកមិនអាចបញ្ចេញញើសបានល្អទេ)
  - ការលាងទឹកអោយគោ ដើម្បីសំអាតខ្លួនវា និងការចាប់ដង្កែចេញពីខ្លួនវា

## 4.1 សេចក្ដីផ្ដើម

រហូតមកទល់ពេលនេះ យើងបាននឹងកំពុងរៀនអំពីសត្វ ដែលកំពុងឈឺ និងតើយើងអាចជួយសត្វទាំងនោះ សុខភាពល្អឡើងវិញយ៉ាងដូចម្ដេច?

ពេលនេះយើងនឹងសិក្សាអំពី វិធីដែលធ្វើអោយសត្វជាសះស្បើយ មានសុខភាពកាន់តែល្អប្រសើរ និងវិធី ទាំងនោះកុំអោយឈឺ ។

## 4.2 គោលបំណង

ក្រោយពីបញ្ចប់ មេរៀន សិក្ខាកាមទាំងអស់នឹងអាចមានសមត្ថភាពដូចខាងក្រោមនេះ

- កំណត់ឈ្មោះកត្តា៤យ៉ាងដែលធ្វើអោយសត្វមានសុខភាពកាន់តែល្អប្រសើរនិងធំធាត់ល្អ
- សរសេរឧទាហរណ៍ពីកន្លែងចិញ្ចឹមល្អ
- សរសេរឧទាហរណ៍អំពីកន្លែងផ្ដល់ចំណីទឹកគ្រប់គ្រាន់
- សរសេរឧទាហរណ៍អំពីកម្មវិធីចាក់ថ្នាំការពារអោយសត្វ
- សរសេរឧទាហរណ៍អំពីកម្មវិធីទំលាក់ព្រូនអោយសត្វ

## 4.3 សំភារៈសំរាប់សិក្សា

## 4.4.2 ការផ្តល់ចំណីអោយសត្វបានគ្រប់គ្រាន់

យើងបាននិយាយពីមុន រួចមកហើយថា ប្រសិនបើសត្វមិនបានទទួលចំណីនិងទឹកគ្រប់គ្រាន់

- គ្រប់សរីរាង្គទាំងអស់នឹងចុះខ្សោយ
- ធ្វើអោយសត្វងាយនិងទទួលជំងឺ

ដូច្នេះបើសិនជាអ្នកចិញ្ចឹមសត្វបានល្អ សត្វរបស់អ្នក

- មានសុខភាពរឹងមាំ
- មិនងាយនឹងទទួលជំងឺ



## ចំពោះសត្វគោនិងក្របី



- គោនិងក្របីត្រូវការស៊ីស្លឹករុក្ខជាតិបៃតង ។ បើសិនគ្មានស្មៅគ្រប់គ្រាន់យើងអាចចិញ្ចឹមវាដោយអោយស៊ីស្លឹកឈើបៃតង ។

តើស្លឹកឈើបៃតងណាខ្លះដែលអាចធ្វើជាចំណីរបស់គោ និងក្របីបាន?

.................... .................... .................... ....................

.................... .................... .................... ....................

- ស្លឹកដំឡូងឈើស្រស់មានជាតិពុលដល់សត្វ ។ បើសិនយើងទុកស្លឹកនេះអោយស្រពោនសិនពេលយក អោយសត្វស៊ី នោះៗវាមិនបណ្តាលអោយមានគ្រោះថ្នាក់អ្វីឡើយ ។
- បើសិនជាគោក្របីរបស់អ្នកស៊ីស្លឹងឈើបៃតងមិនគ្រប់គ្រាន់ជារៀងរាល់ថ្ងៃទេ អ្នកអាចផ្តល់ចំបើងអោយវាស៊ី រហូតដល់ឆ្អែត ។

សត្វគោនិងក្របីចូលចិត្តស៊ីចំបើង តែចំបើង ពុំមានជីវជាតិគ្រប់គ្រាន់ទេ ។

បើសិនជាគោក្របីរបស់អ្នកមិនបានស៊ីស្លឹករុក្ខជាតិបៃតង តែបានស៊ីតែចំបើង នោះអ្នកអាចធ្វើចំបើងផ្សាប់ដោយលាយជាមួយនិងជីអ៊ុយរ៉េ ដើម្បីអោយចំបើងកាន់តែមានជីវជាតិនិងមានរស់ជាតិឆ្ងាញ់ ។

គោក្របីរបស់អ្នកត្រូវការអំបិលខ្លះៗជារៀងរាល់ថ្ងៃ ។ ហេតុដូចនេះហើយបានជាវាចូលចិត្តលិតស្បែកគ្នាទៅទៅមកដើម្បីបានទទួលជាតិអំបិលខ្លះដែលចេញពីញើស ។ ប្រសិនបើគោក្របីរបស់អ្នកខ្វះជាតិអំបិលនៅក្នុង នោះវាធ្វើអោយគោក្របីមិនសូវចង់ស៊ីស្លឹករុក្ខជាតិបៃតង រឺចំបើង ។ ដូច្នេះអ្នកត្រូវផ្តល់អំបិលខ្លះដល់គោរបស់អ្នកជារៀងរាល់ថ្ងៃ ដោយប្រោះទឹកអំបិលលើចំបើង រឺដាក់អំបិលអោយវាលិត ។

សូមប្រុងប្រយ័ត្ន! ចូរកុំផ្តល់អំបិលដល់គោក្របីច្រើនពេក ព្រោះធ្វើអោយវាស្រេកទឹកខ្លាំង ។

- គោក្របីត្រូវការផឹកទឹកស្អាតយ៉ាងហោចណាស់ក៏ម្តងយ៉ាងយូរក្នុងមួយថ្ងៃ ។
  ប្រសិនវាឈឺវាត្រូវការផឹកទឹកកាន់តែញឹក ញាប់ក្នុងមួយថ្ងៃ ។

## ចំពោះសត្វជ្រូក

ប្រជាជនកម្ពុជាចូលចិត្តចិញ្ចឹមជ្រូក ប៉ុន្តែគ្មាននរណាម្នាក់ចូលចិត្តចំណាយប្រាក់សំរាប់ចិញ្ចឹមវាឡើយ ។ ហេតុនេះហើយជាជ្រូកនៅកម្ពុជា

- ការធំធាត់យឺត
- ឆាប់ទទួលជំងឺ

បបរលាយកន្ទក់មិនគ្រប់គ្រាន់សំរាប់ការចិញ្ចឹមជ្រូក អោយបានធំធាត់លឿន និងមានសុខភាពល្អនោះទេ ។ ចំណីដែលថោក ជាងគេហើយដែលប្រើសំរាប់បង្កើនជីវជាតិចំណីគឺស្លឹករុក្ខជាតិបៃតង ។ ជ្រូកក៏ជាសត្វដែលចូលចិត្តស៊ីស្មៅណាដែលវា អាចស៊ីកើត ។

តើស្លឹករុក្ខជាតិបៃតងណាខ្លះដែលជ្រូកអាចស៊ីបាន :

.................. .................. .................. .................. ..................

.................. .................. .................. .................. ..................

បើសិនជាអ្នកចង់ចិញ្ចឹមជ្រូកអោយធំធាត់ខ្លាំង និងមានសុខភាពល្អ អ្នកត្រូវអោយវាស៊ីជារៀងរាល់ថ្ងៃ

- ត្រី
- សណ្តែកខ្លះៗ ។ ចំអិននិងបុកសណ្តែកជាមុនសិនទើបអោយជ្រូកស៊ី បើមិនដូចនេះទេ សណ្តែកនឹងចេញមកក្រៅទាំងមូលវិញតាមលាមក ដែលធ្វើអោយមាន់សប្បាយចិត្តយ៉ាងខ្លាំង ។ ធ្វើដូចនេះមានន័យថាអ្នកមិនបានជួយជ្រូកទេ បែរជាជួយមាន់ទៅវិញ ។
- រៀបចំកន្លែងដាក់ទឹកស្អាតអោយជ្រូកអ្នកអាចផឹកបានគ្រប់ពេលវេលា ។

### ចំពោះសត្វមាន់

- កន្ទក់និងចុងអង្ករជាចំណីដ៏ល្អសំរាប់សត្វមាន់ ហើយវាមានតំលៃថោកជាងអង្ករ ប៉ុន្តែអ្នកត្រូវដាក់ចំណីនេះអោយស៊ីនៅក្នុងស្នូក ធ្វើដូចនេះវាមិនអាចប្រឡាក់ រឺលាយជាមួយនឹងកំទេចដីដែលនៅលើដី ។

មាន់នៅកម្ពុជាតែងតែស្រេកទឹកជានិច្ច ដូច្នេះបើសិនជាអ្នកចង់អោយមាន់ឆាប់ធំធាត់និងមានសុខភាពល្អត្រូវរៀបចំកន្លែងដាក់ទឹកដែលអាចអោយវាផឹកបាននៅពេលណាដែលវាត្រូវការ ។

## 4.4.3 ការការពារដែលបង្កឡើងដោយព្រូន

### សត្វក្មេង

ស្ទើរតែគ្រប់សត្វទាំងមានព្រូននៅក្នុងខ្លួន នៅពេលដែលវានៅក្មេង ។ នេះដោយសារ



- មានពងជាច្រើននៅពាសពេញដី
- នៅពេលដែលកូនសត្វទាំងនោះ ស៊ីដោយវា ពងព្រូននឹងចូលទៅក្នុងខ្លួនសត្វ បន្ទាប់មកក៏ញាស់ក្លាយជាព្រូន ហើយចាប់ផ្តើមស៊ីផ្នែកខាងក្នុងនៃសត្វ ។
- ប្រព័ន្ធការពាររបស់កូនសត្វមិនដែលបានឃើញព្រូននេះពីមុនមក ដូច្នេះវាមិនអាចធ្វើការប្រយុទ្ធតបត និងព្រូននេះបានឡើយ ។

  (សត្វធំៗចាស់ៗដែលមានប្រព័ន្ធការពារធ្លាប់បានឃើញនិងស្គាល់ព្រូននេះពីមុនមក ដូច្នេះប្រព័ន្ធការពារនេះ អាចមានសមត្ថភាពប្រយុទ្ធកំចាត់ព្រូនទាំងនេះបាន) ។

នេះជាហេតុដែលបណ្តាលឱ្យកូនសត្វមានព្រូនច្រើនជាងសត្វធំ ។

ដូច្នេះទោះបីកូនសត្វមើលទៅហាក់បីដូចជាមិនឈឺដោយព្រូនក៏ដោយ ក៏យើងត្រូវដឹងថា

- មានព្រូននៅក្នុងកូនសត្វនោះ
- ព្រូនកំពុងតែធ្វើអោយកូនសត្វនោះឈឺ

ដូច្នេះកសិករគួរតែព្យាបាលកូនសត្វដោយប្រើថ្នាំទំលាក់ព្រូន ទោះបីជាកូនសត្វនោះមិនទាន់ឈឺក៏ដោយ ។ នេះគឺការពារសត្វរបស់អ្នកពីជំងឺ ។



# 4.4 ការការពារជំងឺដែលបង្កឡើងដោយមេរោគ

ការការពារជំងឺសត្វដែលបង្កឡើងដោយមេរោគមានសារសំខាន់ណាស់ ហើយដើម្បីងាយយល់លើបញ្ហានេះ យើងគួរតែធ្វើការឧបមាថា យើងគឺជាសរីរាង្គម្តងទៀត ។

តើអ្នកនៅចាំបានទេ នៅពេលដែលមេរោគបានចាប់ផ្តើមរុករាននិងធ្វើការបំផ្លាញផ្នែកខាងក្នុងនៃខ្លួនសត្វហើយប្រព័ន្ធការពារ មានកំលាំងខ្សោយក្នុងការប្រយុទ្ធជាមួយនិងមេរោគទាំងនោះ ។



ជាការប្រសើរណាស់ បើសិនជាយើងអាចធ្វើអោយប្រព័ន្ធការពារធ្វើការប្រយុទ្ធប្រឆាំងតបតជាមួយមេរោគពិតប្រាកដដោយ

- ការចាក់បញ្ចូលទៅក្នុងខ្លួនសត្វនូវល្បាយនៃមេរោគស្លាប់រឺខ្សោយមួយប្រភេទ ។
  - ល្បាយនៃមេរោគមួយប្រភេទនេះ ហៅថា "វ៉ាក់សាំង" រឺថ្នាំការពារ
  - ក្រោយពេលចាក់បញ្ចូលវ៉ាក់សាំងទៅក្នុងខ្លួនសត្វ មេរោគស្លាប់រឺខ្សោយនេះ បានធ្វើដំណើរចូលទៅក្នុងឈាម ។ ពេលនោះប្រព័ន្ធការពារបានឃើញនិងស្គាល់មេរោគប្រភេទនេះរួចជាស្រេចដូច្នេះនៅ ពេលដែលមានមេរោគនេះពិតប្រាកដចូលទៅធ្វើការប្រយុទ្ធជាមួយនិងប្រព័ន្ធការពារ ប្រព័ន្ធការពារនឹងអាចប្រយុទ្ធឈ្នះរឺសំលាប់មេរោគទាំងនោះបានយ៉ាងស្រួល ។

រឿងនេះវាមិនខុសពីការបង្ហាញរូបថត របស់ចោរប្លន់ទៅប៉ូលីសនិងអត្ថាធិប្បាយអំពីអាវុធនិងវិធីប្រយុទ្ធរបស់ចោរអោយប៉ូលីសបានដឹង ។ ដូច្នោះនៅពេលដែលចោរប្លន់ចូលមកធ្វើការប្រយុទ្ធ ប៉ូលីសបានត្រៀមខ្លួនជាស្រេចក្នុងការចាប់ចោរ ព្រោះតែប៉ូលីសបាន ស្គាល់នូវភិនភាគនិងល្បិចរបស់ចោររួចជាស្រេច ។




ចូរចងចាំថា :

- មានតែមេរោគខ្សោយ រឺស្លាប់តែមួយប្រភេទគត់ នៅក្នុងដបនៃវ៉ាក់សាំង ។
- ដូចនេះហើយ នៅពេលដែលចាក់វ៉ាក់សាំងទៅក្នុងខ្លួនសត្វ បានន័យថា ប្រព័ន្ធការពារបានឃើញនិងស្គាល់មេរោគតែមួយប្រភេទនេះតែប៉ុណ្ណោះ គឺមិនបានស្គាល់មេរោគផ្សេងទៀតឡើយ ។
- ជាទូទៅយើងអាចនិយាយបានថា ក្រោយពីពេលចាក់វ៉ាក់សាំង បានរយៈពេលប្រហែល ១០ថ្ងៃមក ទើបប្រព័ន្ធ ការពារអាចស្គាល់មេរោគទាំងនោះបាន ច្បាស់លាស់ល្អ ។



- ជាធម្មតា យើងក៏អាចនិយាយបានដែលថា ក្រោយពីពេលចាក់វ៉ាក់សាំង ប្រព័ន្ធការពារអាច មានការចងចាំអំពីមេរោគនេះបាន ប្រហែលមួយឆ្នាំប៉ុណ្ណោះ ។ ដូច្នេះវាអាចប្រយុទ្ធឈ្នះមេរោគនេះតែក្នុងរយៈពេលដែលវាបានចងចាំតែប៉ុណ្ណោះ ។




- ក៏ប៉ុន្តែ ចំពោះកូនសត្វដែលចាក់វ៉ាក់សាំងនេះលើកដំបូង ប្រព័ន្ធការពាររបស់វា អាចនៅចងចាំបានមេរោគនេះ តែក្នុងរយៈពេល ២ រឺ ៣ខែតែប៉ុណ្ណោះវានឹងភ្លេចទៅវិញយ៉ាងឆាប់រហ័ស ។ ម្លោះហើយចំពោះកូនសត្វត្រូវចាក់វ៉ាក់សាំងរំលឹកឡើងវិញម្តងទៀត ដើម្បីអោយប្រព័ន្ធការពារមានការចងចាំឡើងវិញ ។




- យើងពុំមានវ៉ាក់សាំងការពារគ្រប់ជំងឺ ដែលបង្កឡើងដោយមេរោគនោះទេ ។ ប៉ុន្តែយើងមានប្រភេទនៃវ៉ាក់សាំងមួយចំនួនដែលអាចការពារនិងមេរោគសាហាវដែលបង្កជំងឺសត្វនៅក្នុងប្រទេសកម្ពុជា ។ អ្នកនឹងបានរៀនអំពីវ៉ាក់សាំងនេះនៅក្នុងមេរៀនទី៥ និងទី៦ ។



# 4.5 សកម្មភាព

យើងនាំគ្នាលេងល្បែងអំពីការចិញ្ចឹមសត្វ  ដើម្បីបានអនុវត្តន៍នូវអ្វីដែលយើងបានរៀនក្នុងមេរៀននេះ ។



# ការចិញ្ចឹមសត្វគោ

## *CATTLE RAISING*

ការចិញ្ចឹមគោជាលក្ខណៈគ្រួសារ ចាំបាច់យើងត្រូវដឹងពីបច្ចេកទេសនៃការចិញ្ចឹមដើម្បីជួយថែរក្សាគោឱ្យមានសុខភ និងជួយជាកម្លាំងអូសទាញសំរាប់ ការប្រើប្រាស់ឱ្យបានយូរអង្វែង ព្រោះគោក្របីជាសត្វមានប្រយោជន៍សំខាន់ដូចជា

-វាផ្តល់ជាកំលាំងអូសទាញសំរាប់ការងារកសិកម្ម

-វាផ្តល់ជាសាច់ និងទឹកដោះ សំរាប់មនុស្សបរិភោគ

- វាផ្តល់ការផលិតកូន សំរាប់បន្តពូជ

- វាផ្តល់លាមក សំរាប់ធ្វើជាជី បង្កើនផលិតផលកសិកម្ម

ដើម្បីអោយការចិញ្ចឹមទទួលបានលទ្ធផលល្អ យើងត្រូវយល់ដឹងអំពីបច្ចេកទេសនៃការចិញ្ចឹមមួយចំនួនដូច

:

១- ជំរក ឬ ក្រោល

២- ការជ្រើសរើសពូជ

៣- ចំណី និងការផ្តល់ចំណី

៤- ការថែទាំ និង ការពារ

### I. ជំរក ឬ ក្រោល



គោក្របី ត្រូវការចាំបាច់នូវជំរក ដើម្បីការពារនូវកំដៅព្រះអាទិត្យ ការពារនូវរដូវវស្សាពេលមានភ្លៀងធ្លាក់ខ្លាំង ដូច មនុស្សយើងដែល ប៉ុន្តែជំរកមិនចាំបាច់មានជញ្ជាំងសងខាងនោះទេ ដើម្បីទុកអោយខ្យល់ចេញចូលជំរកគោបានល្អ ។ ត្រូវសង់ជំរកគោនៅលើដីទួល កន្លែងដេករបស់វាត្រូវតែស្ងួតនិងស្អាតជានិច្ច ពីព្រោះមេរោគទាំងឡាយចូលចិត្តរស់នៅ ក្នុងលាមក ភក់ជ្រាំណាស់ ។ ប្រជាកសិករខ្លះមានផ្ទះធំខ្ពស់ផុតពីដី ដែលអាចធ្វើជំរកគោបាននៅខាងក្រោមផ្ទះ ប៉ុន្តែមិនសូវល្អដូចជាសង់រោងជាជំរកវា ដាច់ដោយឡែកទេ (មើលរូបភាពខាងលើ) ។

ដើម្បីរក្សាទុកលាមកគោ ក្របី សំរាប់ធ្វើជាជី ចាំបាច់ត្រូវជីករណ្តៅធំមួយមានប្រក់ដំបូលការពារពន្លឺថ្ងៃនិង ភ្លៀង ។ រណ្តៅធ្វើទៅតាមលទ្ធភាពរបស់កសិករដែលអាចធ្វើបាន ។ បើសិនពុំមានការប្រមូលលាមកដាក់ក្នុងរណ្តៅទេ លាមកដែលត្រូវទុកធ្វើជាជីនោះ ត្រូវភ្លៀងឬខ្យល់អាចធ្វើឱ្យហួតបាត់បង់នូវគុណភាពរបស់វានៅពេលដែលយើងយកទៅប្រើប្រាស់ (មើល រូបភាព) ។

ការថែរក្សានូវគុណភាពជីលាមកសត្វ



ចាំបាច់ត្រូវប្រមូលលាមកគោ ក្របី និងបោសសំអាតជំរក ឬក្រោលជារៀងរាល់ថ្ងៃ ដើម្បីអោយកន្លែងសត្វបានស្អាត និងស្ងួត ជានិច្ច ។ ពីព្រោះគោមិនចូលចិត្តដេកលើភក់ជ្រាំទេ និងដើម្បីរក្សាអនាម័យបានល្អផង ។

## II .ការជ្រើសរើសពូជ

ការចិញ្ចឹមគោ ដើម្បីទទួលបានលទ្ធផលល្អ យើងត្រូវជ្រើសរើសពូជ ព្រោះពូជជាកត្តាសំខាន់បំផុតក្នុងការចិញ្ចឹមដូច្នេះ យើងត្រូវដឹងអំពីពូជ និងប្រវត្តិច្បាស់លាស់ ។ នៅប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ យើងឃើញមានពូជ :

-ពូជបរទេស (មើលរូបភាពខាងក្រោម)

-ពូជក្នុងស្រុក (មើលរូបភាពខាងក្រោម)

ហើយប្រជាកសិករភាគច្រើននិយមចិញ្ចឹមគោកូនកាត់ រវាងគោពូជបរទេស និងពូជក្នុងស្រុក ។



ពូជគោបរទេស និង កូនកាត់

## ក. ការជ្រើសរើសគោបា ដើម្បីបង្កាត់

- ត្រូវជ្រើសរើសបាជាគោពូជល្អ មានជើងមាំ និងក្រចកល្អ
- ត្រូវជ្រើសរើសគោបាដែលមានពងស្វាសទំហំស្មើគ្នា ដែលមានអាយុយ៉ាងតិច ៣ឆ្នាំឡើងទៅ
- ត្រូវជ្រើសរើសគោបាធំ ប៉ុន្តែកុំអោយធំជាងគោមេពេក ពិសេសចំពោះមេគោកូនដំបូង
- ត្រូវពិនិត្យអោយបានច្បាស់លាស់ តើគោបានោះធាត់ ឬស្គម?
- ត្រូវពិនិត្យ តើម្ចាស់គោបានថែរក្សាគោរបស់គាត់បានល្អដែររឺទេ?
- ត្រូវពិនិត្យ តើគោបានោះធ្លាប់ផលិតកូនបានល្អទេនៅក្នុងភូមិ?
- មិនត្រូវបង្កាត់ជាមួយនឹងបា ដែលជាបងប្អូននឹងគ្នាទេ (ពុំសូវល្អព្រោះជាន់ឈាមគ្នា)
- មិនត្រូវបង្កាត់ជាមួយនឹងគោបា ដែលពាក់មេច្រើនក្នុងមួយអាទិត្យ ព្រោះកម្លាំងវាខ្សោយ ។ តាម

គោបាអាច ពាក់មេបានល្អ ក្នុងចំនួន ៧ទៅ១០ក្បាលប៉ុណ្ណោះក្នុងមួយខែ ។

## ខ. ការជ្រើសរើសគោ

- មានរូបរាងស្អាត សុខភាពល្អ
- មានដោះល្អ មានចុងដោះស្មើល្អទាំងបួន
- បើមេគោយើងនៅតូចពេក និងចំណីអាហារមិនល្អ គួរកុំទាន់បង្កាត់ ពន្យាពេលមួយរយៈសិន ព្រ

ត្រូវការធំធាត់ខ្លួនវាផង ត្រូវការផលិតទឹកដោះកូនបៅផង ដូច្នេះពេលនេះវាត្រូវបាក់កំលាំង ហើ

បង្កាត់ជាលើក ទី២ និង ទី៣តទៅទៀតមិនអាចប្រព្រឹត្តទៅបានល្អទេ ។

មេគោដែលព្រមទទួលបាអោយពាក់ លុះត្រាតែមេគោនោះបង្ហាញសញ្ញារកឈ្មោល ក្នុងករណីវាមានសុខភាពល្អ ។ វដ្ត នៃការរកឈ្មោលរៀងរាល់២១ថ្ងៃម្តង គេត្រូវដាក់បាក្នុងកំឡុងពេល ១៨ម៉ោង នៃសញ្ញារកឈ្មោល ។

## គ. សញ្ញានៃការរកឈ្មោល

- មិនសូវស៊ីស្មៅទេ
- ចេះតែស្រែករោទ៍ មានភាពរសាប់រសល់ ច្រាស់ច្រាល ឡើងពាក់គោដទៃដែលនៅជិតខ្លួន
- បេដាប់បន្តពូជរបស់វារីកធំ មានពណ៌ក្រហមព្រឿងៗរលោង និងមានហូរទឹករំអិលតិចៗសថ្លា
- ពេលជួបបាម្តងៗវាត្រៀមខ្លួនអោយបាពាក់ ជួនឡើងពាក់បាមុនក៏មាន ។ បើនៅក្នុងហ្វូងវាឡើងពាក់គេឯងដែលនៅជិតវា ។
- ក្នុងរយៈពេលនេះជាពេលដែលត្រូវដាក់បា ។ បើហួសរយៈពេលនេះ មាត់ស្បូននិងបិទជិតវិញ ការបង្កាត់ពូជពុំ បានទទួលលទ្ធផលល្អឡើយ ។ ២១ថ្ងៃក្រោយមក វានឹងរកឈ្មោលម្តងទៀត ហើយវានឹងបញ្ចេញអាការៈដូចខាងលើដែរ ។ ប៉ុន្តែ គួរតែកត់សំគាល់លក្ខណៈរបស់មេគោខ្លះ ហាក់បីដូចជាមិនបញ្ចេញសញ្ញាដូចខាងលើនេះ ឱ្យយើងដឹងទេ គឺបញ្ចេញតែលក្ខណៈ បន្តិចបន្តួច ជួនកាលស្ទើរតែគ្មានសោះ ។ គោប្រភេទនេះគួរតែសង្កេតអោយបានល្អិតល្អន់ ដើម្បីកុំឱ្យការដាក់បាកន្លងហួស ខាតពេល ឥតប្រយោជន៍ (មើលរូបភាព) ។



ជាធម្មតាមេគោក្រមុំអាចមានគភ៌ពី២ឆ្នាំកន្លះ ឬ ៣ឆ្នាំ អាស្រ័យយោងទៅតាមពូជរបស់វា ។ ពូជខ្លះធំធាត់លឿន វាក៏ឆាប់រកឈ្មោលដែរ ។

ការមានគភ៌របស់មេគោ មានរយៈពេល៩ខែកន្លះ ប៉ុន្តែអាចកើតមុន ១៥ថ្ងៃ ឬក្រោយពេល១៥ ថ្ងៃក៏មាន ដោយ យោងទៅលើសុខភាព ការថែទាំ ការផ្តល់ចំណី និងពូជរបស់វា ។

នៅប្រទេសកម្ពុជាយើង ជាធម្មតាមេគោមានកូន៣ ឬ៤ក្បាល ប៉ុន្តែបើវាមានការថែទាំបានត្រឹមត្រូវ សុខភាពល្អ វានិងអាចមានកូន ៥ ឬ៦ក្បាលក្នុងមួយជីវិតរបស់វា ។

ត្រូវជ្រើសរើសពេលវេលាសំរាប់ដាក់បា យកល្អមេគោត្រូវឱ្យមានគិភចាប់ពីខែវិច្ឆិកា ដល់ខែ មក
ពេលវេលាល្អបំផុត ពីព្រោះពេលនេះសំបូរស្មៅខ្ចី ងាយស្រួលរកចំណីឱ្យវាស៊ី ដើម្បីបំប៉ន់សុខភាពនៅពេលមានគិភ ។

✡ ការប៉ាន់ស្មានអាយុគោ ដោយសង្កេតលើបន្ទាស់ធ្មេញរបស់វា (មើលរូបខាងក្រោម)



អាយុ ១ ខែ



អាយុ ១២ ខែ



អាយុ ១៨ ខែ



អាយុ ២ ឆ្នាំ



អាយុ ៣ ឆ្នាំ



អាយុ ៤ ឆ្នាំ



អាយុ ៥ ឆ្នាំ



អាយុ ១០ ឆ្នាំ

យើងអាចប៉ាន់ស្មានអាយុគោបានច្បាស់ នៅពេលដែលមានអាយុ ១៨ខែឡើងទៅ ។ ដោយសំគាល់តាមរយៈការផ្លាស់ប្តូរធ្មេញរបស់វា ដែលមានចំនួន៨ នៅផ្នែកខាងមុខ និងជួរខាងក្រោម ។ គោមានធ្មេញពីរប្រភេទគឺ ធ្មេញទឹកដោះ និងធ្មេញ ចាស់(ធ្មេញបន្ទាស់) ។ ធ្មេញចាស់ ឬធ្មេញបន្ទាស់ ដុះជំនួសធ្មេញទឹកដោះម្តងពីរៗ ផ្តើមចេញពីចន្លោះកណ្តាល ទៅ ហើយមានទំហំធំជាងធ្មេញទឹកដោះ ។

- ពេលអាយុ ១៨ខែ វាមានធ្មេញចាស់ ២ ដុះនៅចន្លោះកណ្តាល ធ្មេញទឹកដោះ ៦
- ពេលអាយុ ២ឆ្នាំ វាមានធ្មេញចាស់ ៤ ដុះនៅចន្លោះកណ្តាល ធ្មេញទឹកដោះ ៤
- ពេលអាយុ ៣ឆ្នាំ វាមានធ្មេញចាស់ ៦ ដុះនៅចន្លោះកណ្តាល ធ្មេញទឹកដោះ ២
- ពេលអាយុ ៤ឆ្នាំ វាមានធ្មេញចាស ៨ ។

## III. ចំណី និង ការផ្តល់ចំណី

គោស៊ីស្មៅដែលដុះពីធម្មជាតិនៅជិតផ្ទះក្នុងរបងចំការ វាលស្រែ ។ ប៉ុន្តែយើងត្រូវផ្តល់ចំណីបន្ថែមខ្លះៗទៀត ឱ្យបានញឹកញាប់សំរាប់វាស៊ី ជាពិសេសនៅរដូវដែលពុំសូវមានស្មៅ ។ ពេលដាក់ចំណីអោយវាស៊ី យើងច្រើនប្រើប្រាស់ទ្រុង ដែលអាចដាក់ចំណីនៅក្នុងនោះបាន ។ ទ្រុងសំរាប់ដាក់ចំណីនេះមានទំហំទៅតាមចំនួនគោដែលយើងមាន ប៉ុន្តែទ្រុងនោះ ត្រូវមានបាតក្រោម ដើម្បីរក្សាចំណីមិនឱ្យនៅលើដីផ្ទាល់ និងមានរនាំងបាំងចំហៀងៗ ដើម្បីការពារកុំឱ្យខ្ចាត ចេញក្រៅទ្រុងពេលវាស៊ី ។ ទ្រុងទាំងនោះយើងអាចផលិតពីឬស្សីផ្តៅ រឺឈើទៅតាមលទ្ធភាពដែលយើងមាន ។ ទ្រុងដាក់ ចំណីមានប្រយោជន៍ណាស់ ដែលមិនធ្វើអោយចំណីរបស់វារាយប៉ាយ នៅពេលដែលយើងផ្តល់អោយវាមិន អាចកំពប់ មកដី ដែលនាំឱ្យវាជាន់លាយឡំ ជាមួយនឹងលាមកជាហេតុធ្វើឱ្យមានភាពកខ្វក់ ដែលនាំមកនូវជំងឺផ្សេងៗ ។ យើងត្រូវ សំអាតទ្រុងដាកចណេ ឱ្យបានរាល់ពេល ដែរ ។ ចំណីដែលអាចឱ្យគោស៊ីបាន មាន :
កន្ទក់ ដើមចេកហាន់ស្តើងៗ ដើមអំពៅ និងស្លឹក ស្លឹកកន្ទុំថេត ស្លឹកអង្កាដី ដើមពោត និងស្លឹក ស្លឹកឬស្សី ស្មៅដំរី (ដែលដាំសំរាប់ជាចំណី) ចំបើង .... ។ល ។ (មើលរូបភាព)



ក្នុងចំណោមចំណីខាងលើ ចំណីមួយចំនួនយើងអាចយកមកកែច្នៃ ដើម្បីអោយមានជីវជាតិនិងរសជាតិម

ដូចជា : ផ្កកចំបើង (straw Urea) និងដុំមីណេរ៉ាល់ (Mineral Block) . . . . សំរាប់ផ្តល់ឱ្យ

នៅរដូវមិនសូវសំបូរចំណី និង តំបន់ទឹកលិច ។

អំបិលក៏អាចជួយអោយស្មៅស្ងួតហើយមានរសជាតិឆ្ងាញ់ដែរ ( អំបិលលាយជាមួយទឹកស្រោចលើស្មៅស្ងួ

នេះជាមធ្យោបាយសំរាប់បង្កើនរសជាតិស្មៅស្ងួត សំរាប់ឱ្យសត្វចូលចិត្ត ។

ចំពោះការឱ្យចំណីទៅគោ យើងត្រូវផ្សេងផ្សំចំណីឱ្យបានសមស្រប ក្នុងការឱ្យចំណីគោតែមួយមុខក្នុងមួ

ថ្ងៃជា ការមិនល្អ **ឧទាហរណ៍ :** ថ្ងៃនេះអោយស៊ីចំបើងសុទ្ធ ថ្ងៃស្អែកឱ្យស៊ីស្មៅសុទ្ធ ហើយថ្ងៃស្អែកអោយស៊ីកន្ទក់ និ

ដើមចេកសុទ្ធ ។ ជៀសវាងការអោយចំណីសុទ្ធក្នុងមួយថ្ងៃ ត្រូវធ្វើយ៉ាងណាអោយចំណីទៅគោលាយឡំគ្នា រាល់ថ្ងៃមាន

- ចំណីមិនសូវមានគុណភាព : ចំបើង ស្មៅស្ងួត អំពៅ
- ចំណីសំបូរជាតិទឹក : ស្មៅស្រស់ ដើមចេក អំពៅ
- ចំណីបន្ថែម : ផ្កកចំបើង និងដុំមីណេរ៉ាល់ ( របៀបធ្វើនិងមានបង្ហាញបន្ទាប់ពីមេរៀននេះ)

គោស៊ីឆ្អែតមិនដើរស្វែងរកចំណីស៊ីទៀតទេ ពេលឆ្អែតវាឈប់ស៊ី មិនដូចមនុស្សទេ ។

✡ **ទឹក** : ទឹកជាកត្តាសំខាន់មួយដែរក្នុងការចិញ្ចឹម ។ គោត្រូវការផឹកទឹកយ៉ាងតិចមួយដងក្នុងមួយថ្ងៃ

គោ អាចផឹកទឹកតាមស្ទឹង បឹង អូរ ប្រឡាយ ឬស្រះ ដែលមានទឹកស្អាត នៅពេលដែលវាដើររកស៊ីចំណី

បើសិនជាទឹកកខ្វក់ យើងចាំបាច់ត្រូវយោងទឹកពីអណ្តូងដែលស្អាត សំរាប់ឱ្យគោផឹក ។ គោចូលចិត្តផឹកទឹកនៅពេល

តាមសេចក្តីត្រូវការ ដើម្បីរក្សានូវសុខភាពរបស់វា ។



## IV. ការថែទាំ និងការការពារ :

ដើម្បីអោយគោ ក្របីមានកំលាំងមាំមួននិងសុខភាពល្អ អាចបំរើការងារបានងាយស្រួល យើងត្រូវផ្តល់ចំណីអាហារដែលមានជីវជាតិ រសជាតិ និងទឹកស្អាតអោយបានគ្រប់គ្រាន់ ។

ការលាងសំអាតគោ ក្របី ក៏ជាជំនួយក្នុងការថែទាំអោយមានសុខភាពល្អដែរ ។ ក្នុងពេលដែលលាងសំអាតនេះ យើងត្រូវតែពិនិត្យអោយបានសព្វគ្រប់ទីកន្លែង ជាពិសេសក្រោមពោះ ជើង មាត់ រង្វង់ភ្នែក និងជុំវិញត្រចៀករបស់វា នូវបរាសិត ខាងក្រៅ (ចៃ ដង្កែ.....) ប្រុងប្រយ័ត្ននៅពេលដុះលាងនេះ ត្រូវបេះសំអាតនូវបរាសិតទាំងនេះ ។ បើមានបរាសិតច្រើនត្រូវ តាមភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីមានវិធានការកំចាត់បរាសិតទាំងនេះ ។



របៀបបោសសំអាតបរាសិតខាងក្រៅ

### ការថែទាំគោមេដើម :

ដើម្បីអោយគោមេមានកំលាំងមាំមួន និងសុខភាពល្អងាយស្រួលក្នុងការកើតកូន យើងត្រូវផ្តល់ចំណីអាហារដែលមាន ជីវជាតិគ្រប់គ្រាន់ ។ មុនពេលជិតកើតកូនមួយសប្តាហ៍ យើងត្រូវបង្ខាំងវាទុកក្នុងក្រោលដែលមានអនាម័យល្អសំរាប់ពេល បង្កើតកូន និងមានចំបើងស្ងួតសំរាប់ជាកំរាល ។

ត្រូវពិនិត្យមើលចុងដោះទាំងបួន ខ្លាចក្រែងមានស្ទះរន្ធដោះណាមួយ បើមានស្ទះត្រូវលាងទឹកក្តៅឧណ្ហៗ និងសាប៊ូ ក្នុងមួយថ្ងៃយ៉ាងតិច២ដង ។

### សញ្ញានៃការជិតកើតកូន :

- ពេលជិតកើតកូន ពោះរបស់មេគោរីកធំ
- ក្បាលដោះរីកធំ និងមានទឹកដោះហូរតិចៗចេញពីចុងដោះទាំងបួន
- ប្រដាប់បន្តពូជរីកធំ និងទឹករំអិលហូរចេញមក
- ក្នុងលក្ខណៈនេះមេគោត្រូវសំរាក ហើយយើងត្រូវពិនិត្យមើលឱ្យបាន ៣ទៅ៤ ដង ក្នុងមួយថ្ងៃ ក្រែងមានបញ្ហា អ្វីកើតឡើង ។

# ការចិញ្ចឹមជ្រូក
## *PIG RAISING*

ការចិញ្ចឹមជ្រូកជាផ្នែកមួយនៃវិជ្ជាកសិកម្មប្រជាកសិករខ្មែរយើងនិយមចិញ្ចឹមជ្រូក ជាលក្ខណៈគ្រួសារ ពេលបច្ចុប្បន្ននេះ យើងក៏សង្កេតឃើញមានជាលក្ខណៈឧស្សាហកម្មខ្លះៗ ដែរ ។ ដូច្នេះដើម្បីកែច្នៃការចិញ្ចឹមជ្រូកនេះ មានប្រសិទ្ធភាព និង រីកចំរើន ត្រូវយល់ដឹងនូវចំណុចសំខាន់ៗ ដូចតទៅ :

១- ការរៀបចំទីកន្លែង និងទ្រុង

២- ការជ្រើសរើសពូជ

៣- ការរៀបចំចំណី

៤- ការថែទាំ និង វិធានការការពារ

### ១-ការរៀបចំទីកន្លែង និងទ្រុង

ចំពោះការសង់ទ្រុង យើងអាចសង់បានច្រើនរបៀបដោយយោង ទៅតាមធនធានរបស់អ្នកចិញ្ចឹម គោ បំណងនៃ ការចិញ្ចឹមជាលក្ខណៈគ្រួសារ ឬជាបែបឧស្សាហកម្ម ។

- ការសង់ទ្រុង យើងត្រូវជ្រើសរើសទីកន្លែងល្អ មិនស្មុះស្មាប់ ឬជ្រាំទ ហើយត្រូវអោយនៅដាច់ឆ្ងាយ ពីទីប្រជុំជន និងផ្លូវគមនាគមន៍ ដើម្បីជៀសផុតពីការឆ្លងជំងឺផ្សេងៗ ។

- ការសង់ទ្រុង ត្រូវសង់បែរមុខឆ្ពោះទៅទិសខាងកើត ដើម្បីអោយពន្លឺព្រះអាទិត្យចាំង នៅពេលព្រឹក ហើយមានខ្យល់អាកាសល្អ អាចជួយសំងួតទ្រុងនិងសំលាប់មេរោគបានមួយចំនួនផង ម្យ៉ាងទៀតពន្លឺព្រះអាទិត្យនៅ ពេលព្រឹកអាចធ្វើឱ្យជ្រូកទទួលនូវជីវជាតិដេ (Vitamine D) ។

#### -ទំហំទ្រុង :

- ទទឹង ៣ម និងបណ្តោយ ៤ម សំរាប់ជ្រូកមេជើង ១ក្បាល
- ទទឹង ៣ម និងបណ្តោយ ៤ម សំរាប់ជ្រូកមេកូន ១ក្បាល
- ទទឹង ៣ម និងបណ្តោយ ៤ម សំរាប់ជ្រូកបា ១ក្បាល
- ទទឹង ៣ម និងបណ្តោយ ៤ម សំរាប់ជ្រូកសាច់ ៦ក្បាល

- បាតទ្រុងត្រូវក្រាលស៊ីម៉ង់ត៍ ( កុំឱ្យរលោងពេក ឬគគ្រើមពេក) ដើម្បីងាយស្រួលក្នុងការសំអាតទ្រុង និងមានអនាម័យល្អ ។ ការធ្វើអនាម័យទ្រុង ចាំបាច់ត្រូវអនុវត្តន៍ឱ្យបាន ៤ដងក្នុង១ឆ្នាំ ដោយប្រើកំបោរស ឬថ្នាំសំលាប់ មេរោគផ្សេងៗទៀត ។

ឧទាហរណ៍ ៖ របៀបប្រើកំបោរស ត្រូវបញ្ចេញជ្រូកមកក្រៅទ្រុង ទើបបាចកំបោរស ពាសពេញផ្ទៃទ្រុង បន្ទាប់មកស្រោចទឹកដើម្បីឱ្យកំបោរពុះក្នុងទ្រុង រួចទុកចោលរយៈពេលយ៉ាងតិចពី ១ទៅ២សប្តាហ៍ទើបលាងសំអាតចេញហើយបញ្ចូល ជ្រូកទៅក្នុងទ្រុងវិញ ។

- ចំពោះការប្រើប្រាស់ថ្នាំរំងាប់មេរោគផ្សេងទៀត ត្រូវអនុវត្តន៏ទៅតាមការណែនាំដែលមានសរសេរពីរបៀបប្រើប្រាស់នៅលើសំបកថ្នាំនីមួយៗ ។

ទ្រុងជ្រូកសងតាមរបៀបបច្ចេកទេស



## ២. ការជ្រើសរើសពូជ ៖

ក្នុងការចិញ្ចឹមជ្រូកដើម្បីអោយល្អប្រសើរហើយចំណាយទុនតិច នោះចាំបាច់ត្រូវតែជ្រើសរើសពូជ ព្រោះក៏ជាកត្តា សំខាន់មួយក្នុងការចិញ្ចឹមដែរ ។

នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ មានពូជជ្រូកខុស១គ្នាគឺ ៖ ពូជដែលមាននៅក្នុងស្រុក និងពូជជ្រូកដែលនាំចូលពីក្រៅ ។

ពូជជ្រូកដែលនៅក្នុងស្រុក សង្កេតឃើញមានដូចជា ៖

- ជ្រូកកណ្តុរ មានរាងល្អិត មាត់ស្រួច ត្រចៀកតូច ខ្លួនខ្លី ជើងខ្លី ។
- ជ្រូកហៃណាំ មានខ្នងបាក់ ច្រមុះរាងរចុងបន្តិច ត្រចៀកឈរុញទៅមុខ ពណ៌ខ្មៅ ។

## - ពូជជ្រូកនាំចូលពីក្រៅ

- យ៉កស្សៀរ ឬឡាជីវ៉ាយស៍ (Yorkshire or Large White) ច្រមុះរាងវែងបន្តិច ត្រចៀ
ឈរត្រង់ ដងខ្លួនវែង ជើងមាំ ពណ៌ស ។

| | |
|---|---|
| រូបជ្រូក យ៉កស្សៀរ ឬ ឡាជីវ៉ាយ |  |

- ឡែនរ៉េស៍ (Landrace) ច្រមុះវែង ត្រចៀកធំបាក់ទៅមុខ ដងខ្លួនវែង ជើងមាំ ពណ៌ស ។

| | |
|---|---|
| រូបជ្រូក ឡែនរ៉េស៍ |  |

- ឌុយរ៉ុក (Duroc) ច្រមុះវែងបន្តិច ត្រចៀករាងតូចជាងឡែនរ៉េស៍បាក់ទៅមុខ ដងខ្លួនវែ
ជើងទាំង បួនមាំ ពណ៌ត្នោត ។

| | |
|---|---|
| រូបជ្រូក ឌុយរ៉ុក |  |

នាពេលបច្ចុប្បន្ននេះ មានពូជជ្រូកក្លាយមកពីការបង្កាត់រវាងពូជជ្រូកបរទេស និងពូជជ្រូកក្នុងស្រុកដែលយើងនិយមហៅថា ពូជកូនកាត់ ។ ចំពោះពូជជ្រូកក្នុងស្រុក បរទេស និងកូនកាត់ យើងសង្កេតឃើញថា ពូជបរទេស និងពូជកូនកាត់ មានការលូតលាស់រហ័សជាងពូជក្នុងស្រុក ។

## ✡ ការជ្រើសរើសសំរាប់ទុកធ្វើមេ និង បា :

- មេពូជ : ត្រូវជ្រើសរើសយកមេដែលមានដោះ៦គូរ យ៉ាងតិចឡើងទៅ ត្រង់ជួរគ្នា គ្មានដោះខ្វាក់ ។ ចំពោះកាយលក្ខណៈ ភ្លៅមាំ ត្រគៀករាងសាយ (ចូលមើលរូបភាព) ក្នុងករណីដែលយើងចង់ទុកធ្វើជាមេពូជ គួរដឹងពីប្រវត្តិអោយបានច្បាស់ យកល្អគឺ យកតែមេសាយកូនល្អ គ្មានជំងឺរ៉ាំរ៉ៃ ឬជំងឺឆ្លងដល់កូន ហើយគួរតែជ្រើសរើសកូនដែលកើត នៅសារទី២ព្រោះវាមានការលូតលាស់ធំធាត់ល្អ ។



- បាពូជ : យកពីមេដែលសាយកូនល្អ គ្មានជំងឺរ៉ាំរ៉ៃ ឬជំងឺឆ្លង ជ្រើសរើសកូនកើតលើកទី២ដែរ ដែលមានកាយ លក្ខណៈដូចជា ស្មាទូលាយ ដងខ្លួនវែង ពោះរាងវៀវ ពងស្វាសប៉ុនគ្នា គ្មានអ៊ែកនី (Hernia) គំពងទក (ចូរមើលរូប) ។



## ៣. ការរៀបចំចំណី :

ដើម្បីអោយការចិញ្ចឹមទទួលបានលទ្ធផលល្អ យើងគួររៀបចំចំណីសំរាប់ផ្តល់យ៉ាងណាឱ្យមានសមាស ដូចជា : កន្ទក់ កញ្ចុំងអង្ករ ពោត កាកសណ្តែក សំបកខ្យង ត្រី អំបិល បន្លែស្រស់ ដែលសំបូរជាតិប្រូតេ វីតាមីន រ៉ែធាតុ..

ចំពោះការផ្សំចំណីនេះមានច្រើនរបៀប ទៅតាមការប្រើប្រាស់របស់ប្រទេសផ្សេងៗ និងពេលខ្លះទៀ តាមចំណីដែលមានជាក់ស្តែងក្នុងស្រុក ។ ខាងក្រោមនេះជាតារាងនៃអាហារផ្សំ :

| ប្រភេទជ្រូក | បរិមាណចំណីសំរាប់ជ្រូក ១ក្បាល ក្នុង ១ថ្ងៃ គិតជា " គក្រ " | | | | | | |
|---|---|---|---|---|---|---|---|
| មេជ្រូកផើមរីមេទំនេរ | កញ្ចុំងអង្ករ | កន្ទក់ | ពោត | កាកសណ្តែក | ម្សៅត្រី | ម្សៅខ្យង | អំបិ |
| ជ្រូកបា | ០,៣៥០ | ០,៨៧៥ | ១,៣៥៥ | ០,៥២៥ | ០,៥២៥ | ០,០៧០ | ០,០៥ |
| ជ្រូកសាច់ | ០,៣៥០ | ០,៨៧៥ | ១,២២៥ | ០,៥២៥ | ០,៥២៥ | ០,០៧០ | ០,០៥ |
| កូនជ្រូកមិនទាន់ផ្តាច់ដោះ | ០,៣៥០ | ១,២០០ | ១,២៧៨ | ០,៥២៥ | ០,៥២៥ | ០,០៧០ | ០,០៥ |
| និងកូនជ្រូកផ្តាច់ដោះ | ០,២៥០ | ០,៥០០ | ០,៧៥០ | ០,៥០០ | ០,៥០០ | ០,០៥០ | ០,០៣ |

## ១. ការថែទាំ

ការចិញ្ចឹមជ្រូកនៅក្នុងប្រទេសកម្ពុជាមានពីររបៀប គឺ ការចិញ្ចឹមលែងជាសេរី . និងការចិញ្ចឹមដាក់ ឬចង ។

**ការចិញ្ចឹមលែងជាសេរី** គឺយើងត្រូវដាក់បាយឱ្យស៊ី ក្រៅពីនេះសត្វអាចដើររកចំណីផ្សេងទៀ បំពេញតាមបំណងរបស់ខ្លួនដែលត្រូវការ ។ ការលែងសត្វអោយដើរស៊ីសេរី វាអាចបំពេញនូវអ្វីដែលមានការខ្វះ ក្នុងខ្លួនវា ប៉ុន្តែវា ក៏ជាវិបត្តិមួយពិបាកអោយយើងធ្វើការតាមដានសុខភាពរបស់សត្វ និង ការថែទាំវាហើយពិបា នេះ គឺការលែងសត្វអោយដើរសេរី វាអាចអោយសត្វកើតជំងឺឆ្លងបាន ដូចជាជំងឺបរាសិត និងជំងឺឆ្លងរាតត្បាតផ្សេង

**ការចិញ្ចឹមដាក់ទ្រុង ឬចង** យើងតែងតែផ្តត់ផ្គង់ចំណីអាហារនិងទឹកអោយបានទៀង ពេលវេលា ការចិញ្ចឹមរបៀបនេះ យើងអាចថែទាំធ្វើអនាម័យទៅលើជ្រូក ទ្រុង ស្នូកចំណី ស្នូកទឹក ....... ។ ចំពោះទឹកត្រូវផ្តល់ជាប្រចាំ ព្រោះទឹកមានសារៈសំខាន់ណាស់សំរាប់ជីវិតកង្វះខាតជាតិទឹកអាចធ្វើឱ្យកំដៅសត្វកើនឡើ ការចិញ្ចឹមដាក់ទ្រុង ឬចង វាងាយស្រួលក្នុងការតាមដានសុខភាពរបស់សត្វ ។



ជ្រូកចិញ្ចឹមលែងជាសេរី



ជ្រូកចិញ្ចឹមដាក់ទ្រុង

## ✡ ការថែទាំជ្រូកសាច់

ដើម្បីថែទាំជ្រូកសាច់អោយបានល្អ យើងត្រូវ

- ជ្រើសរើសកូនជ្រូកដែលមានសុខភាពល្អមកចិញ្ចឹម
- ត្រូវធ្វើការទំលាក់បរាសិត អោយបានចំនួន ២ ទៅ ៤ដងក្នុង ១ឆ្នាំ
- ត្រូវដាក់ជ្រូកតាមក្រុម តាមអាយុ និងតាមទំងន់ប្រហាក់ប្រហែលគ្នា ក្នុងករណីចង់ចិញ្ចឹមច្រើនក្បាល
- ត្រូវពិនិត្យតាមដានសុខភាពនិងការលូតលាស់របស់ជ្រូកជារៀងរាល់ថ្ងៃ ។ ការតាមដានទំងន់នៃការលូត-លាស់របស់វា យើងអនុវត្តនីក្នុង ១ខែម្តង តាមរូបមន្តខាងក្រោម

A = ទំងន់ជ្រូកសរុប (គិតជាគក្រ)

X = រង្វាស់ប្រវែងទំហំទ្រូង (គិតជា សង្ទីម៉ែត្រ)

Y = រង្វាស់ប្រវែងដងខ្លួន (គិតជា សង្ទីម៉ែត្រ)




$$A(kg) = \frac{X^2Y}{14400}$$

## ✡ ការថែទាំជ្រូកបា

ជ្រូកបាជាទូទៅអាចបង្កាត់បានចាប់ពីអាយុ ៧ខែឡើងទៅ ។ ការថែទាំជ្រូកបាក្រោយពីបានជ្រើសពូជនិងកាយលក្ខណៈ ដូចបានរៀបរាប់ខាងដើម យើងត្រូវចាប់អារម្មណ៍ទៅលើចំនុចសំខាន់មួយចំនួនដូចតទៅ

-ត្រូវទំលាក់បរាសិតឱ្យបានចំនួន ២ ទៅ៤ដងក្នុងមួយឆ្នាំ ។

-ការផ្តល់ចំណីត្រូវផ្តល់ឱ្យស៊ីចំនួន ២ទៅ២,៥០ គក្រ ក្នុងមួយថ្ងៃ ចៀសវាងនូវការធាត់ពេកដែលបណ្តាលឱ្យពាក់ មេមិនបានច្រើន ។

- នៅពេលពុំសូវមានមេពាក់ យើងត្រូវហ្វឹកហាត់អោយមានចលនា ដើម្បីកុំអោយវាធាត់ពេក ។
- ជ្រូកបាអាចពាក់មេបាន ៨ក្បាល ក្នុង១ខែ (គិតជាមធ្យម) ។

## ✡ ការថែទាំជ្រូកមេ

ជាទូទៅជ្រូកមេចាប់ពេញវ័យពីអាយុ ៦ ឬ៧ខែ ឡើងទៅ វាអាស្រ័យទៅតាមពូជ ។ វដ្តនៃការរកឈ្មោល របស់ ជ្រូកមេមានរៀងរាល់២១ថ្ងៃម្តង ។

ចំពោះមេក្មេង (មេដំបូង) គួរតែអោយវាបង្កាត់នៅពេលដែលវារកឈ្មោលជាលើកទី២ ព្រោះយើង ទទួលបាន កូនជ្រូកនៅសំបុកដំបូងថ្លោសល្អ ។

**ការរៀបចំបង្កាត់:** យើងត្រូវកត់សំគាល់ពីសញ្ញារកឈ្មោលមួយចំនួនរបស់មេជ្រូក ដើម្បីឱ្យការបង្កាត់ ចំពេលល្អ ។ សញ្ញានៃការរកឈ្មោលរបស់មេ មានរយៈពេលពី២ ទៅ ៣ថ្ងៃ ចំពោះមេចាស់ អាចមានពី ៣ទៅ ចំពោះមេក្មេង( ដូច្នេះ ចំពោះការដាក់បា មេចាស់ត្រូវពាក់នៅចន្លោះថ្ងៃទី ២ទៅ ៣ មេក្មេងឱ្យពាក់នៅចន្លោះថ្ងៃទី៣ ទើបល្អ) ។

### សញ្ញានៃការរកឈ្មោល

- ស៊ីចំណីធម្មតា ឬតិច ឬមិនស៊ី
- ប្រដាប់បន្តពូជរីកធំ ឡើងពណ៌ក្រហម មានហៀរទឹករំអិល
- បើនៅក្នុងហ្វូង វាឡើងពាក់គេឯង
- មិនសូវដេក មានភាពវង្វេងវៃ ត្រចៀកបះត្រង់
- យើងយកដៃសង្កត់លើត្រគៀក វានៅស្ងៀម
- ចំពោះមេចាស់ ពិបាកសង្កេតលើប្រដាប់បន្តពូជ

## ✡ ការថែទាំជ្រូកមេដើម

ក្រោយការបង្កាត់រយៈពេល២១ថ្ងៃឡើងទៅ បើមេជ្រូកនោះមិនមានបង្ហាញនូវសញ្ញារកឈ្មោលឡើ យើងអាចសន្និដ្ឋានថាមេនោះដើម ។ ផ្ទុយទៅវិញបើសិនជាវាបង្ហាញនៃការរកឈ្មោលឡើងវិញទៀត សន្មត់ថាក លើកមុនពុំមានកំណើតកូនទេ( មិនជាប់)ដូច្នេះត្រូវបង្កាត់ម្តងទៀត ។

ក្រោយការបង្កាត់មេជ្រូករួច យើងត្រូវពិនិត្យលៃលកចំណីដែលយើងផ្តល់ឱ្យវា ដើម្បីជៀសវាងកុំឱ្យ នេះធាត់ពេក ឬស្គមពេក ព្រោះមេជ្រូកដែលធាត់ច្រើនកូនថ្លោស ដែលជាផលវិបាកនៅពេលជ្រូកកើតកូន ហើយ ដែលធាត់ពេក គឺមិនសូវសំបូរទឹកដោះឡើយ ។ ចំពោះមេជ្រូកស្គមពេក កូនកើតខ្សោយ ជាហេតុនាំឱ្យកូនជ្រ សុខភាពល្អ ហើយជួនកាលកូនអាចងាប់ក្នុងពោះដោយមេខ្សោយពេក ឬក៏គ្មានកំលាំងនឹងប្រឹងបង្កើតកូន ។ រយៈ ដែលយើង ពិនិត្យមើលការផ្តល់ចំណី កុំ ឱ្យមេធាត់ពេក ឬស្គមពេក គឺចាប់ពីបង្កាត់រហូតដល់ដើមបាន៩៥ថ្ងៃ ។ *ពេលផ្តើម ៩៥ ថ្ងៃឡើងទៅ ត្រូវបន្ថែមវាឱ្យច្រើន ជាងមុនបន្តិចរហូតដល់ពេលកើតកូន ទើបយើងបន្ថយមកវិញបន្តិ*

នៅថ្ងៃកើតកូន យើងត្រូវឱ្យមេជ្រូកស៊ីតែបន្តិចទេ ព្រោះជួនកាលមេខ្លះ នៅថ្ងៃកើតកូនវាមិនស៊ីចំណីលុះបានមួយថ្ងៃ យើងត្រូវបន្ថែមបន្តិច បើមេស៊ីអស់ ស្អែកឡើងយើងបន្ថែមបន្តិចទៀត យើងឱ្យវាស៊ីល្មមគ្រប់គ្រាន់ចាប់ពី៤ថ្ងៃ ទៅ១អាទិត្យ ចាប់ពី ២អាទិត្យឡើងទៅ យើងត្រូវបន្ថែមឱ្យវាស៊ីឆ្អែតគ្រប់គ្រាន់ ដើម្បីកុំឱ្យមេខ្វះទឹកដោះ ។

## ✡ ការថែទាំជ្រូកមេពេលកើតកូន

ជាធម្មតាមេជ្រូកតែងតែផើមរយៈពេល ១១៤ ទៅ ១១៦ថ្ងៃ យើងអាចគិតយ៉ាងស្រួល គឺ៣ខែ ៣អាទិត្យ ៣ថ្ងៃ ដើម្បី ត្រៀមលក្ខណៈនៅពេលកើតកូនបានល្អ ដាច់ខាតយើងត្រូវដឹងនូវពេលវេលាដែលត្រូវកើតកូន ។

មុនពេលកើតកូនមួយសប្តាហ៍ យើងត្រូវលាងសំអាតមើលជ្រូកអោយស្អាត ត្រូវមានទ្រុងទុកសំរាប់អោយវាកើតកូន ត្រូវត្រៀមចំបើងស្ងួតសំរាប់ជាកំរាល និងកញ្ចោ ឬជាលតូចល្មម សំរាប់ដាក់កូននៅពេលកើត ។

ក្នុងរយៈពេលនេះ យើងត្រូវពិនិត្យតាមដានអោយបានច្បាស់លាស់ ត្រូវផ្តល់បន្ថែមដូចជាត្រកួនស្រស់ជាញឹកញាប់ផ្សំនឹង ចំណីដែលយើងអោយវា ដើម្បីការពារកុំអោយជ្រូកទល់លាមក ។

នៅថ្ងៃកើតកូនមកដល់ យើងអាចសង្កេតឃើញដោយមេជ្រូកឆ្លេឆ្លា មេជ្រូកកកេរនេះកកេរនោះ ដែលខ្មែរហៅថា ជ្រូកកាច់សំបុក ដូច្នេះយើងត្រូវក្រាលចំបើងស្ងួតអោយវាសំរាប់ធ្វើជាកំរាលនៅពេលកូនកើតនៅដោះជួរទីមួយយើងឃើញមានស្រក់ទឹកដោះ មុនពេលចាប់ផ្តើមកើតកូន ពី៣០ទៅ១ម៉ោង (ចំពោះមេជ្រូកខ្លះ) ។ កាលណាយើងឃើញលក្ខណៈមេដូច្នេះ យើងត្រូវត្រៀមឧបករណ៍ប្រើប្រាស់មួយចំនួនសំរាប់ជួយវាដូចជា ក្រណាត់ស្អាតសំរាប់ជូតឱ្យកូនជ្រូកនៅពេលដែលកើត តំបៀតសំរាប់ឃាត់ឈាមនៅពេលកាត់ផ្ចិត កន្ត្រៃសំរាប់កាត់ផ្ចិត អំបោះសំរាប់ចងផ្ចិត អាល់កុលនិងអ៊ីយ៉ូតសំរាប់រំងាប់មេរោគ កន្ត្រៃកាត់ធ្មេញកូនជ្រូក ឬកន្ត្រៃកាត់ក្រចកក៏បានដែរ ។ សំភារៈទាំងអស់នេះមុនយកមកប្រើត្រូវរំងាប់មេរោគជាមុនសិន ។



## ✡ របៀបជួយបង្កើតកូនជ្រូក :

ពេលមេប្រឹងខ្លាំងហើយមិនឃើញកើតកូនចេញមក យើងអាចជួយសង្គ្រោះមេជ្រូកបាន ដោយប្រើដៃលាបប្រេង ដូង ឬប្រេងវ៉ាស៊ីលីន លូកចូលតាមទ្វារបន្តពូជ ។ ពេលលូកចូលទៅ យើងត្រូវស្ទាបអោយដឹងថា តើកូនជ្រូកនេះ កើតមកមានទម្រង់សមស្របដែរឺទេ បើកើតទទឹងខ្លួន យើងត្រូវរុញកូនជ្រូកដោយថ្នមៗចូលទៅក្នុងវិញរួចទើប បង្វិលវាឱ្យត្រូវលក្ខណៈទើបអាចចេញមកក្រៅតាមកម្លាំងដែលមេជួយប្រឹង ។ កូនជ្រូកដែលទើបនឹងកើតចេញ មកត្រូវប្រញាប់ជូតស្លេស្មចេញពីច្រមុះ និង មាត់វាដោយយួរជើងខាងក្រោយទាំងពីរឡើងលើ រលាស់ធ្លាក់ស្លេស្ម ដើម្បីការពារកុំអោយឈ្លក់ ។ ឯដងខ្លួនរបស់វាមិនចាំបាច់ជូតទេ ព្រោះស្រោមស្បែកដែលរុំព័ទ្ធជុំវិញវាអាចជួយ ការពារមេរោគបានមួយចំនួន ។ ត្រូវយកតំបៀតឃាត់ឈាមគៀបទងផ្ចិតចំងាយ ២ស.ម ពីគល់ផ្ចិតរួចអំបោះដែលត្រាំអាល់កុល ឬសូលុយស្យុងអ៊ីយ៉ូត ទើបប្រើកន្ត្រៃស្អាតកាត់ចំងាយពីគល់ផ្ចិតប្រវែង ៣ស.ម រួចជ្រលក់ផ្ចិតនោះ ទៅក្នុងអាល់កុល ឬសូលុយស្យុងអ៊ីយ៉ូត ។ យើងធ្វើបៀបនេះរហូតដល់កើតអស់ ។ ពេលកើតអស់ហើយយើងត្រូវចាប់ផ្តើម កាត់ធ្មេញកូនជ្រូកនេះចេញ ដើម្បីការពារកុំអោយវាខាំដោះមេវា បណ្តាលឱ្យមានរបួស ។

ការកាត់ធ្មេញនេះ យើងត្រូវកាត់ដោយមិនអោយធ្មេញបែក ឬកៀកអញ្ចាញធ្មេញពេកទេ យើងត្រូវការលើគល់ ធ្មេញបន្តិចដោយមិនត្រូវឱ្យធ្មេញនេះមុតឡើយ ។ ពេលកើតកូនអស់ហើយ រយៈពេលប្រមាណកន្លះម៉ោងមួយម៉ោងក្រោយមកយើងត្រូវឱ្យកូនជ្រូកបៅដោះមេ បើកូនណាខ្សោយ ឬស្គម បៅដោះផ្នែកដើមទ្រូង ឯកូនសុខភាពល្អបៅ ដោះផ្នែកពោះ ។

## ✡ ការថែនាំកូនជ្រូកក្រោយពេលផ្តាច់ដោះ :.

ជាទូទៅកូនជ្រូកផ្តាច់ដោះក្នុងកំឡុងអាយុ ៤៥ថ្ងៃ ដែលមានទំងន់ ៧គក្រ ជាមធ្យម ។ កូនជ្រូកមានលក្ខណៈពណ៌ សំបុរអាស្រ័យទៅតាមពូជរបស់វា ។

ដើម្បីជ្រើសរើសកូនជ្រូក និង ថែទាំឱ្យបានល្អ ត្រូវអនុវត្តទៅតាមវិធានការសំខាន់ៗ :

- ទិញកូនជ្រូកដែលមានទំងន់មធ្យម ៧គក្រ

-ត្រូវដឹកនាំកូនជ្រូកឱ្យបានសមស្របទៅតាមលក្ខណៈនៃជុច ទ្រុង និង បន្ថយចំងាយក្នុងការទិញកូនដូចជាទិញ នៅក្នុងភូមិឃុំជិតៗមិនពិបាកក្នុងការដឹកនាំ ។

-ត្រូវទិញកូនជ្រូកដែលដឹងពីប្រវត្តិមេ និង បា ដែលគ្មានជំងឺ

-ត្រូវធ្វើការទំលាក់បរាសិតខាងក្នុង និង ព្យាបាលបរាសិតខាងក្រៅនៃកូនជ្រូក

-ជំរកកូនជ្រូកដែលទើបនិងផ្តាច់ដោះថ្មីៗ ត្រូវដាក់ក្នុងទ្រុង

-ត្រូវមានស្នូកសំរាប់ដាក់ចំណី និង ទឹកផ្តល់ឱ្យកូនជ្រូកឱ្យបានគ្រប់គ្រាន់ ហើយស្នូកទាំងនេះត្រូវលាងសំអាតជាប្រចាំ ។

-ត្រូវដាក់ចំណីអាហារឱ្យកូនជ្រូកចំនួន ៦ពេល ប្រសើរជាង ៣ពេល ក្នុងមួយថ្ងៃ

-ក្រោយពីអាយុ ៥ ទៅ ៦សប្តាហ៍ យើងត្រូវផ្តល់ចំណីដោយដាក់ឱ្យស៊ី ១ថ្ងៃ ៣ពេល និង ចំណីបំប៉នត្រូវមានជាតិប្រូតេអ៊ីន, ជីវជាតិ, ជាតិរ៉ែ ( មើលរូបភាពចំណី) ។

រូបភាព ចំណីមានជីវជាតិ រ៉ែធាតុប្រូតេអ៊ីន



-ការរំលាយអាហារអាស្រ័យលើអាយុនៅពេលផ្តាច់ដោះ ។ ម៉្យាងទៀតការទំលាប់អោយស៊ីកាកសំណល់ផ្ទះបាយអាចកើតមាន២០ថ្ងៃ ក្រោយពេលផ្តាច់ដោះ ដូច្នេះក្នុងរយៈពេលនេះ ត្រូវផ្តល់អាហារដែលអាចរលាយបានស្រួល ។ គេ អាចចំអិនអង្ករ ដើម្បីអោយជាតិម្សៅរលាយបានងាយ ជាតិសែលុលឡូស (សរសៃ) នៃបន្លែផ្សេងៗងាយស្រួលក្នុងការរំលាយអាហារជាតិប្រូតេអ៊ីន និង ជាតិខ្លាញ់ក្នុងម្សៅ ត្រីក៏ងាយស្រួលក្នុងការរំលាយអាហារដែរ ។

-គេត្រូវចាប់ផ្តើមអោយកូនជ្រូកស៊ីជាតិអាមីដុង (ជាតិម្សៅ អង្ករ ពោត) តាំងពីវានៅបៅដោះ គឺជាវិធីមួយដែលជួយជំរុញឱ្យអាហារមានជាតិរឹងងាយស្រួលក្នុងការរំលាយ ។

-ការខ្វះជីវជាតិផ្តល់ថាមពលក្នុងចំណីអាហារ គឺជាកត្តាដែលធ្វើអោយរាំងស្ទះដល់ការលូតលាស់របស់កូនជ្រូក ។

-ការបង្រៀនអោយកូនជ្រូករៀនស៊ីចំណីអាហាររឹង ដោយផ្លាស់ប្តូរចំណីអាហារដែលមានជីវជាតិ ហើយងាយស្រួល ក្នុងការរំលាយអាហារ ត្រូវចាប់ផ្តើមអោយបានឆាប់ជាទីបំផុត ។

- ការយល់ដឹងទាំងនេះមានលក្ខណៈទូលំទូលាយដល់ប្រជាកសិករដែលចិញ្ចឹមជ្រូកយកកូន ។

-ត្រូវដាក់ទឹកតាមតំរូវការរបស់វា (ទំលាប់អោយផឹកទឹកបានច្រើន) ។

-ក្រោយរយៈពេលផ្តាច់ ៥ ទៅ ៦សប្តាហ៍ កូនជ្រូកអាចរួចផុតពីគ្រោះថ្នាក់ ហើយគេអាចចិញ្ចឹមវាតាមទំលាប់ (ការដាក់ទ្រុងប្រសើរជាង) ។

-ត្រូវទិញកូនជ្រូកពីរមកចិញ្ចឹមដែលមានទំងន់ប្រហាក់ប្រហែលគ្នា ប្រសើរទិញតែមួយមកចិញ្ចឹម ។

✡**វិធានការការពារជំងឺ** : គឺជាមធ្យោបាយចំបង សំរាប់ការចិញ្ចឹម ព្រោះនៅពេលដែលសត្វឈឺ វាអាចចម្លងទៅសត្វដ៏ទៃក្នុងហ្វូងបានយ៉ាងឆាប់រហ័ស និង បណ្តោយឱ្យស្លាប់ចំនួនច្រើន ឬអស់គ្មានសល់ អាស្រ័យទៅតាមប្រភេទជំងឺនីមួយៗ ដូចនេះត្រូវមានវិធានការការពារ គឺត្រូវទិញសត្វពីកន្លែងដែលគ្មានជំងឺ បំបែកសត្វឈឺចេញពីហ្វូង ចាក់ថ្នាំការពារជំងឺគ្រប់ប្រភេទ និង ទំលាក់បរាសិត ។

# ការចិញ្ចឹមមាន់

## *Chickem Raising*

## I . សេចក្តីផ្តើម :

មាន់ជាសត្វស្លាបម៉្យាងដែលមនុស្សយើងចូលចិត្តចិញ្ចឹម ព្រោះវាផ្តល់សាច់ និង ស៊ុតជាអាហារ និ
លទ្ធភាព ជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារ ជាពិសេសប្រជាកសិករយើងនៅតាមជនបទ ។

ការចិញ្ចឹមមាន់មិនជាការពិបាកទេ បើសិនជាការចិញ្ចឹមនោះត្រូវបានយកចិត្តទុកដាក់ល្អ ។ មុនពេល
មាន់យើងគួរ តែសិក្សាស្រាវជ្រាវឱ្យបានល្អិតល្អន់ជាមុនសិន នូវបច្ចេកទេសចិញ្ចឹម ធ្វើយ៉ាងនេះទើបការចិញ្ចឹមរប
នឹងទទួលបានផលល្អ ថែមទាំងមានការសន្សំសំចៃ និង ចំណេញពេលវេលា និង ថវិកាទៀតផង ។



## II . ផលប្រយោជន៍នៃការចិញ្ចឹមមាន់

ការចិញ្ចឹមមាន់អាចផ្តល់ផលប្រយោជន៍ដូចជា :

-វាផ្តល់ស៊ុត និង សាច់ សំរាប់ធ្វើជាអាហារ

-លាមកសំរាប់ធ្វើជាជីដាក់ដំណាំផ្សេងៗ

-រោម ស្លាប សំរាប់ធ្វើជាឧបករណ៍ប្រើប្រាស់ដូចជា អំបោស

វាអាចផ្តល់ផលប្រយោជន៍ឆាប់រហ័ស ដោយប្រើរយៈពេលខ្លី ដែលអាចធ្វើឱ្យសេដ្ឋកិច្ចគ្រួសារធូរ
មួយកំរិត ។




ដើម្បីឈានទៅដល់គោលបំណង និង ទទួលបានសារៈប្រយោជន៍ខាងលើ គប្បីស្វែងយល់ និង ដឹងពីកត្តាសំខាន់ៗ ក្នុងការចិញ្ចឹម ព្រោះកត្តាទាំងនេះមានសារៈសំខាន់ណាស់ មិនអាចខ្វះកត្តាណាមួយបានឡើយ ។ កត្តាទាំងអស់នោះមាន ដូចតទៅ :

១- ការជ្រើសរើសពូជ

២- ការរៀបចំទ្រុង

៣- ចំណីអាហារនិង ទឹក

៤- របៀបថែទាំ និង វិធានការការពារ

**១.ការជ្រើសរើសពូជ :** ពូជមាន់មាន២យ៉ាងគឺ ពូជមាន់មកពីបរទេស និង ពូជនៅក្នុងស្រុក

**ក. ពូជមាន់មកពីបរទេស :**

-មិនសូវធន់នឹងជំងឺ

-ពិបាកបន្សាំទៅនឹងល័ក្ខខ័ណ្ឌអាកាសធាតុ

-មិនអាចចិញ្ចឹមវាដោយអោយដើររកស៊ីចំណីដោយខ្លួនឯងបានទេ

-ត្រូវមានទ្រង់ និង ថែទាំតាមបច្ចេកទេសត្រឹមត្រូវ

-ត្រូវការចំណី និង ទឹកគ្រប់គ្រាន់

-លូតលាស់រហ័ស ( ចំពោះមាន់ផ្តល់សាច់)

-ផ្តល់ពងបានច្រើន ( ចំពោះមាន់ផ្តល់ពង)

-ត្រូវមានអនាម័យទ្រុង និង ទីកន្លែងចិញ្ចឹម

ពូជបរទេសដែលមានចិញ្ចឹមក្នុងស្រុកយើងសព្វថ្ងៃនេះ ដូចជាពូជ : ឡឺហ្គន (Leghorn) ពូជអ៊ីសាប្រោ (Isabrown) ហៃប្រ៊ីដ ប្រ៊យល័រ (Hybird broiler) . . . . ។ល ។



មាន់ពូជបរទេស



### ខ. ពូជក្នុងស្រុក

ពូជមាន់ក្នុងស្រុកមានលក្ខណៈសំគាល់របស់វាគឺ

-ងាយចិញ្ចឹមជាលក្ខណៈគ្រួសារ

-ធន់នឹងជម្ងឺ

-ងាយស្រួលក្នុងការបន្សាំអាកាសធាតុ

-អាចចិញ្ចឹមលែង ហើយវាដើររកស៊ីដោយខ្លួនឯង

-ចេះក្រាបភ្ញាស់ពង និង បណ្ដើរកូន ការពារសត្រូវរបស់វាបានមួយចំនួន

-លូតលាស់យឺត ផ្ដល់ពងតិច

ពូជមាន់ក្នុងស្រុកគេសង្កេតឃើញមាន : ពូជមាន់សំពៅ ពូជមាន់ថៃ ពូជមាន់សំឡី ពូជមាន់ស្ល ពូជមាន់ក្រញ៉ាស់ ពូជមាន់កណ្ដួង ពូជមាន់ប្រជល់ ........ ។ល ។ ពូជមាន់ទាំងនេះប្រជាកសិករយើងកំពុងនិយមចិញ្ចឹ ច្រើននៅតាមជនបទនាពេលបច្ចុប្បន្ន ។

✡ **ការជ្រើសរើសមាន់មកចិញ្ចឹម :** ជាកត្តាសំខាន់ណាស់ដើម្បីឱ្យការចិញ្ចឹមនោះទទួលលទ្ធ ល្អគេអាចជ្រើសរើសកូនមាន់ មាន់ជំទង់ ឬមេមាន់ មកចិញ្ចឹម ។

✡ **ការជ្រើសរើសកូនមាន់ :**

-មានសុខភាពល្អ រហ័សរហួន

-មានរោមស្ងួតត្រសុះ ចំពុះបិទ ភ្នែករហ័សថ្លា ស្បែកមិនជ្រីវជ្រួញ គ្មានស្លាកស្នាម ឈរត្រង់

-ផ្ចិតនៅជុំវិញគូទ ត្រូវឱ្យស្ងួតស្អាត (គ្មានជាប់អាចម៍ភាគ)

-យកកូនមាន់ដែលធំ ហើយជ្រើសពីមេដែលមាឌធំ

## ✡ ការជ្រើសរើសមាន់ជំនង់ និងមេមាន់

ត្រូវជ្រើសរើសយកមាន់ដែលមិនធាត់ពេក ឬស្គមពេក

-ត្រូវមានជំពុះបិទជិត

-ភ្នែកថ្លា

-សិរមានពណ៌ក្រហម

-ជើង : ស្បែកជើងមិនជ្រីវជ្រួញ ភ្លឺរលោង

-គូទទូលាយ ចំពោះមេមាន់មានលក្ខណៈដូចតទៅ : ចន្លោះឆ្អឹងគូទ និង ទ្រូងទូលាយ (ដាក់ម្រាមដៃបីចុះ) ផុយទៅវិញ មាន់មិនសូវពង បើឆ្អឹងគូទចង្អៀត ។

-គប្បីជ្រើសរើស ឬទុកមេមាន់ណាដែលមានពងច្រើន (លើសពី១០ពង) ចេះភ្ញាស់ និង ថែរក្សាកូនបានល្អ

-ត្រូវទិញពីកន្លែងណា ដែលគ្មានជំងឺមកចិញ្ចឹម

**រៀបចំទ្រុង** : មានច្រើនរបៀប អាស្រ័យទៅតាមបំណង និង ធនធានរបស់អ្នកចិញ្ចឹម ។

-ត្រូវសង់លើដីទួលមិនលិចទឹក

-ទ្រុងត្រូវអោយពន្លឺថ្ងៃចាំងចូលនៅពេលព្រឹក ដើម្បីសំលាប់មេរោគបានមួយចំនួន

-ទ្រុងត្រូវមានដំបូល និង ជញ្ជាំង ហើយដំបូលត្រូវធ្វើឱ្យខ្ពស់ សំរួលអោយមានខ្យល់ចេញចូលបានល្អ

-ធ្វើទ្រនំអោយសត្វដេក និង មានសំបុកគ្រប់គ្រាន់សំរាប់មេមាន់ពង

-មុននឹងដាក់មាន់ក្នុងទ្រុង ត្រូវតែធ្វើការរំងាប់មេរោគ ដោយប្រើកំបោរសបាចលើផ្ទៃដីទ្រុងទាំងមូល ហើយទុក រយៈពេល ១ ទៅ ២សប្តាហ៍ បន្ទាប់មកទើបបោសចេញអោយស្អាត

-ទំហំទ្រុងគឺ ១ម៉ែត្រក្រឡា សំរាប់មាន់៣ក្បាល

-មិនគួរចិញ្ចឹមមាន់ទុកក្រោមផ្ទះ ព្រោះវាអាចមានឥទ្ធិពលមិនល្អ ដល់សុខភាពមនុស្ស




ទ្រុងមាន់អាចដាក់បាន ១០០-១៥០ក្បាល

## ៣. ចំណីអាហារ និងទឹក :

នៅក្នុងទ្រុងត្រូវមានស្នូកទឹក និង ស្នូកចំណី ដើម្បីដាក់ទឹក និង ចំណីឱ្យសត្វវាផឹក ឬស៊ីបានស្អាតល្អ ស្នូកទឹក និង ស្នូកចំណី ត្រូវសំអាតជារៀងរាល់ថ្ងៃ ធ្វើយ៉ាងណាកុំអោយមាន់ជាន់កំពប់ ដែលបណ្តាលអោយសើម ឬក៏មានការកខ្វក់ដល់ ទ្រុងមាន់ ។

របៀបផ្តល់ទឹក និង ចំណី ត្រូវអនុវត្តន៍ ដូចតទៅ :

### ក. ការរៀបចំ និង ផ្តល់ចំណី :

ការរៀបចំចំណីត្រូវអនុវត្តទៅតាមរបៀបចិញ្ចឹម តាមបែបសេរី ឬតាមការចិញ្ចឹមដាក់ទ្រុង ឬតាមការដាក់ ទ្រុងផង លែងផង ។

ចំពោះមាន់ចិញ្ចឹមតាមបែបសេរី មិនជាចោទលើបញ្ហាប្រើប្រាស់ចំណីផ្សំ ដូចមាន់ចិញ្ចឹមដាក់ទ្រុងទេ ពីព្រោះ វាដឹងថាវាត្រូវការបំពេញនូវអ្វីដែលខ្លួនវាខ្វះខាត ដូចជាជីវជាតិ ប្រូតេអ៊ីន ខនិជ.... ។ល។ ដូច្នេះវាអាចរកបំពេញដោយ ខ្លួនវាក៏ប៉ុន្តែ យើងត្រូវការផ្តល់ចំណីអោយវាដែរ ព្រោះចំណីអាហារមានសារៈសំខាន់ ក្នុងការធ្វើឱ្យមាន់លូតលាស់ និងផ្តល់ ពងបានច្រើន ។ ដូចនេះត្រូវផ្តល់ចំណីអាហារដែលមានជាតិប្រូតេអ៊ីន ថាមពល ជាតិខ្លាញ់ វីតាមីន និង ជាតិខនិជ ។

**ជាតិប្រូតេអ៊ីន :** សំរាប់ផ្តល់ការលូតលាស់ និង ការបង្កើតពង ។ ខ្វះជាតិប្រូតេអ៊ីនក្នុងអាហារ នាំឱ្យសត្វលូត លាស់យឺត ផ្តល់ពងតិច រោមមិនស្អាត ។ ចំណីដែលសំបូរជាតិប្រតេអ៊ីនមាន : ត្រី សណ្តែកសៀង កាកសណ្តែក កាកសណ្តែកបាយ ។ សត្វល្អិតផ្សេងៗ ក៏ផ្តល់ជាតិប្រូតេអ៊ីនដល់មាន់ដែរ ដូចជា គណ្តៀរ ជន្លេន ចង្រិត ... ។ល ។

**ថាមពល** សំរាប់ផ្តល់ឱ្យរាងកាយ មានសកម្មភាព និង លូតលាស់ ។ ចំណីអាហារដែលសំបូរថាមពលមាន : កន្ទក់ កញ្ចុងអង្ករ ពោត កាកដំឡូងឈើ ស្ករ ។

**ជាតិ ខនិជ និង រ៉ែធាតុ :** សំរាប់ជួយអោយឆ្អឹងលូតលាស់ និង សំបកស៊ុតរឹង ។ ចំណីដែលសំបូរជាតិរ៉ែមាន ម្សៅឆ្អឹង សំបកខ្យងខ្ចៅ សំបកគ្រុំ សំបកលៀស ។

**ជីវជាតិ :** សំរាប់បង្កើតភាពរឹងមាំ និង ប្រឆាំងនិងមេរោគ ។ ចំណីដែលសំបូរជីវជាតិមាន : បន្លែ ស្មៅ រុក្ខជាតិ បៃតង (ស្លឹកកន្ទុំថេត អង្កាដី ស្លឹកដំឡូង ស្លឹកស្ពៃ ត្រកួន) ។

**អំបិល** ខ្វះជាតិអំបិលនៅក្នុងចំណី បណ្តាលឱ្យការស៊ីចំណីរបស់មាន់ត្រូវថយចុះ ។ ដូច្នេះការផ្សំចំណីប្រហែល ៥ គ.ក ត្រូវប្រើអំបិល ១% ។ (មើលរូបភាពខាងក្រោម)






ត្រូវអោយមាន់ស៊ីចំណីច្រើនមុខ ជាពិសេសចំពោះមាន់ចិញ្ចឹមដាក់ទ្រុង ត្រូវផ្តល់ចំណីឱ្យបានគ្រប់គ្រាន់ និងមានគុណភាពល្អ ។ គេអាចផ្តល់ចំណីច្នៃផ្សំ ដែលមាននៅក្នុងស្រុក តាមរូបមន្តដូចតទៅ :

| ល.រ | សមាសធាតុចំណី | បរិមាណ (ភាគរយ) |
|---|---|---|
| ១- | ស្រូវ កញ្ចុង ពោតក្រហម គ្រាប់ធញ្ញជាតិ | ៤០ % |
| ២- | កន្ទក់ | ១៥% |
| ៣- | ត្រីហាល ឬត្រីស្រស់ | ១០% |
| ៤- | ម្សៅកាកដូងស្ងួត | ១៥% |
| ៥- | សណ្តែកសៀង ឬសណ្តែកបាយ | ៦% |
| ៦- | ស្លឹកកន្ទុំថេតស្ងួត | ៥% |
| ៧- | ម្សៅសំបកខ្យង | ២% |
| ៨- | អំបិល | ០,៥% |

ខ- **ទឹក:** ទឹកជាកត្តាចាំបាច់បំផុតសំរាប់មាន់ ព្រោះទឹកជួយដល់ការរំលាយអាហារ ។ បើសិនជាផ្តល់ទឹកមិនគ្រប់គ្រាន់ អាចបណ្តាលឱ្យមាន់ទល់លាមក ។ មាន់អាចស្លាប់បានប្រសិនជាខ្វះជាតិទឹកក្នុងរយៈពេល ២៤ម៉ោង ។ ដូច្នេះ ត្រូវមានស្នូកទឹក និង ផ្តល់ទឹកស្អាតដល់មាន់ជាប្រចាំ ទាំងនៅរដូវប្រាំង និង រដូវវស្សា ។

ដើម្បីឱ្យការចិញ្ចឹមទទួលបានផលល្អ យើងគួរតែយល់ដឹង ពីការផ្តល់ចំណី និង ទឹកដូចជា :

-ត្រូវផ្លាស់ប្តូរទឹកក្នុងស្នូកឱ្យបានរាល់ថ្ងៃ ឬនៅពេលសង្កេតឃើញទឹកក្នុងស្នូកកខ្វក់

-ត្រូវផ្តល់ចំណីឱ្យមាន់ពេលព្រឹក និង ពេលល្ងាចឱ្យបានទៀងទាត់ បន្ថែមលើចំណីដែលវាដើររកស៊ីតាមធម្មតា

## ៤. ការចិញ្ចឹមថែទាំ និង វិធានការ ការពារ :

ការចិញ្ចឹមមាន់តាមវិធី៣យ៉ាងគឺ :

១-ការចិញ្ចឹមដាក់ទ្រុង

២- ការចិញ្ចឹមដាក់ទ្រុង ពេលយប់ និង លែងពេលថ្ងៃ

៣- ការចិញ្ចឹមលែងសេរី

**១.ការចិញ្ចឹមដាក់ទ្រុង :** គឺគេបង្ខាំងទុកក្នុងទ្រុងទាំងយប់ទាំងថ្ងៃ ការចិញ្ចឹមរបៀបនេះត្រូវឱ្យមាន .

-ទ្រុងត្រឹមត្រូវ

-ចំណីគ្រប់គ្រាន់ មានគុណភាពល្អ

-ងាយស្រួលក្នុងការត្រួតពិនិត្យមាន់ និងមិនទាមទារដីធំ

-កាត់បន្ថយការចំលងជំងឺ

ការចិញ្ចឹមបែបនេះ ល្អចំពោះការចិញ្ចឹមមាន់ច្រើនក្បាល ។



## ២-ការចិញ្ចឹមមាន់ដាក់ទ្រុងពេលយប់ និងលែងពេលថ្ងៃ :

ការចិញ្ចឹមរបៀបនេះ គឺគេលែងនៅពេលព្រឹក និង បញ្ចូលមាន់វិញនៅពេលល្ងាច ។ ដូច្នេះមាន់អាចដើររកស៊ីតាមវាលស្រែ ចំការ និងជុំវិញផ្ទះ ហើយកសិករគ្រាន់តែឱ្យចំណី ឬទឹក ពេលព្រឹក និង ពេលល្ងាចប៉ុណ្ណោះ ។

-ទាមទារដី និង ទីធ្លាសំរាប់មាន់

-ងាយស្រួលក្នុងការឆ្លងជំងឺសត្វផ្សេងទៀត

-អាចធ្វើបានចំពោះការចិញ្ចឹមមាន់មានចំនួនតិច




ទ្រុងមាន់ដាក់បាន ១០ក្បាល




ទ្រុងមាន់ដាក់បាន ២០ក្បាល

ទ្រុងមាន់ចិញ្ចឹមលែងពេលថ្ងៃ

## ៣-ការចិញ្ចឹមលែង :

ការចិញ្ចឹមរបៀបនេះ គឺឱ្យវាដើររកចំណីស៊ីដោយខ្លួនឯង តាមទីធ្លា វាលស្រែ និងបរិវេណជុំវិញផ្ទះ ។

ការចិញ្ចឹមលែង និង ការចិញ្ចឹមដោយបង្ខាំងទុកពេលយប់ លែងពេលថ្ងៃ ល្អចំពោះការចិញ្ចឹមមាន់តិចតួចប៉ុណ្ណោះព្រោះ កសិករចំណាយទុនតិចសំរាប់ទិញចំណី ជាងការចិញ្ចឹមមាន់ដាក់ទ្រុង ។ ប៉ុន្តែមានផលវិបាកដូចជា :

-មានការពិបាកក្នុងការតាមដានសុខភាពសត្វ

-សត្វមិនអាចទទួលចំណីគ្រប់គ្រាន់ ( បើកសិករមានសត្វច្រើន)

-ពិបាកក្នុងការធ្វើការចាក់ថ្នាំការពារជំងឺ

-សត្វមានការលូតលាស់យឺត និង ផ្តល់ពងតិច ដោយសារពុំមានការថែទាំល្អ ( មើលរូបភាពខាងក្រោម)



**មាន់ចិញ្ចឹមលែងសេរី**



## ការភ្ញាស់កូនមាន់

ការភ្ញាស់កូនមាន់មានពីររបៀបគឺ :

១-ភ្ញាស់សិប្បនិម្មិត ( គឺប្រើដោយម៉ាស៊ីន ឬប្រើអង្កាម)

២-ភ្ញាស់ដោយធម្មជាតិ ( គឺគេឱ្យមេមាន់ក្រាប)

សព្វថ្ងៃនេះប្រជាកសិករយើង ធ្លាប់អនុវត្តន៍ជាទូទៅតាមធម្មតា គឺការភ្ញាស់ដោយឱ្យមេមាន់ក្រាប គេ យកមេ មាន់ណាដែលធាត់ធំ ឬមេទាកាប៉ា ដើម្បីអោយវាក្រាបពងបានច្រើន គឺពី ១៥ ទៅ ១៨ពង ។ ការភ្ញាស់រ នេះគឺផ្តល់លទ្ធផលល្អណាស់ តែពុំអាចផ្តល់កូនមាន់អោយបានគ្រប់គ្រាន់ សំរាប់ការចិញ្ចឹមក្នុងកសិដ្ឋានធំៗ ដែលត្រូវកា មាន់ច្រើនហើយមានអាយុស្មើៗគ្នា ។

**សំបុក** គេច្រើនប្រើ ល្អី កញ្ជើរ ឬ កន្ត្រកធ្វើជាសំបុក ។ ក្នុងល្អី កញ្ជើរ ឬ កន្ត្រកគេដាក់ចំបើង ស្លឹក ស្ងួតជាដើម ។ ហើយយកទៅដាក់កន្លែងដែលមានការបិទបាំងល្អ មិនសូវមានពន្លឺ ។

សំបុកពងមិនត្រូវអោយប៉ះទឹកភ្លៀង កំដៅថ្ងៃក្តៅពេកទេ ហើយទុកដាក់កុំអោយសត្វកណ្តុរ ឬសត្វផ្សេ ទៀត ចូលទៅស៊ីបាន ។

រយៈពេលក្រាបគឺ ២១ថ្ងៃ ទើបញាស់ ។ នៅពេលមេមាន់ចាប់ផ្តើមក្រាប យើងត្រូវយកស្នូកទឹក ចំណើ ក្បែរសំបុក ដើម្បីឱ្យមេមាន់ងាយស្រួលចឹកចំណើអាហារ ។ ដើម្បីចៀសវាងកុំឱ្យកើតស្រមើរ នៅពេលមេមាន់កំពុង យើងត្រូវយកស្លឹក ថ្នាំជក់ កិន ឬ បុកឱ្យម៉ដ្ឋ រួចយកទៅរោយលើខ្លួន និងសំបុករបស់វា ព្រោះកាលណាកើតស្រ ដែលជាហេតុនាំឱ្យមេមាន់ លែងក្រាបក៏សឹងមាន ។

លុះដល់មេមាន់ក្រាបបាន ២០ថ្ងៃហើយ កូនមាន់ចាប់ផ្តើមចោះសំបក ត្រូវទុកឱ្យកូនមាន់ចោះចេញដោ ខ្លួនឯង ។ លុះដល់ ថ្ងៃទី២១ កូនមាន់ញាស់ចេញពីសំបក តែនៅពេលនោះកូនមាន់នៅសើម យើងទុកបន្ទ

ប្រ២ថ្ងៃទៀត ដើម្បី ឱ្យកូនមាន់ស្ងួតរោម និង មានភាពរឹងប៉ឹងល្អ ទើបយើងដាក់ចុះមកក្រោមឱ្យមេមាន់បណ្តើរ ឬបំបែកចេញពីមេយកទៅ ចិញ្ចឹមកន្លែងផ្សេងទៀតក៏បាន ។

**ការថែរក្សាកូនមាន់ :**

មាន ២របៀប : -ដោយមេបណ្តើរ

-ដោយឧស្សាហកម្ម

**ក.ដោយការចិញ្ចឹម ដោយមេមាន់បណ្តើរ :** ជាការល្អគួរទុកឱ្យមេរបស់វាថែកូនរបស់វាតាមសំបុក ទីមួយៗក្នុងកំឡុងអាទិត្យទី១ ទៅទី៣ តំរូវការដំបូងរបស់កូនមាន់គឺ ទឹកស្អាត ។

មេមាន់ក្នុងស្រុកជួយកូនមាន់រកចំណីអាហារ និង ការពារនៅពេលមានខ្យល់ ភ្លៀង ផ្គរ និង មានគ្រោះថ្នាក់ ពេលសត្វដទៃចង់យាយីកូនរបស់វា ។

នៅពេលកូនមានអាយុ ២ទៅ៣ខែ មេមាន់ឈប់បណ្តើរកូន រួចពងបន្តទៅទៀត ។

គេអាចប្រមូលយកកូនមាន់ក្នុងស្រុកអាយុ ១ថ្ងៃ ប្រមូលផ្តុំមកចិញ្ចឹមតាមរបៀបឧស្សាហកម្ម ។ ធ្វើដូចនេះ មេមាន់ ក្នុងស្រុកឆាប់រកឈ្មោល និង ពងសារជាថ្មី ។

ចំពោះកូនមាន់ដែលទើបនឹងភ្ញាស់រហូតដល់ ១២ម៉ោង អ្នកចិញ្ចឹមគួរតែកុំទាន់អោយចំណីវាស៊ី ព្រោះនៅ ក្នុងទងផ្ចិតរបស់វា នៅមានសារជាតិចិញ្ចឹមខ្លួនវានៅឡើយ ។ ក្នុងកំឡុងពេលនេះ គួរផ្តល់អាហារដែលមានជីវជាតិ និង ប្រូតេអ៊ីន ។

✡ **ការថែទាំចិញ្ចឹមមាន់ជំទង់ :** កូនមាន់ដែលមានអាយុលើសពី ៤សប្តាហ៍ឡើងទៅ វាដុះរោម និង ស្លាបដណ្តប់ខ្លួនរបស់វាបានគ្រប់គ្រាន់ ហើយវាមានកំដៅបញ្ចេញមកដើម្បីការពារខ្លួនវាបានស្រួល រីឯការលូតលាស់ លឿនជាងកូនមាន់អាយុតិច (ចំពោះកូនមាន់ឈ្មោល) លូតលាស់លឿនជាងកូនមាន់ញី ដូច្នេះអាចឱ្យយើងងាយស្រួល ក្នុងការសង្កេតកូនមាន់ញី និង កូនមាន់ឈ្មោល ។

✡ **ការថែទាំចិញ្ចឹមមាន់ធំ :** ពេលមាន់ជំទង់អាយុបាន ៥ទៅ៦ខែ យើងត្រូវជ្រើសរើសមាន់មេសំរាំង សំរាប់ចិញ្ចឹមយកពងបន្តពូជ បើយើងមិនត្រូវការទេ យើងអាចលក់ចេញ ឬយកសាច់ក៏បាន ។

មាន់អាចបន្តពូជបាន នៅពេលដែលវាមានអាយុពី៥ទៅ៦ខែឡើងទៅ អាស្រ័យទៅតាមពូជនិងផ្តល់ចំណីដល់វា ។

**របៀបបង្កាត់ :** មាន់ឈ្មោល១ក្បាលអាចជាន់មេមាន់បាន៨ទៅ ១០ក្បាលដែលមានប្រសិទ្ធភាព ដូច្នេះ ដើម្បីកុំឱ្យរំខានដល់មេមាន់ត្រូវទុកមាន់ឈ្មោលអោយបានសមស្របទៅតាមអត្រារបស់មេមាន់ដែលចិញ្ចឹម ។

**វិធានការបង្ការ :** ក្រៅពីកត្តាទាំងអស់ខាងលើ យើងមានបញ្ហាសំខាន់គួរឱ្យចាប់អារម្មណ៍មួយចំនួនគឺ :

-ត្រូវចាក់ថ្នាំការពារជំងឺឆ្លងច្រើនប្រភេទរបស់សត្វមាន់ ( ដូចជាជំងឺអាសន្នរោគ ញូវកាស អុតបក្សី ......។ល ។)

-ត្រូវផ្តល់ថ្នាំការពារនេះ នៅពេលដែលសត្វមានសុខភាពល្អ និងមុនជំងឺមកដល់ ហើយត្រូវប្រើទៅតាមរបៀ ណែនាំនៃប្រភេទថ្នាំនីមួយៗ ។

-ត្រូវទំលាក់បរាសិត ឱ្យបានទៀងទាត់ អាស្រ័យទៅតាមប្រភេទថ្នាំ ។

-ត្រូវទិញមាន់ពីកន្លែងដែលគ្មានជំងឺមកចិញ្ចឹម នៅពេលដែលអ្នកសង្ស័យថាមាន់របស់អ្នកមានឈឺត្រូវបំបែកចេ ពីមាន់ដែលជា ។

-ត្រូវបង្ខាំងមាន់របស់អ្នកទុកក្នុងទ្រុង នៅពេលដែលអ្នកជិតខាងមានមាន់ឈឺ

-សាកសពមាន់ដែលមានជំងឺ ត្រូវកប់ ឬដុតចោល ហាមវះកាត់សាកសពសត្វ ដោយចោលរោមពោះវៀ លាមកជិតកន្លែងចិញ្ចឹម ។

-ត្រូវធ្វើអនាម័យទ្រុង ស្នូកទឹក ស្នូកចំណើ ឱ្យបានហ្មត់ចត់

-ការពារកុំឱ្យមនុស្សនាំសត្វឈឺចូលមកកន្លែងចិញ្ចឹម ។



# 4.5 សកម្មភាព

យើងនាំគ្នាលេងល្បែងអំពីការចិញ្ចឹមសត្វ ដើម្បីបានអនុវត្តន៍អ្វីដែលយើងបានរៀនក្នុងមេរៀននេះ ។



## មេរៀនទី ៥

# របៀបប្រើប្រាស់វ៉ាក់សាំង និងថ្នាំព្យាបាល






# ការការពារ

## 5 .1 សេចក្តីផ្តើម

នៅក្នុងមេរៀននេះអ្នកនឹងបានរៀនអំពីរបៀបថែរក្សាថ្នាំ របៀបប្រើប្រាស់ គណនាកំរិតនៃការប្រើប្រាស់ថ្នាំ តំលៃថ្នាំ ។ អ្នកនឹងបានលេងល្បែងដើម្បីជួយអោយអ្នកមានការងាយស្រួលក្នុងការចងចាំ ។

## 5 .2 គោលបំណង

ក្រោយពីការបញ្ចប់មេរៀន សិក្ខាកាមទាំងអស់នឹងអាចមានសមត្ថភាពដូចខាងក្រោមនេះ :

- ដាក់ឈ្មោះថ្នាំវ៉ាក់សាំងដែលយើងមាន
- ដាក់ឈ្មោះថ្នាំទំលាក់ព្រូនដែលយើងមាន
- ដាក់ឈ្មោះថ្នាំសំលាប់មេរោគដែលយើងមាន
- ដាក់ឈ្មោះថ្នាំជំនួយកំលាំងសត្វដែលយើងមាន
- ថែរក្សា និង ប្រើប្រាស់ថ្នាំព្យាបាលនិងវ៉ាក់សាំងបានត្រឹមត្រូវ
- កំណត់នូវកំរិតនៃការប្រើប្រាស់ និងតំលៃរបស់ថ្នាំព្យាបាល និង វ៉ាក់សាំងបានត្រឹមត្រូវ

## 5 .3 សំភារៈសំរាប់សិក្សា

5.4 អត្ថបទ

## 5.4.1 របៀបប្រើប្រាស់វ៉ាក់សាំង

### ក្នុងការប្រើប្រាស់វ៉ាក់សាំងមាន ៤យ៉ាង

- របៀបថែទាំវ៉ាក់សាំង
- របៀបប្រើប្រាស់វ៉ាក់សាំង (របៀបចាក់)
- តើត្រូវប្រើប៉ុន្មានដង និង សំរាប់សត្វប្រភេទណា?
- តើកសិករត្រូវបង់ប្រាក់ប៉ុន្មានរៀល?

សិក្ខាកាមត្រូវសរសេរ

- របៀបថែទាំវ៉ាក់សាំង

........................................................................................................................................

........................................................................................................................................

........................................................................................................................................

..............                ..........................................................................................................

- របៀបប្រើប្រាស់វ៉ាក់សាំង

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

សិក្ខាកាមត្រូវរៀនតាមប្រភេទថ្នាំនីមួយៗ

- តើត្រូវរៀនប៉ុន្មានដង និង សំរាប់សត្វប្រភេទណា?
- តើកសិករត្រូវបង់ប្រាក់ប៉ុន្មានរៀល?

## 5.4.2 វ៉ាក់សាំងដែលប្រើប្រាស់ក្នុងកម្ពុជា

មានវ៉ាក់សាំងសំរាប់ចាក់ការពារជំងឺខាងក្រោមនេះ



ជំងឺ សារទឹក

ជំងឺ អុតក្ដាម

ជំងឺ ឈាមខ្មៅ

ជំងឺ បូសខ្យល់



ជំងឺ បេស្ដ៍ជ្រូក



ជំងឺ ញូវកាស់មាន់

ជំងឺ អុតមាន់

ជំងឺ អាសន្នរោគមាន់

## 5.4.5 របៀបប្រើប្រាស់ថ្នាំព្យាបាល

ក្នុងការប្រើប្រាស់ថ្នាំព្យាបាលមាន ៤យ៉ាង :

១-របៀបថែរក្សាថ្នាំព្យាបាល

២-របៀបប្រើប្រាស់ថ្នាំព្យាបាល

៣-តើត្រូវប្រើប៉ុន្មានដង និងសំរាប់សត្វប្រភេទណា?

៤-តើកសិករត្រូវបង់ប្រាក់ប៉ុន្មានរៀល?

សិក្ខាកាមត្រូវសរសេរ

- របៀបថែរក្សាថ្នាំព្យាបាល

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

- របៀបប្រើប្រាស់ថ្នាំព្យាបាល

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

សិក្ខាកាមត្រូវរៀនតាមប្រភេទថ្នាំនីមួយៗ

- តើត្រូវប្រើប៉ុន្មានដង និងសំរាប់សត្វប្រភេទណា?
- តើកសិករត្រូវបង់ប្រាក់ប៉ុន្មានរៀល?

## 5.4.6 ថ្នាំព្យាបាលដែលសំលាប់ព្រូន

**ប្រភេទថ្នាំ** : ថ្នាំបញ្ចុះព្រូន

**ឈ្មោះថ្នាំ** : LEVAMISOLE (100 ml)

**ការប្រើប្រាស់** : ថ្នាំនេះប្រើសំរាប់បញ្ចុះប្រភេទព្រូនមូលដែលរស់នៅក្នុងពោះវៀននិងក្នុងសួត ។

**របៀបប្រើប្រាស់** ៖ ចាក់សាច់ដុំ រឺ ក្រោមស្បែក ។

**កំរិតនៃការប្រើប្រាស់** ៖ ចំពោះសត្វគោក្របី ត្រូវចាក់ ៥ ម.ល សំរាប់ ១០០គ.ក្រ នៃទំងន់សត្វ ។

ចំពោះសត្វជ្រូកត្រូវចាក់ ០.៥ ម.ល សំរាប់ ១០គ.ក្រ នៃទំងន់សត្វ ។

**ការប្រុងប្រយ័ត្ន ៖**

ហាមប្រើប្រាស់ថ្នាំនេះលើសកំរិត ។ ចំពោះគោក្របី ហាមចាក់លើសពី ៣៧.៥ ម.ល ។

ចំពោះសត្វជ្រូកហាមចាក់លើសពី ៤ម.ល ។

**ប្រភេទថ្នាំ** ៖ ថ្នាំបញ្ចុះព្រូន

**ឈ្មោះថ្នាំ** IVOMEC (50 ml)

**ការប្រើប្រាស់** ៖ ថ្នាំនេះប្រើប្រាស់សំរាប់

- បញ្ចុះប្រភេទព្រូនមូលដែលរស់នៅក្នុងពោះវៀននិងក្នុងសួត ។
- សំលាប់ អង្កែ

**របៀបប្រើប្រាស់** ៖ ចាក់ក្រោមស្បែក ។

**កំរិតនៃការប្រើប្រាស់** ៖ ចំពោះសត្វគោក្របី ត្រូវចាក់ ១ ម.ល សំរាប់ ៥០គ.ក្រ នៃទំងន់សត្វ ។

ចំពោះសត្វជ្រូកត្រូវចាក់ ០.៣ ម.ល សំរាប់ ១០គ.ក្រ នៃទំងន់សត្វ ។

**ការប្រុងប្រយ័ត្ន ៖**

ហាមប្រើប្រាស់ថ្នាំនេះលើសកំរិត ។

**ប្រភេទថ្នាំ** ៖ ថ្នាំបញ្ចុះព្រូន

**ឈ្មោះថ្នាំ** **MEBENDAZOLE**

**ការប្រើប្រាស់** ៖ ថ្នាំនេះប្រើប្រាស់សំរាប់

- បញ្ចុះប្រភេទព្រូនមូលដែលរស់នៅក្នុងពោះវៀននិងក្នុងសួត ។

**របៀបប្រើប្រាស់** ៖ តាមមាត់ ក្នុងចំណី ។

**កំរិតនៃការប្រើប្រាស់** ៖

ចំពោះសត្វគោក្របី ត្រូវចាក់............ ម.ល សំរាប់ ...........គ.ក្រ នៃទំងន់សត្វ ។ ១ដង

ចំពោះសត្វជ្រូកត្រូវចាក់ ..........ម.ល សំរាប់............គ.ក្រ នៃទំងន់សត្វ ។ ១ដង ១ថ្ងៃ (ក្នុងរយៈពេល៣ថ្ងៃ)

**ការប្រុងប្រយ័ត្ន ៖**

ហាមប្រើប្រាស់ថ្នាំនេះលើសកំរិត ។

## អាសុនតុល
## ASUNTOL

ជាថ្នាំម្សៅ ប្រើប្រឆាំង បរាសិតខាងក្រៅ : អង្កែ ចៃ ស្រមើល ដង្កៃ................................. ។

### ១. សមាសធាតុ :

- Coumaphos (organophosphate)

### ២. របៀបរៀបចំថ្នាំ :

វាល់ថ្នាំអាសុនតុល ១ស្លាបព្រាពងទាកូន (0,៥ ក្រាម) ដាក់ទៅក្នុងបំពង់បាញ់ រួចចាក់ទឹកបន្ថែមកន្លះលីត្រ ។ ក្រឡុក ឬកូរថ្នាំ ឱ្យរលាយស្មើសាច់ មុននឹងយកទៅបាញ់លើខ្លួនសត្វ ។

### ៣. ការព្យាបាល :

- ជ្រូក : - ដុសលាងក្រមរ ខ្លួនសត្វ ដោយប្រើសាប៊ូ និងច្រាស់
  - ដុសលាងឱ្យខ្លាំងៗ គ្រប់ទីកន្លែងទាំងអស់ រួចទុកឱ្យស្ងួត
  - បាញ់ថ្នាំលើខ្លួនសត្វ ដោយបំពង់បាញ់ គ្រប់ទីកន្លែង ជាពិសេសស្លឹកត្រចៀក
- មាន់ : - បាញ់ថ្នាំលើជើងសត្វ
- គោ : - បាញ់នៅកន្លែងដែលមានដង្កែ
  - ចំពោះចៃ ត្រូវបាញ់ថ្នាំនៅលើខ្លួនសត្វ

### ៤. កំរិតប្រើ :

- កន្លះលីត្រ = សំរាប់កូនជ្រូក ៤-៥ ក្បាល (អាយុ ២ខែ)
- កន្លះលីត្រ = សំរាប់ជ្រូក ២ក្បាល (អាយុ ៣ខែ)
- កន្លះលីត្រ = សំរាប់គោតូច ១ក្បាល
- កន្លះលីត្រ = សំរាប់គោធំ ១ក្បាល

ធ្វើការព្យាបាលឡើងវិញ នៅសប្តាហ៍ក្រោយ ។

### ប្រយ័ត្ន :

- ហាមផឹកថ្នាំនេះ និងទុកដាក់ឱ្យផុតពីដៃក្មេង
- ត្រូវលាងសំអាតដៃឱ្យបានស្អាត ក្រោយពេលប្រើថ្នាំនេះ
- ហាមប្រើថ្នាំ នៅជិតទឹកផឹក ទឹកប្រើប្រាស់ ឬចំណីអាហារ ។

## 5.4.7 ថ្នាំព្យាបាលដែលសំលាប់ មេរោគ

**ប្រភេទថ្នាំ** : ថ្នាំផ្សះសំរាប់បង្អន់បាក់តេរី

**ឈ្មោះថ្នាំ** : TERRAMYCIN D (100 cc)

**ការប្រើប្រាស់** : អាចប្រើក្នុងការព្យាបាលជំងឺសត្វពាហណៈ និងសត្វស្លាបដែលបណ្តាលមកពីបាក់តេរី ។

**របៀបប្រើប្រាស់** : ចាក់សាច់ដុំ រឺ ចាក់តាមសរសៃវែនយ៉ាងយឺត១ ។

**កំរិតនៃការប្រើប្រាស់** : 1cc/10kg ក្នុង១ថ្ងៃម្តង រយៈពេល៣ថ្ងៃ ។

**ការប្រុងប្រយ័ត្ន :**

ហាមប្រើប្រាស់សាច់សត្វដែលចាក់ថ្នាំនេះមុន ២១ថ្ងៃក្រោយពីពេលចាក់ថ្នាំ ។

ហាមចាក់ត្រង់មួយកន្លែងបើកំរិតថ្នាំលើសពី ២០ ម.ល ចំពោះសត្វគោក្របី ១០ ម.ល ចំពោះ ជ្រូក

ហាមប្រើប្រាស់ថ្នាំនេះក្នុងការព្យាបាល ឆ្មា ឆ្កែ និងសេះ ។

**ប្រភេទថ្នាំ** : ថ្នាំផ្សះសំរាប់បង្អន់បាក់តេរី

**ឈ្មោះថ្នាំ** : OXYTETRACYCLINE 10% (100cc)

**ការប្រើប្រាស់** : អាចប្រើក្នុងការព្យាបាលជំងឺឆ្លងសត្វគោ ក្របី ជ្រូកដែលបណ្តាលមកពីបាក់តេរីមួយចំនួន ។

អាចប្រើប្រាស់ក្នុងការព្យាបាលជំងឺសត្វដែលបណ្តាលមកពីបាក់តេរីដូចជា :ជំងឺប្រដាប់ដង្ហើម រលាក រលាកស្បូន និងដំបៅក្រចកជាដើម ។

**របៀបប្រើប្រាស់** : ចាក់សាច់ដុំ រឺ ក្រោមស្បែក ។

**កំរិតនៃការប្រើប្រាស់** : ១ម.ល សំរាប់ ១០ គ.ក្រ នៃទំងន់សត្វ ។ ១ថ្ងៃម្តង ( ក្នុងរយៈពេល៣ថ្ងៃ)

**ការប្រុងប្រយ័ត្ន :**

ហាមប្រើប្រាស់សាច់សត្វដែលចាក់ថ្នាំនេះមុន ២១ថ្ងៃក្រោយពីពេលចាក់ថ្នាំ ។

ហាមចាក់ត្រង់មួយកន្លែងបើកំរិតថ្នាំលើសពី ២០ ម.ល ចំពោះសត្វគោក្របី ១០ ម.ល ចំពោះ ជ្រូក

ហាមប្រើប្រាស់ថ្នាំនេះក្នុងការព្យាបាល ឆ្មា ឆ្កែ និងសេះ ។

**ប្រភេទថ្នាំ** : ថ្នាំផ្សះសំរាប់បង្អន់បាក់តេរី

**ឈ្មោះថ្នាំ** : TERRALINE 10%

**ការប្រើប្រាស់** : អាចប្រើក្នុងការព្យាបាលជំងឺឆ្លងសត្វគោ ក្របី សេះ ចៀម ពពែ ឆ្កែ ជ្រូកដែលបណ្តាលមកពីបាក់តេរីមួយចំនួន ។

ដូចជា ៖ ជំងឺរលាកផ្លូវដង្ហើម រលាកផ្លូវបន្តពូជក្រោយពេលកើតកូនហើយ រលាកដោះ រលាកស្បូន មុខរបួសក្រោយពេលវះកាត់ ឈឺក្រចកជើង កញ្ជ្រិល និងរាគរូសជាដើម ។

របៀបប្រើប្រាស់ ៖ ចាក់សាច់ដុំ

កំរិតនៃការប្រើប្រាស់ ៖

ចំពោះកូនសត្វត្រូវចាក់១ម.ល សំរាប់ ១០គ.ក្រ នៃទំងន់សត្វ ។ ១ថ្ងៃម្តង (ក្នុងរយៈពេល៣ថ្ងៃ)

ចំពោះសត្វធំត្រូវចាក់ ១ម.ល សំរាប់ ២០គ.ក្រ នៃទំងន់សត្វ ។ ១ថ្ងៃម្តង (ក្នុងរយៈពេល៣ថ្ងៃ)

**ការប្រុងប្រយ័ត្ន ៖**

ត្រូវរក្សាទុកក្នុងកន្លែងត្រជាក់ និង ងងិត ។

ហាមប្រើប្រាស់ទឹកដោះពីសត្វដែលបានចាក់ថ្នាំនេះមុនរយៈពេល៣ថ្ងៃ ក្រោយពីពេលចាក់ថ្នាំ

ហាមប្រើប្រាស់សាច់សត្វ មុន១៤ថ្ងៃក្រោយពេលចាក់ថ្នាំ ។

# ស៊ុលហ្វា ៣៣

## SULFA 33

ជាថ្នាំសំរាប់ចាក់ និងផឹក ១ដបមានចំណុះ ១០០ មល ។

### ១. សមាសធាតុ :

- Sulphadimidine sodium
- Sodium methytlhydroxybenzoate

### ២. គបនឹងជំងឺ :

គោ ចៀម ពពែ ជ្រូក សេះ ទន្សាយ បក្សី ការបង្ករោគបណ្ដាលកមពីមីក្រុបចំរុះ ចាញ់ Sulphadimidine ដូចជា: កុកស៊ីឌីយ៉ូស៊ីស កូលីបាក់ស៊ីលូស៊ីស សាល់ម៉ូណែលឡូស៊ីស អាសន្នរោគ រាគ.........................

### ៣. ផ្លូវបញ្ចូលថ្នាំ និងកំរិតប្រើ :

- តាមមាត់ :
  - បក្សី : ៥ ទៅ ៦ ml/L ទឹកផឹក ព្យាបាល ៣ ទៅ ៥ ថ្ងៃ ។
  - កុកស៊ីឌីយ៉ូស៊ីសបក្សី : ត្រូវព្យាបាល ៣ ថ្ងៃ ឈប់ ២ថ្ងៃ រួចព្យាបាល ៣ថ្ងៃទៀត ។
- ចាក់សាច់ដុំ (IM) ឬសរសៃវ៉ែន (IV)
  - ប្រភេទផ្សេងៗ ក្រៅពីបក្សី: ១.៥ ml ទៅ ៣ ml/១០ kg ទំងន់សត្វរស់ព្យាបាល ៣ ទៅ ៥ថ្ងៃ

### ៤. បំរាម :

ហាមប្រើក្នុងករណី សត្វប្រឆាំង Sulphonamides ជំងឺថ្លើមធ្ងន់ធ្ងរ ឬខ្សោយតំរងនោម

### ៥. ការប្រុងប្រយ័ត្ន :

- ត្រូវចាក់ទឹក តាមចំណុះព្យាបាលសត្វ ។ សូលុយស្យុងថ្នាំ លាយម្ដងប្រើក្នុងរយ:ពេលតែ ២៤ ម៉ោង ។
- ត្រូវផ្ដល់ទឹកឱ្យសត្វ ដែលព្យាបាល ផឹកឱ្យបានច្រើន ។

### ៦. រយៈពេលហាមប្រើប្រាស់ :

- ផ្លូវបញ្ចូលឱសថផ្សេងៗ
  - សត្វកំពុងព្យាបាល និងក្រោយព្យាបាល ១០ថ្ងៃ ហាមពិឃាតយកសាច់សំរាប់ឱ្យមនុស្សបរិភោគ ។
  - ទឹកដោះយកពីមេគោ កំពុងព្យាបាល និងក្រោយព្យាបាល ១០ពេល មិនត្រូវយកទៅបរិភោគ ។
- តាមមាត់ :
  - សាច់បក្សី កំពុងព្យាបាល និងក្រោយពេលព្យាបាល ១០ថ្ងៃហាមពិឃាតយកសាច់ សំរាប់ឱ្យមនុស្សបរិភោគ ។
  - ស៊ុតយកចេញពីបក្សី កំពុងព្យាបាលនិង ក្រោយពេលព្យាបាល ១២ថ្ងៃ ហាមយកមកសំរាប់មនុស្សបរិភោគ ។

**ប្រភេទថ្នាំ** :ថ្នាំផ្សះសំរាប់បង្អន់បាក់តេរី

**ឈ្មោះថ្នាំ** : TYLO (100 cc)

**ការប្រើប្រាស់** :អាចប្រើក្នុងការព្យាបាលជំងឺសត្វពាហណៈនិងសត្វស្លាប ដែលបណ្តាលមកពីបាក់តេរីមួយចំនួន ។

ដូចជា : ជំងឺផ្លូវដង្ហើម ផ្លូវបន្តពូជ ផ្លូវទឹកមូត រលាកដោះ បួលលើសត្វជ្រូក ជំងឺផ្លូវដង្ហើមបក្សី ជំងឺអំពៅអំបែក បក្សី និងជំងឺសើរស្បែកដែលបណ្តាលមកពីបាក់តេរី ។

**របៀបប្រើប្រាស់** :ចាក់សាច់ដុំ

**កំរិតនៃការប្រើប្រាស់ :** ចំពោះសត្វធំត្រូវចាក់ ១ម.ល សំរាប់ ១០គ.ក្រ នៃទំងន់សត្វ ១ថ្ងៃម្តង ។

ចំពោះកូនសត្វត្រូវចាក់១ម.ល សំរាប់ ៥គ.ក្រ នៃទំងន់សត្វ ១ថ្ងៃម្តង ។

ចំពោះសត្វស្លាប ១ម.ល សំរាប់ ២.៥គ.ក្រ នៃទំងន់សត្វ ១ថ្ងៃម្តង ។

រយៈពេលព្យាបាលពី ៣ទៅ១០ថ្ងៃ អាស្រ័យទៅតាមលក្ខណៈធ្ងន់ស្រាលនៃជំងឺ ។

**ការប្រុងប្រយ័ត្ន :**

ហាមប្រើប្រាស់សាច់សត្វ មុន២១ថ្ងៃក្រោយពេលចាក់ថ្នាំ ។

# ស៊ុលទ្រីហ្សិក
# SULTRIJECT

ជាថ្នាំសំរាប់ចាក់ ១ដបមានចំណុះ ១០០ម.ល ។

## ១.សមាសធាតុ :

-Sulphadimethoxine Sodium
-Trimethoprim
-Methyl Parohydroxybenzoate

## ២.គុណវិជ្ជ :

-គោ ចៀម ពពែ ជ្រូកសេះ ទន្សាយ បក្សី ការបង្ករោគបណ្តាលមកពីមីក្រុបចំរុះ ចាញ់នឹង Sulphadimethoxine និង Trimethoprim ជំងឺផ្លូវដង្ហើមស្រួចស្រាវ រាគឈាម រាគរូសកូនសត្វ សារទឹក រលា សន្លាក់ អាសន្នរោគ ..........

## ៣.ផ្លូវបញ្ចូលថ្នាំ និងកំរិតប្រើ :

-ចាក់សាច់ដុំ (IM) ចាក់ក្រោមស្បែក (SC) ចាក់តាមសរសៃយឺតៗ (IV)

-**គោ ជ្រូក ពពែ ចៀម :** 1ml / 10kg នៃទំងន់សត្វរស់សំរាប់ ១ថ្ងៃ ( 30ml / សត្វ១ក្បាលមិនលើសកំរិ

-រយៈពេលព្យាបាល ៣ថ្ងៃ ។

## ៤.បំរាម :

-ហាមប្រើក្នុងករណី សត្វប្រឆាំង Sulphadimethoxine ជំងឺថ្លើមធ្ងន់ធ្ងរ ឬខ្សោយតំរងនោម ។

## ៥.ការប្រុងប្រយ័ត្ន :

-ក្នុងករណីមានអាឡែស៊ី បញ្ឈប់ការព្យាបាលជាបន្ទាប់

-ត្រូវផ្តល់ទឹកឱ្យសត្វដែលព្យាបាល ផឹកឱ្យបានច្រើន

## ៦.រយៈពេលហាមប្រើប្រាស់ :

-សាច់ : ក្នុងចន្លោះពេល ១២ ថ្ងៃ ក្រោយការប្រើប្រាស់ថ្នាំចុងក្រោយ ។

-ទឹកដោះ : ១២ ពេល ។

# ស្ត្រិបតូមីស៊ីន ១ក្រាម
## STREPTOMYCIN 1G

**១.សមាសធាតុ :**

STREPTOMYCIN 1G

**២.គុណវិបត្តិ :**

ដែលបណ្តាលមកពីបាក់តេរីក្រាម ( - ) ដូចជា : ជំងឺផ្លូវដង្ហើម រលាកសួត រលាកផ្លូវរំលាយអាហារ ផ្លូវបន្តពូជ រលាកដោះ រលាកស្បូន រាគរូស ។ល។

**៣.កំរិត និងវិធីប្រើ :**

-ចាក់សាច់ដុំ (IM) ចាក់ក្រោមស្បែក (SC) ចាក់យឺតៗតាមវ៉ែន (IV)

**-សេះ គោ ក្របី :** ១ដប សំរាប់ ៥០គក្រ នៃទំងន់សត្វ

**-ជ្រូក ចៀម ពពែ :** ១ដប សំរាប់ ៤០គក្រ នៃទំងន់សត្វ

**-សត្វស្លាប :** ១ដប សំរាប់ ២០គក្រ នៃទំងន់សត្វ

**៤.រយៈពេលនៃការប្រើ :**

-ចាក់ ៣ដង ក្នុង ១ថ្ងៃ (រយៈពេលព្យាបាល ៣-៤ថ្ងៃ) ។

**ប្រភេទថ្នាំ** : ថ្នាំផ្សះ សំលាប់បាក់តេរី

**ឈ្មោះថ្នាំ** : STREPTOPEN (100cc)

**ការប្រើប្រាស់** : អាចប្រើក្នុងការព្យាបាលដែលបណ្តាលមកពីបាក់តេរីក្រាម( + )និងក្រាម( - ) ។

**របៀបប្រើប្រាស់** : ចាក់សាច់ដុំ

**កំរិតនៃការប្រើប្រាស់ :** ត្រូវចាក់ ១ cc សំរាប់ ១០គ.ក្រ នៃទំងន់សត្វ ។ ១ថ្ងៃម្តង រហូតដល់ជាសះស្បើយ

**ការប្រុងប្រយ័ត្ន :**

ក្រឡុកដបមុនពេលចាក់ ។

ហាមប្រើលើទន្សាយ ។

ហាមប្រើសាច់ដែលចាក់ថ្នាំនេះមុនរយៈពេល ១០ថ្ងៃក្រោយពេលចាក់ ។

# ក្លរតេត្រាសូន

# CHLORTETRASONE

ជាថ្នាំសំរាប់ចាក់ ១ដបមានចំណុះ ៥០ . ១០០ម.ល។

## ១-សមាសធាតុ :

-Prodnisolone
-Oxytetracycline
-Chloramphenicol
-Lidocaine Chlorhydrate

## ២-ភបនិចជំងឺ :

ដែលបណ្តាលមកពីបាក់តេរីក្រាម (+) ពពួកឡិបតូស្ពៀរ៉ា ឬ រិកេត្យា (Liptospirae ou Rickettsiae

## ៣-ផ្លូវបញ្ចូលថ្នាំ និងកំរិតប្រើ :

-ចាក់សាច់ដុំ (IM) ចាក់ក្រោមស្បែក (SC) ចាក់ចូលសន្លាក់ឬ ចាក់ចូលស្រោមពោះ(IP)(ចំពោះជ្រូក)។

-ចាក់មួយថ្ងៃម្តង រយះពេល ៣-៤ ថ្ងៃ

-កំរិត

| ប្រភេទ | ទំងន់សត្វ (Kg) | ចំណុះថ្នាំត្រូវចាក់ (ml) |
|---|---|---|
| សត្វតូច | 1<br>10<br>20 | 1<br>2.5<br>5 |
| សត្វទំហំមធ្យម | 25<br>50<br>100 | 5<br>10<br>20 |
| សត្វធំ | 250<br>500<br>ចាប់ពី 600 ឡើង | 25<br>30<br>40 |

## ៤-ដំបូន្មាន :

-25ml សំរាប់ចាក់សត្វធំ មិនហួសកំរិតទេ ដូចគ្នា 10ml សំរាប់សត្វតូច

-ក្នុងរយះពេលនៃការព្យាបាល សត្វខ្លះមានក្លិន DMSO

## ៥-បំរាម :

-ចាក់តាមផ្លូវផ្សេងៗ គួរចៀសវាងចំពោះកូនគោ ព្រោះសត្វមានការឈឺចាប់ខ្លាំង

-ហាមចាក់សត្វធើម ក្នុងតំណោក់កាលទី ៣ចុងក្រោយ។

**ប្រភេទថ្នាំ** : ថ្នាំផ្សះ សំលាប់បាក់តេរី

**ឈ្មោះថ្នាំ** : GENTAMICIN ( 2 cc)

**ការប្រើប្រាស់** : អាចប្រើក្នុងការព្យាបាលដែលបណ្តាលមកពីបាក់តេរីក្រាម(-) ។

ដូចជា : ជំងឺតាមផ្លូវដង្ហើម រលាកសួត ជំងឺតាមផ្លូវទឹកម៉ូត្រ ការរលាត់ស្បែក របួស ដំបៅ ជំងឺត្រចៀក និងជំងឺភ្នែក ជាដើម ។

**របៀបប្រើប្រាស់** : ចាក់ក្រោមស្បែក . សាច់ដុំ

**កំរិតនៃការប្រើប្រាស់** : ត្រូវចាក់ ១-២ ម.ល សំរាប់ ១គ.ក្រ នៃទំងន់សត្វ ។ ១ថ្ងៃចាក់៣ដង

**ការប្រុងប្រយ័ត្ន** :

ហាមប្រើថ្នាំនេះជាមួយពពួកថ្នាំបង្អន់បាក់តេរី ។

ហាមប្រើលើសកំរិត ព្រោះអាចបណ្តាលឱ្យខូចតំរងនោម សោតវិញ្ញាណនិងអាចប៉ះពាល់ដល់ ជីវិត ។

ហាមប្រើលើគោក្របីក្នុងកំឡុងពេលកើតកូន ព្រោះវាអាចបណ្តាលអោយអត្រាកាល់ស្យូម ថយចុះ ។

ការចាក់តាមសរសៃអាចបណ្តាលអោយមានគ្រោះថ្នាក់ ។

**ប្រភេទថ្នាំ** : ថ្នាំផ្សះ សំលាប់បាក់តេរី

**ឈ្មោះថ្នាំ** : AMPICILLIN ( 2g )

**ការប្រើប្រាស់** : ថ្នាំនេះមានប្រសិទ្ធភាពទៅលើបាក់តេរីក្រាម(+) និងក្រាម(-) ។

ដូចជា : ជំងឺរាគរូសកូនជ្រូក ជំងឺសើរស្បែកខ្លះ ជំងឺផ្តាសាយបក្សី រោគសន្ទរោគបក្សី ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃជាដើម ។

**របៀបប្រើប្រាស់** : ចាក់សាច់ដុំ រឺ តាមសរសៃវ៉ែន

**កំរិតនៃការប្រើប្រាស់** :

ចំពោះសត្វពាហណៈត្រូវចាក់ ១ ដប សំរាប់ ១០០គ.ក្រ នៃទំងន់សត្វ ។

ចំពោះសត្វស្លាបត្រូវចាក់ ១ ដប សំរាប់ ២០គ.ក្រ នៃទំងន់សត្វ ។ ១ថ្ងៃចាក់២ រឺ ៣ដង ។

**ការប្រុងប្រយ័ត្ន** :

មិនត្រូវប្រើថ្នាំនេះទៅលើសត្វទន្សាយឡើយ ។



# អុកស៊ីតែត (ចាក់)
# OXYTET (Injectable)

ថ្នាំនេះប្រើសំរាប់ គោ ក្របី ជ្រូក មាន់ ទា

ថ្នាំនេះ គឺជាអង់ទីប៊ីយ៉ូទិកមួយបែប សំរាប់ប្រើទប់ទល់ប្រឆាំងនឹងជំងឺ ដែលមានរោគសញ្ញាដូចខាងក្រោម :

-រលាកក្រពះ ពោះវៀន

-រលាកតម្រងនោម

-ហើមក ហើមពោះ

-រលាកប្រព័ន្ធដង្ហើម ពិបាកដកដង្ហើម

-រលាក ឬ ដំបៅនៅលើស្បែក

-គ្រុនក្តៅ មិនស៊ីចំណី

វិធីប្រើថ្នាំ : ចាក់សាច់ដុំ "ចាក់ ១ដង ក្នុង ១ថ្ងៃ"

➔ ប្រើសំរាប់សត្វគោ ក្របី ជ្រូក

ប្រើ ១.១ cc សំរាប់ទំងន់សត្វរស់ ៥គ.ក្រ

ប្រើ ២.២ cc សំរាប់ទំងន់សត្វរស់ ១០គ.ក្រ

ប្រើ ៤.៤ cc សំរាប់ទំងន់សត្វរស់ ៥០គ.ក្រ

➔ ប្រើសំរាប់សត្វស្លាប 0.២ cc សំរាប់ទំងន់សត្វរស់ ១គ.ក្រ

រយៈពេលព្យាបាល :

ត្រូវព្យាបាលរាល់ថ្ងៃ រយៈពេលពី ៣ ទៅ ៥ថ្ងៃ

ប្រយ័ត្ន :

ហាមបរិភោគសាច់សត្វ បន្ទាប់ពីចាក់ថ្នាំនេះហើយ ២២ថ្ងៃ ។



# សិបតូទ្រីល (ចាក់)

## SEPTOTRYL24% (Injectable)

**១. សមាសធាតុ :** ជាថ្នាំសំរាប់ចាក់ ១ដប មានចំណុះ ១០០ម.ល ។ ជាពពួកថ្នាំ Sulfarmide

**២. គុណភាពវិធី :** ថ្នាំនេះប្រើសំរាប់សត្វ គោ ក្របី ជ្រូក មាន់ ទា .... ។ ជាល្បាយថ្នាំជាតិប្រេងប្រើសំរាប់ទប់ទល់ប្រឆាំង និងជំងឺ ដែលមានដូចខាងក្រោម :

-គ្រុនក្តៅ

-រលាកប្រព័ន្ធដកដង្ហើម ពិបាកដកដង្ហើម

-រលាកផ្លូវរំលាយអាហារ ក្រពះ ពោះវៀន

-គ្រុនពោះវៀន

-ហើមក ហើមពោះ (ជំងឺសារទឹក)

-រាគឈាម.... ។

**៣. វិធីប្រើប្រាស់ថ្នាំ :** ចាក់សាច់ដុំ

-គោ ក្របី :ប្រើ ២០ម.ល សំរាប់ ៣០០គ.ក្រ នៃទំងន់សត្វ

ប្រើ ១០ម.ល សំរាប់ ១៥០គ.ក្រ នៃទំងន់សត្វ

-កូនគោ ក្របី :ប្រើ ៤ម.ល សំរាប់ ៦០គ.ក្រ នៃទំងន់សត្វ

-ជ្រូក :ប្រើ ១ម.ល សំរាប់ ១៥គ.ក្រ នៃទំងន់សត្វ

-កូនជ្រូក :ប្រើ ១ម.ល សំរាប់ ១៥គ.ក្រ នៃទំងន់សត្វ

-បក្សី (តូច) :ប្រើ ០.២ម.ល សំរាប់ ១គ.ក្រ នៃទំងន់សត្វ

-បក្សី (ធំ) :ប្រើ ០.១៥ម.ល សំរាប់ ១គ.ក្រ នៃទំងន់សត្វ

✡ ចំពោះបក្សីធំ មិនត្រូវប្រើលើសពី ០.៥ម.ល សំរាប់សត្វមួយក្បាលឡើយ ។

**រយៈពេលព្យាបាល :** ត្រូវព្យាបាលរាល់ថ្ងៃ រយៈពេលពី ៣ ទៅ ៥ថ្ងៃ ។

**៤. ប្រយ័ត្ន :** -ហាមបរិភោគសាច់សត្វ បន្ទាប់ពីចាក់ថ្នាំនេះរយៈពេល ៣ថ្ងៃ ។

-មិនត្រូវប្រើលើសត្វកើត

-មិនត្រូវប្រើលើសត្វសេះ

-ត្រូវផ្តល់ទឹកឱ្យបានគ្រប់គ្រាន់

-មិនត្រូវប្រើលើសត្វដែលខូចតម្រងនោម

-អាចមានហើមលើកន្លែងចាក់



# សូតាប៉េន (ចាក់)
## SHOTAPEN (Injectable)

ថ្នាំនេះប្រើសំរាប់ គោ ក្របី ជ្រូក មាន់ ទា

ថ្នាំនេះ គឺជាអង់ទីប៊ីយ៉ូទិកមួយបែប សំរាប់ប្រើទប់ទល់ប្រឆាំងនឹងជំងឺ ដែលមានរោគសញ្ញាដូចខាងក្រោម

-គ្រុនក្តៅខ្លាំង មិនស៊ីចំណី

-ហើមពោះ ហើមក មានដុំពកៗ ហើយដុំពកនោះមានសភាពក្តៅ បើច្របាច់ឮសូរក្រិបក្រៀប

-ដង្ហើមញាប់ ច្រមុះស្ងួត ហៀរទឹកភ្នែក ទឹកមាត់

-រាគឈាម

-រលាកកន្សោមដោះ

-រលាកសួត មានហូរខ្ទុះ

-រលាកទងសួត ហើមសួត ក្អក

**វិធីប្រើថ្នាំ :** ចាក់សាច់ដុំ

ប្រើ ៥ទៅ១០ cc សំរាប់ទំងន់សត្វរស់ ១០០គ.ក្រ

ប្រើ ១ទៅ២ cc សំរាប់ទំងន់សត្វរស់ ២៥គ.ក្រ

**រយះពេលព្យាបាល :** (គឺជាថ្នាំដែលសកម្មយូរ)

☆ ចាក់ ១ម្ជុល នៅថ្ងៃទី១

មិនចាំបាច់ចាក់ថ្នាំនៅថ្ងៃទី ២ និងទី៣ទេ

☆ ចាក់១ម្ជុលទៀតនៅថ្ងៃទី ៤

**ប្រយ័ត្ន :**

ហាមបរិភោគសាច់សត្វ បន្ទាប់ពីចាក់ថ្នាំនេះហើយ ១០ថ្ងៃ ។

ហាមរិតទឹកដោះគោ បន្ទាប់ពីចាក់ថ្នាំនេះហើយ ៥ថ្ងៃ ។

# ប៉េនីស៊ីលីនហ្សេ ១លាន

## PENICILLINE G1000 000 LU

ជាថ្នាំអង់ទីប៊ីយ៉ូទិចមួយចាស់ជាងគេប្រើសំរាប់សត្វ គោ ក្របី ជ្រូក ។ ដើម្បីឱ្យអង់ទីប៊ីយ៉ូទិចនេះមានប្រសិទ្ធភាព ត្រូវចាប់ផ្ដើមព្យាបាលភ្លាមជាបន្ទាន់ ហើយគោរពយ៉ាងម៉ត់ចត់នូវកំរិត រយៈពេលនៃការព្យាបាល ។ ជួនកាលមេរោគមិនចាញ់អង់ទីប៊ីយ៉ូទិចទេ ហើយសត្វក៏មិនជាដែរ ។

**ការប្រើប្រាស់ :** សំរាប់ការពារ និងព្យាបាលជំងឺបណ្ដាលមកពីបាក់តេរី ។

**កំរិត និងវិធីប្រើ :** ចាក់ក្នុងសាច់ដុំ

-១ដប ( ១លាន IU ) ៥០គ.ក្រ នៃទំងន់សត្វ ។

-លាយថ្នាំជាមួយនិងទឹកសាប ៥ម.ល ក្រឡុកឱ្យសូលុយស្យុងស្មើល្អ ។

-បូមបញ្ចូលក្នុងសឺរាំងវិញ តាមកំរិតដែលត្រូវការ ។

-កុំទុកថ្នាំឱ្យលើសពី ៣ថ្ងៃ ។

**រយៈពេលនៃការប្រើ :**

-ព្យាបាល : ចាក់ ២ដង ក្នុង១ថ្ងៃ

រយៈពេលប្រើ ៣ថ្ងៃជាប់គ្នា ។

| ទំងន់សត្វ | ថ្ងៃទី១ | | ថ្ងៃទី២ | | ថ្ងៃទី៣ | |
|---|---|---|---|---|---|---|
| | ព្រឹក | ល្ងាច | ព្រឹក | ល្ងាច | ព្រឹក | ល្ងាច |
| ១-២៥គ.ក្រ | ១,៥ម.ល | ១,៥ម.ល | ១,៥ម.ល | ១,៥ម.ល | ១,៥ម.ល | ១,៥ម.ល |
| ២៥-៥០គ.ក្រ | ៣ម.ល | ៣ម.ល | ៣ម.ល | ៣ម.ល | ៣ម.ល | ៣ម.ល |
| ៥០គ.ក្រនិង លើស | ៥ម.ល | ៥ម.ល | ៥ម.ល | ៥ម.ល | ៥ម.ល | ៥ម.ល |

# អុកស៊ីតូស៊ីន (OXYTOCIN)

អុកស៊ីតូស៊ីន គឺជាអ័រម៉ូន (Hormone) ចេញមកតាមធម្មជាតិរបស់សត្វមេ ។ តាមធម្មតាវាតែងតែមានកំរិតខ្ពស់នៅពេលដែលវាកើតកូននិងពេលសត្វដោយឈ្មោល ។ មុខនាទីរបស់វាគឺធ្វើអោយសាច់ដុំស្បូនកន្ត្រាក់នៅពេល កើតកូនវាជួយជំរុញច្រានកូនចេញមកក្រៅ ។ នៅពេលពាក់គ្នាវាជួយជុំរុញដំណើររបស់ស្ពែម៉ាតូសូអ៊ែ Spermatozoa ឱ្យឆ្លងកាត់ស្បូន សំដៅទៅអូវែ (Ovaries) ។

អុកស៊ីតូស៊ីន និងមានឥទ្ធិពលរបស់វាទៅលើកោសិកាសាច់ដុំនៅចំពោះមុខការកើតឡើងក្នុងកំរិតខ្ពស់របស់អ័រម៉ូន (អឺស្រ្តូសែន) Oestrogen ។ នេះបង្ហាញថាហេតុអ្វីបានជាវាមានសកម្មភាពនៅពេលកើតកូននិងនៅពេលសត្វពាក់គ្នា ពេលហោគេចាក់បញ្ចូលអុកស៊ីតូស៊ីន វានឹងមានឥទ្ធិពលនៅពេលដែលអឺស្រ្តូសែនមានកំរិតខ្ពស់ឡើង ។

## ✡ ការប្រើប្រាស់ក្នុងការព្យាបាល :

១-បច្ចេកទេសបង្កើតកូន : ក្នុងហេតុការណ៍នៃការបង្កើតកូនត្រូវពន្យាពេលយូរ និងមានការហេវហត់ដល់សាច់ដុំស្បូន គេអាចប្រើថ្នាំអុកស៊ីតូស៊ីននេះសំរាប់ជំនួយដល់ការកន្ត្រាក់សាច់ដុំស្បូនម្តងទៀត ។ ជាពិសេសថ្នាំនេះមានប្រយោជន៍សំរាប់សត្វ ដែលមានកូនច្រើនដូចជា : ឆ្កែ និងជ្រូក ។ ពីព្រោះចំនួនកូនច្រើនពេក ទម្ងន់របស់កូនរួមផ្សំមួយនឹងពេលវែងក្នុងការបញ្ចេញ កូនមកក្រៅ វាបណ្តាលឱ្យស្បូនមានការហេវហត់ដោយងាយ ហើយវាពន្យឺតឈប់កន្ត្រាក់តែម្តង ដូច្នេះអុកស៊ីតូស៊ីនប្រយោជន៍ជាពិសេសសំរាប់ហេតុការណ៍បែបនេះ ព្រោះវាមានការលំបាកក្នុងការទាញកូនចេញមកក្រៅ ។

## ✡ ការប្រុងប្រយ័ត្ន :

-ត្រូវដឹងឱ្យច្បាស់ថា តើមាត់ស្បូនបានបើកពេញលេញហើយរឺនៅ? បើសិនមានកូនសត្វមួយរឺច្រើន និងថង់ទឹកភ្លោះត្រូវបានច្រានចេញ នោះមាត់ស្បូនត្រូវរីក ។ ចំពោះជ្រូកគេអាចស្ទាបដោយដៃបាន បើសិនជាគេប្រើអុកស៊ីតូស៊ីនមុនមាត់ស្បូនបានបើក នោះសំពាធនៃការកន្ត្រាក់កើតឡើងខ្លាំងនឹងបណ្តាលអោយរហែកស្បូន ។

-ត្រូវដឹងឱ្យច្បាស់ថា គ្មានអ្វីនៅស្ទះមាត់ស្បូនដូចជាកូននៅស្អិតជាប់គ្នា ជាការសំខាន់ ណាស់ត្រូវដឹងថាកូនសត្វស្ថិតនៅក្នុងស្ថានភាពធម្មតាដែលត្រូវចេញឬទេ? មុននឹងប្រើថ្នាំអុកស៊ីតូស៊ីន ។

២-បញ្ចេញទឹកដោះ : ចំពោះជ្រូកញី និងគោញីក្មេងដែលមានទឹកដោះតិច អុកស៊ីតូស៊ីនអាចប្រើប្រាស់បានតាមកំរិតកំហាប់ដូចខាងក្រោម ដើម្បីជំរុញឱ្យទឹកដោះហូរចេញតាមដោះ ។ ការធ្វើបែបនេះ វាមានប្រសិទ្ធភាពត្រឹមតែសប្តាហ៍ទី១និង ទី២នៃការបំបៅកូនតែប៉ុណ្ណោះ ។

- កំរិតប្រើប្រាស់ : ជ្រូកញី : ១០-២០ IU អុកស៊ីតូស៊ីន ចាក់សាច់ដុំ (I/M) ឬក្រោមស្បែក (S/C) គេអាចចាក់ម្តងទៀតក្នុងរយៈពេល ១៥-៣០នាទីក្រោយមក បើចាំបាច់ត្រូវប្រើ

  គោញី : ១០-៤០ IU អុកស៊ីតូស៊ីន ចាក់សាច់ដុំ (I/M) ។